អង្គការ សមធម៌កម្ពុជា
equitable cambodia



# របាយការណ៍ស្តីពី ស្ថានភាពឧស្សាហកម្ម រ៉ែមាស នៅកម្ពុជា៖ ការរំលោភសិទ្ធិមនុស្ស និង ការបំផ្លាញបរិស្ថាន

អង្គការ សមធម៌កម្ពុជា
equitable cambodia

អង្គការសមធម៌កម្ពុជាគឺជាអង្គការជាតិឈានមុខមួយក្នុងការស្វែងរកការគាំទ្រឲ្យមានការការពារសិទ្ធិលំនៅដ្ឋាន ដីធ្លី និងធនធានធម្មជាតិនៅកម្ពុជា។ អង្គការនេះត្រូវបានបង្កើតឡើងនៅឆ្នាំ២០១២ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ពីវិបត្តិនៃការរំលោភបំពានដីធ្លីដ៏រ៉ាំរ៉ៃ និងសិទ្ធិមនុស្ស។ តាមរយៈការស្រាវជ្រាវគោលនយោបាយ ការស្វែងរកការគាំទ្រនៅថ្នាក់ជាតិ និងអន្តរជាតិ ការបង្កើតក្រុមការងារចម្រុះ និងការរៀបចំចងក្រងសហគមន៍ អង្គការសមធម៌កម្ពុជាខិតខំប្រែក្លាយការអភិវឌ្ឍន៍ដីធ្លី និងសេដ្ឋកិច្ចរបស់ប្រទេស ឲ្យទៅជាគំរូមួយដែលគោរព ការពារ និងបំពេញសិទ្ធិប្រជាជនកម្ពុជាគ្រប់រូប។ អង្គការសមធម៌កម្ពុជានឹងសម្រេចគោលដៅរបស់ខ្លួន តាមរយៈកម្មវិធីថាមវន្តបី ដែលកម្មវិធីនីមួយៗខិតខំប្រឹងប្រែងដើរឆ្ពោះទៅរកចក្ខុវិស័យរបស់ប្រទេសកម្ពុជាមួយដែលពលរដ្ឋទាំងអស់អាចអាស្រ័យបានសិទ្ធិមនុស្សជាមូលដ្ឋាន ហើយធនធានធម្មជាតិរបស់ប្រទេសត្រូវបានគ្រប់គ្រងប្រកបដោយចីរភាពដើម្បីផលប្រយោជរួម។

សំរាប់ព័ត៌មានបន្ថែម
អាសយដ្ឋាន ផ្ទះលេខ២០៥ ផ្លូវលេខ១៤៥ ភូមិ៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចម្ការមន ក្រុងភ្នំពេញ
ទូរសព្ទលេខ (៨៥៥)២៣ ២១០ ៨០៥
សារអេឡិចត្រូនិច office@equitablecambodia.org
គេហទំព័រ https://equitablecambodia.org

រក្សាសិទ្ធិដោយ អង្គការ សមធម៌កម្ពុជា ឆ្នាំ២០២៣

របាយការណ៍នេះចេញផ្សាយ ខែធ្នូ ឆ្នាំ២០២៣

# មាតិកា


០១ សេចក្តីសង្ខេបមូលបទ

៣ វិធីសាស្ត្រស្រាវជ្រាវ និងដែនកំណត់

៤ ការពិភាក្សាអំពីប្រវត្តិ និងគោលនយោបាយ

១៦ ករណីសិក្សាទី១
ក្រុមហ៊ុនរ៉ែ៖ ក្រុមហ៊ុន អង្គរ ហ្គោល ខប, មេសកូ ហ្គោល

២៤ ករណីសិក្សាទី ២
ក្រុមហ៊ុនរ៉ែ៖ ក្រុមហ៊ុន រុងឆេង អ៊ីនដាសស្ទ្រៀល អ៊ិនវេសមិន (ខេមបូឌារ), រីណោសិន មីនីរ៉ល (ខេមបូឌារ)

៣៩ ករណីសិក្សាទី៣
ក្រុមហ៊ុនរ៉ែ៖ ក្រុមហ៊ុន ឌៃលខម កម្ពុជា ភីធីអី ស៊ិនហ្សាន អ៊ិនដាសស្ទ្រៀល

៥០ ករណីសិក្សាទី ៤
ក្រុមហ៊ុនរ៉ែ៖ ក្រុមហ៊ុន ស៊ីងយ៉ន កាងយៀក ខូអិលធីឌី

៦០ អនុសាសន៍

# សេចក្តីសង្ខេបមូលបទ

រាប់រយឆ្នាំមកនេះ ប្រជាជនកម្ពុជា បាននឹងកំពុងប្រតិបត្តិជីករុករករ៉ែខ្នាតតូច "ដោយប្រើដៃ" យករ៉ែនិង គ្រឿងអលង្ការ ដ៏មានតម្លៃ សម្រាប់ពាណិជ្ជកម្ម។ វិធីសាស្ត្រ និងសម្ភារដែលត្រូវបានប្រើប្រាស់គឺសាមញ្ញ មានផលប៉ះពាល់តិចតួច ដល់បរិស្ថាន ហើយការចំណាយលើ កម្លាំងពលកម្ម និងប្រតិបត្តិការទាប មានតម្លៃថោកសមរម្យ។ របាយការណ៍មួយរបស់ក្រសួងបរិស្ថានបានវាយតម្លៃថា "តំបន់ភាគពាយ័ព្យ (ជា)តំបន់ដែលមាន សុវត្ថិភាពបំផុត មួយក្នុងប្រទេសកម្ពុជា ដូច្នេះហើយមាន អំណោយផលដល់ អ្នកស្វែងរកមាស" នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ដែលជាការ ជម្រុញឱ្យមាន “សកម្មភាពស្វែងរកមាស យ៉ាងមមាញឹក ដោយកសិករ ក្នុងមូលដ្ឋាន។” ចាប់តាំងពីចូល សតវត្សរ៍ថ្មីមក ឧស្សាហកម្មនេះត្រូវបានផ្លាស់ប្តូរបន្តិចម្តងៗ ពីលក្ខណៈ “ខ្នាតតូច” បែបប្រពៃណី ទៅជាវិស័យសាជីវកម្ម ដោយផ្តោតលើផលិតកម្ម គ្រឿងយន្តខ្នាតធំ។ មន្ត្រីជាន់ខ្ពស់ម្នាក់របស់ គណបក្សកាន់អំណាច ក្នុងឆ្នាំ២០០៧ បាននិយាយថា ការពង្រីកឧស្សាហកម្មនេះ នឹងជួយដល់ “ការថយចុះ នៃការពឹងផ្អែក របស់ប្រទេសកម្ពុជាលើជំនួយពីម្ចាស់ជំនួយ និងលើប្រាក់កម្ចីដែល ជាបន្ទុកដ៏ធ្ងន់" និងបង្កើត “ប្រាក់បន្ថែមទៀតសម្រាប់ផ្នែកអប់រំ សុខភាព ហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីសង្គម និងការបង្កើន ឱកាសការងារ សម្រាប់យុវជនកម្ពុជាទាំងអ្នកមានជំនាញ និងគ្មានជំនាញ»។

ចាប់តាំងពីពេលនោះមក ការចូលកាន់កាប់ ដោយសាជីវកម្មលើធនធានរ៉ែ បានបន្តអនុញ្ញាតឱ្យក្រុម បុព្វការិជនអភិជន (party-elite rogenitors) ជាច្រើននៃឧស្សាហកម្មនេះ ទទួលបានប្រាក់ចំណេញអតិបរិមា និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ខណៈពេលដែលកាត់បន្ថយគណនេយ្យភាពប្រដោយប្រសិទ្ធភាព។

ការពង្រីក ការធ្វើគ្រឿងយន្តកម្ម និងការប្រើប្រាស់សារធាតុគីមី របស់ឧស្សាហកម្មនេះ បានបង្កើនហានិភ័យ នៃ ការទន្ទ្រានយកដីធ្លី ការបំផ្លាញបរិស្ថាន និងសុខភាព និងសុវត្ថិភាពការងារសម្រាប់ប្រជាពលរដ្ឋ និងសហគមន៍របស់ប្រទេសកម្ពុជា ជាពិសេសជនជាតិដើមភាគតិច។ ហានិភ័យទាំងនេះក៏បង្កភាពកាន់តែធ្ងន់ធ្ងរដល់ការរំលោភសិទ្ធិមនុស្ស ដែលមានពីមុនមក ជាពិសេសការរំលោភលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលការពារសិទ្ធិក្នុងការទទួលបានទីលំនៅ និងដីគ្រប់គ្រាន់ដែលចាំបាច់សម្រាប់ការចិញ្ចឹមជីវិត និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច។ ការគាស់កាយសាងសង់ផ្លូវទៅកាន់តំបន់ដាច់ស្រយាលសម្រាប់ការទាញយករ៉ែ និងការចម្រាញ់យករ៉ែមាសបង្កើនអត្រាហានិភ័យខ្ពស់ដល់ការកាប់បំផ្លាញព្រៃឈើ ជាសកល។

សំឡេងរបស់ជនជាតិដើមភាគតិចនៅតែបន្ត ត្រូវបានគេព្រងើយកន្តើយ ឬមិនត្រូវបានគិតគូរ ហើយបទប្បញ្ញត្តិពិសេសសម្រាប់ការការពារសិទ្ធិនៅក្នុងច្បាប់អន្តរជាតិ និងច្បាប់កម្ពុជាមិនត្រូវបានអនុវត្តជាប្រព័ន្ធឡើយ។ ក្តីព្រួយបារម្ភអំពីបរិស្ថានទាក់ទងនឹងការកាប់បំផ្លាញព្រៃឈើ ការគ្រប់គ្រងកាកសំណល់ពុល និងការបាត់បង់ជីវចម្រុះ នៅតែមិនត្រូវបាន

ដោះស្រាយឱ្យបានទាន់ពេលវេលា។

រដ្ឋនៅតែគ្រប់គ្រងលើ ការចេញអាជ្ញាប័ណ្ណ ជីករ៉ែ និងការបន្តការចូលរួម របស់តួអង្គនយោបាយដ៏មានឥទ្ធិពលបង្ហាញ ពីបញ្ហាតម្លាភាព និងគណនេយ្យភាព។ ដោយមើលឃើញ កាលៈទេសៈទាំងនេះ បទបញ្ញត្តិស្តីពី ការផ្តល់អាជ្ញាប័ណ្ណនៅតែជាចំណុចចម្បង នៃការរិះគន់របស់សង្គមស៊ីវិលចំពោះឧស្សាហកម្មនេះ។ ការដ្ឋានជីករ៉ែដំណាក់កាលចម្រាញ់មួយដែលកំពុងធ្វើប្រតិបត្តិការ ក្នុងខេត្តមណ្ឌលគិរី មានប្រវត្តិក្រុមហ៊ុនដែលធ្លាប់មានស្លាកស្នាមត្រូវបានកាត់ទោសដោយតុលាការជាតិប្រទេសអូស្ត្រាលីថ្មីៗនេះ ដែលបានផាកពិន័យអតីតម្ចាស់ក្រុមហ៊ុនជាង ១០ លានដុល្លារអាមេរិក ពីបទសូកប៉ាន់មន្ត្រីកម្ពុជា ដែលការណ៍នេះពិបាកនឹងចាត់ទុកថាជារឿងធម្មតា ហើយនឹងមិនកើតឡើងម្តងទៀតណាស់។

សហគមន៍មូលដ្ឋាន ដែលជាអាជីវកម្មជីករ៉ែមាសខ្នាតតូចបែបបុរាណ (ASGM) - ជាពិសេសអ្នកដែលអនុវត្តបច្ចេកទេស ដែលមិនប៉ះពាល់ដល់បរិស្ថានដោយប្រើប្រាស់ សារជាតុគីមីតិចតួច ឬមិនប្រើសោះ - កាន់តែកំពុងរងគ្រោះ ដោយក្រុមហ៊ុនធំៗដែលកំពុងផ្លាស់ទៅកាន់តំបន់ ដែលពីមុនត្រូវបានប្រើប្រាស់ដោយ អ្នកជីករ៉ែមាសដោយដៃ ក្នុងទ្រង់ទ្រាយតូច បែបបុរាណ។ ស្ថានភាពនេះគឺកាន់តែអាក្រក់ជាងនេះ នៅក្នុងតំបន់មួយចំនួនទៀត ហើយសម្ពាធនេះ បានបន្តដាក់បន្ទុកលើ អ្នកជីករ៉ែមាសដោយដៃ ក្នុងទ្រង់ទ្រាយតូច បែបបុរាណឱ្យបោះបង់ចោលប្រតិបត្តិការ របស់ពួកគេនៅក្នុងតំបន់ជាច្រើន។

បញ្ហាផ្សេងទៀតក៏នៅតែជាក្តីបារម្ភផងដែរ៖ សិទ្ធិការងារ និងលក្ខខណ្ឌការងារនៅតែអន់ជាងវិស័យសំខាន់ៗផ្សេងទៀត ដំណើរការពិគ្រោះយោបល់សាធារណៈ និងយុទ្ធសាស្ត្រ សម្រាប់ប្រតិបត្តិការដែលអាចមាន នាពេលអនាគតគឺមិនមានលក្ខណៈជាប្រព័ន្ធ និងមិនកំណត់ច្បាស់លាស់ពីទស្សនៈបទបញ្ញត្តិ ហើយវេទិកាសន្ទនាជាមួយតួអង្គសង្គមស៊ីវិលកាន់តែថយចុះទៅៗ ក្នុងកំឡុងឆ្នាំថ្មីៗនេះ។

ក្រសួងរ៉ែ និងថាមពលនិយាយថា ខ្លួនបានបង្កើត "មូលនិធិគាំទ្រសង្គម" ដោយប្រើប្រាក់ដែលបានរួមចំណែកដោយ តួអង្គឧស្សាហកម្មរ៉ែ ប៉ុន្តែសហគមន៍បង្ហាញពីការលំបាក ក្នុងការទទួលបានមូលនិធិនោះ វាមិនច្បាស់ទេថា មូលនិធិនោះ ត្រូវបានប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាព ប៉ុណ្ណានោះទេក្នុងការកែលម្អ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗសម្រាប់សហគមន៍ក្នុងមូលដ្ឋាន។ ម៉្យាងទៀត មានភាពមិនច្បាស់លាស់ ជាប្រព័ន្ធថា តើកំណើនដែលបានរំពឹងទុក ប្រាក់ចំណូលរបស់រដ្ឋ ដែលទទួលបានពីសួយសារអាករ(royalties) និងការបង់ពន្ធនឹងជួយជម្រុញការផ្តល់មូលនិធិ សម្រាប់សេវាគាំទ្រសង្គមដោយរបៀបណា បើតម្លាភាពនៃប្រាក់ចំណូលនៅបន្តជាបញ្ហាយ៉ាងខ្លាំង នៅក្នុងប្រទេសគ្រប់វិស័យ។

ឯកសារស្រាវជ្រាវនេះ មានបំណងផ្តល់ទស្សនៈ អំពីទិដ្ឋភាពផ្សេងៗ នៃវិស័យនេះ៖ ការពិនិត្យមើលប្រវត្តិនៃវិស័យនេះ ចាប់តាំងពី សាជីវកម្មរបស់ខ្លួន ការវិភាគនៃការឆ្លើយតបរបស់រដ្ឋ និងសង្គមស៊ីវិល និងការវាយតម្លៃអំពីស្ថានភាពទូទៅនៃវិស័យនេះ ដូចដែលវាស្ថិត នៅក្នុងឆ្នាំ ២០២៣នេះ។ នៅក្នុងរបាយការណ៍នេះ មានករណីសិក្សា ចំនួនប្រាំនឹងបង្ហាញពីតថភាពបច្ចុប្បន្ននៃវិស័យនេះ និងអ្នកពាក់ព័ន្ធផ្សេងៗ រួមទាំងប្រជាពលរដ្ឋក្នុងមូលដ្ឋាន តួអង្គ

[9] បទសូកប៉ាន់មន្ត្រីកម្ពុជា៖ សូមចូលទៅកាន់តំណៈ https://www.afp.gov.au/news-centre/media-release/australian-mining-company-investigated-afp-over-alleged-foreign-bribery

ឧស្សាហកម្ម និងសមាជិកសង្គមស៊ីវិល។
បន្ទាប់ពីរយៈពេល ២០ឆ្នាំ នៃការបន្តធ្វើសាជីវកម្ម ឧស្សាហកម្មជីករ៉ែមាស តែគួរឱ្យសោកស្តាយ មានសញ្ញាតិចតួច នៃការកែលម្អគោលនយោបាយ និងការអនុវត្ត ទាក់ទងនឹងសិទ្ធិមនុស្ស និងសិទ្ធិដីធ្លី ការការពារបរិស្ថាន តម្លាភាព និងគណនេយ្យភាព។ ជារួម វិស័យរ៉ែទាំងមូលនៅតែទទួលរងនូវបញ្ហាធំៗ នៅក្នុងតំបន់ទាំងនេះ។
ចំណាត់ការម៉ត់ចត់ និងជាបន្ទាន់ត្រូវបានតម្រូវឱ្យធ្វើឡើងដើម្បីពិនិត្យមើលឡើងវិញនូវអាជ្ញាប័ណ្ណរុករករ៉ែ និងប្រតិបត្តិការជំណាក់កាលចម្រាញ់ទាំងអស់ក្នុងន័យបង្ការជម្លោះនាពេលអនាគតជាមួយសហគមន៍ក្នុងមូលដ្ឋាន និងការបំផ្លាញបរិស្ថាន និងជួយដល់ប្រទេសកម្ពុជា ចង់បង្ហាញឧស្សាហកម្មនេះថាជាការវិនិយោគដ៏ទាក់ទាញទៅកាន់ប្រតិបត្តិករសក្តានុពលដែលមានបំណងចូលឧស្សាហកម្មនេះ។ ការត្រួតពិនិត្យ មើលឡើងវិញ ទាំងនេះគួរបញ្ចូលជាចាំបាច់នូវ ការគិតគូរពេញលេញ អំពីការរំលោភសិទ្ធិមនុស្ស ទាំងពេល អតីតកាល និងពេលបច្ចុប្បន្ន និងផែនការសកម្មភាព គ្រប់ជ្រុងជ្រោយដើម្បី ដោះស្រាយបញ្ហាទាំងនេះ វិធានការពង្រឹងយុទ្ធសាស្ត្រ ការពារបរិស្ថាន និងវិធានការក្នុងការធ្វើឱ្យមានអាទិភាពនូវ តម្លាភាព ទាក់ទិននឹង ភាពជាកម្មសិទ្ធិ ដែលមានអត្ថប្រយោជន៍។

*វាជារឿងសំខាន់ ដែលវិស័យរ៉ែទាំងមូល ត្រូវផ្តោតលើ ប្រយោជន៍ប្រជាពលរដ្ឋកម្ពុជា និងបរិស្ថានជាជាងការផ្តោតលើ តែប្រាក់ចំណេញ និងសួយសារអាករ របស់សាជីវកម្ម។*

## វិធីសាស្ត្រស្រាវជ្រាវ និងដែនកំណត់

សម្រាប់ ករណីសិក្សា នៅក្នុង របាយការណ៍ នេះ ទិន្នន័យ ត្រូវបានប្រមូលដោយ ធ្វើការពិភាក្សាផ្តោតជាក្រុម (FGDs) ជាមួយ សហគមន៍មូលដ្ឋាន ដែលរស់នៅក្នុង និងជិតតំបន់ជីកយករ៉ែ ដែលកំពុងត្រូវបានធ្វើអាជីវកម្មដោយសាជីវកម្មធំៗ។ ការសម្ភាសក៏ត្រូវបានធ្វើឡើងជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ រួមមានកម្មករក្រុមហ៊ុន មន្ត្រីមូលដ្ឋាន (មន្ត្រីឃុំ និងមេភូមិ) និងអង្គការសង្គមស៊ីវិលនានាផងដែរ។ ជាសរុបមានមនុស្សចំនួន ៥៩ នាក់ត្រូវបានសម្ភាស សម្រាប់ឯកសារស្រាវជ្រាវនេះ។ ការសម្ភាស និង ការពិភាក្សា ផ្តោតជាក្រុមត្រូវបានធ្វើឡើងក្នុងរយៈពេល ជាងពីរខែក្នុងឆ្នាំ ២០២៣។ អ្នកស្រាវជ្រាវបាន ជួបប្រទះនូវ ឧបសគ្គមួយចំនួន៖ ការងារចុះទៅសម្ភាស ចំពេលនឹង ការបោះឆ្នោតជាតិដ៏ចម្រូងចម្រាស ដែលបានធ្វើឡើង នៅខែកក្កដា ឆ្នាំ២០២៣។ ការដកសិទ្ធិ របស់គណបក្សប្រឆាំងធំពីសន្លឹកឆ្នោត និងបរិយាកាស នយោបាយតានតឹង បានបណ្តាលឱ្យ អ្នកឆ្លើយសំណួរ មិនសូវមានឆន្ទៈក្នុងការចូលរួម ដោយបើកចំហ តាមដែលអាចធ្វើទៅបានដោយសារ ការភ័យខ្លាច នៃការសងសឹកចំពោះការរិះគន់ ពិតប្រាកដ ឬតាមការយល់ឃើញ អំពីគោលនយោបាយ ឬការអនុវត្តរបស់រដ្ឋាភិបាល។ លើសពីនេះ ការទាក់ទង ទៅមន្ត្រីជាន់ខ្ពស់ របស់រដ្ឋាភិបាល មានការលំបាកខ្លាំងណាស់ ប៉ុន្តែជាថ្មីម្តងទៀត នេះប្រហែលអាចមកពី មន្ត្រីទាំងឡាយមិនចង់ពិភាក្សាអំពី បញ្ហាគោលនយោបាយ និងការអនុវត្តនៅក្នុងបរិបទនៃយុទ្ធនាការបោះឆ្នោត។

| ព័ត៌មានត្រួសៗរបស់អ្នកផ្តល់បទសម្ភាស | ចំនួនអ្នកផ្តល់បទសម្ភាស |
|---|---|
| អ្នកភូមិដែលត្រូវបានរងប៉ះពាល់ដោយប្រតិបត្តិការជីករ៉ែ | ៣១នាក់ (៤នាក់ជាជនជាតិដើមភាគតិច) |
| មេឃុំ | ១ |
| អ្នកដឹកនាំសហគមន៍ | ៣ |
| កម្មករក្រុមហ៊ុន | ១០ |
| តំណាងអង្គការក្រៅរដ្ឋាភិបាល | ៨ |
| មេភូមិ | ៥ |
| អ្នកគ្រប់គ្រងក្រុមហ៊ុន | ១ |

## ការពិភាក្សាអំពីប្រវត្តិ និងគោលនយោបាយ

មានការសរសេរ ជាច្រើនអំពី ឧស្សាហកម្មរ៉ែមាស នៅប្រទេសកម្ពុជា។ ក្របខណ្ឌច្បាប់ផ្សេងៗត្រូវបានបង្កើតឡើងក្នុងរយៈពេល ២០ឆ្នាំ ចុងក្រោយនេះ ដែលនាំឱ្យ សង្គមស៊ីវិល មួយចំនួន មានការពិនិត្យមើលអំពី ក្របខណ្ឌ និងគោលនយោបាយទាំងនោះ រួមទាំងការអនុវត្តជាក់ស្តែង ក្នុងប្រតិបត្តិការគម្រោង ជាក់លាក់មួយចំនួន។ រូបភាពនៃច្បាប់ គោលនយោបាយ និងក្របខណ្ឌនិយតកម្មនេះ មិនត្រូវបានរំពឹងថា ត្រូវបានពិនិត្យមើលគ្រប់ជ្រុងជ្រោយនោះទេ។ ផ្ទុយទៅវិញ វានឹងបង្ហាញ បែបខ្លីៗ នូវបរិយាកាស ពិភាក្សាអំពី គោលនយោបាយទូទៅនៅក្នុងប្រទេស និងផ្តល់នូវ ការវិភាគត្រួសៗអំពីកិច្ចប្រឹងប្រែងបែបទំនើប ជាលើកដំបូង ក្នុងការធ្វើរៀបចំបទប្បញ្ញត្តិស្តីពី ការរុករករ៉ែនៅក្នុងប្រទេស។ បញ្ហាសំខាន់ៗជាច្រើន ដែលជាប់ពាក់ព័ន្ធ នឹងប្រធានបទនេះ កើតឡើងពីការវិភាគ លើព័ត៌មានដែលកើតឡើងរយៈពេលពីរទសវត្សរ៍កន្លងមក ជុំវិញវិស័យរ៉ែនៅកម្ពុជា ហើយបញ្ហាអវិជ្ជមាន មួយចំនួនបង្ហាញពីការខ្វះការយកចិត្តទុកដាក់ ជាអកុសល។ ចំណុចចាប់ផ្តើម សម្រាប់ការវិភាគនេះ គឺច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើ អាជីវកម្មធនធានរ៉ែ[២] ("ច្បាប់") ដែលជាកិច្ចប្រឹងប្រែង បែបទំនើបដំបូងក្នុង ការធ្វើកំណែទម្រង់ក្នុងឧស្សាហកម្មនិស្សារណកម្ម ហើយទាញបន្ថែមទៀតលើ ការផ្លាស់ប្តូរក្របខណ្ឌច្បាប់ផ្សេងៗ និងការឆ្លើយតបរបស់សង្គមស៊ីវិលរហូតដល់បច្ចុប្បន្ន។

[២] ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ៖ សូមចូលទៅកាន់តំណ: http://www.mme.gov.kh/documents/255/MME_National_Policy-EN.pdf

## ការការពារបរិស្ថាន

មាត្រា ២១ នៃច្បាប់នេះចែងអំពី ការការពារបរិស្ថាន និងលើកឡើងពីតម្រូវការ ក្នុងការគោរពតាមច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ដូចដែលនឹងបាន បញ្ជាក់យ៉ាងច្បាស់ នៅក្នុងឯកសារ ស្រាវជ្រាវនេះ ការការពារបរិស្ថាន និងសិទ្ធិមនុស្ស របស់អ្នកភូមិក្នុងមូលដ្ឋាន ជាធម្មតាត្រូវបានចាត់ទុកជា ការពិចារណាបន្ទាប់បន្សំ ដោយផ្តល់ភាពសំខាន់ជាង ទៅលើភាពចាំបាច់ និងភាពបន្ទាន់នៃសេដ្ឋកិច្ចជាតិ ពីសំណាក់ អ្នកបង្កើតគោលនយោបាយ ហើយតួអង្គសង្គមស៊ីវិល ផ្តោតសំខាន់ជាងលើតម្លាភាព និង គណនេយ្យភាពនៅចំណុចប្រាស្រ័យទាក់ទងគ្នា រវាងភាគីពាក់ព័ន្ធរបស់សាជីវកម្ម-រដ្ឋាភិបាល។ ពុំមានការសិក្សាពេញលេញណាមួយបានផ្តោតលើ ការព្យាយាមបង្ហាញ ឱ្យឃើញនូវទំហំដែល ឧស្សាហកម្ម និស្សារណកម្មកំពុង បំផ្លាញបរិស្ថានតាមរយៈ ការកាប់បំផ្លាញព្រៃឈើ ការចោលកាកសំណល់ពុល និងការបាត់បង់ជីវចម្រុះនោះទេ។

និយាយពី គោលនយោបាយជាតិស្តីពី ធនធានរ៉ែ ឆ្នាំ២០១៨-២០២៨ ចំនុចទី៥ គោលបំណងទី២ ចែងថា “ជាទូទៅ ការស្វែងរក និងការរុករកធនធានរ៉ែ មិនបង្កផលប៉ះពាល់ ធ្ងន់ធ្ងរ ដល់បរិស្ថានទេ។ ទោះ យ៉ាងណាក៏ដោយ សកម្មភាព ទាំងនេះនៅក្នុងតំបន់ ការពារធម្មជាតិ ត្រូវធ្វើតាម នីតិវិធីជាក់លាក់ មិនដូចនៅក្នុង តំបន់ផ្សេងទៀតទេ»។ ផែនការសកម្មភាព ពាក់ព័ន្ធ នៅក្នុងឯកសារគោលនយោបាយ រួមមានការបង្កើត “នីតិវិធីដាច់ដោយឡែកមួយក្នុង ការផ្តល់អាជ្ញាប័ណ្ណរ៉ែនៅក្នុងតំបន់ការពារធម្មជាតិ និងការកំណត់វិធានការចាំបាច់សម្រាប់ ការការពារបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ រុក្ខជាតិ និងសត្វ។ ការប្រើប្រាស់បច្ចេកវិទ្យាទំនើបនៃការធ្វើអាជីវកម្មរ៉ែ ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ អ្នកនិពន្ធនៃរបាយការណ៍នេះមិនអាចរកឃើញភស្តុតាងណាមួយ ដែលថារដ្ឋាភិបាលបានធ្វើសកម្មភាពលើ ការសន្យានេះ ប្រកបដោយអត្ថន័យ ឬបានច្រើននោះទេ។ ខណៈពេលដែលគោលនយោបាយ ជាអកុសល ធ្វើឱ្យមានភាពមិនច្បាស់លាស់ រវាងសកម្មភាពរុករក (ដែលបានលើកឡើងយ៉ាងច្បាស់) និងការចម្រាញ់ (គ្រាន់តែថ្លែងបង្កប់ន័យ តាមរយៈ ចំណុចសកម្មភាព) យ៉ាងហោចណាស់ ថ្លែងបង្កប់ន័យ នូវការទទួលស្គាល់ថា ការជីកយករ៉ែនៅ ក្នុងតំបន់ការពារធម្មជាតិ គឺមានគ្រោះថ្នាក់ជាង។ យ៉ាងណាក្តី មានភស្តុតាងតិចតួច ឬគ្មានភស្តុតាងសោះតែម្តង ដែលបង្ហាញថា ការទទួលស្គាល់នេះ កំពុងត្រូវបានគិតគូរយ៉ាងម៉ត់ចត់ ដើម្បីធ្វើឱ្យ ចេញជា សកម្មភាពប្រកបដោយអត្ថន័យ ឬផ្តល់អាទិភាពដល់ ការពិចារណាលើបញ្ហាបរិស្ថាន នៅក្នុងតំបន់ទាំងនេះ។

## សិទ្ធិដីធ្លី

យោងតាមមាត្រា ២៥ គ្រោងការណ៍សំណងខូចខាត ត្រូវបានបង្កើតឡើងដែលបង្កើតសិទ្ធិឱ្យ "ម្ចាស់ដី" ត្រូវបានផ្តល់សំណងដោយប្រតិបត្តិករជីករ៉ែ "ទាំងក្នុងនិងក្រៅតំបន់មានអាជ្ញាប័ណ្ណចំពោះការខូចខាតដែលបណ្តាលមកពីប្រតិបត្តិការជីក រ៉ែរបស់ពួកគេ ដោយមិនគិតពីការខូចខាតដោយចៃដន្យឬរំពឹងទុកឡើយ"។ ប៉ុន្តែគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលវិសាលភាពច្បាស់លាស់នៃសិទ្ធិនេះត្រូវបានកំណត់មិនត្រឹមត្រូវ៖

"...នៅពេលដែលតំបន់ប្រតិបត្តិការជីករ៉ែដែលបានកំណត់ក្នុងអាជ្ញាប័ណ្ណប៉ះពាល់ដល់ដីកម្មសិទ្ធិ ម្ចាស់ដី ត្រូវអនុញ្ញាតឱ្យ អ្នកកាន់អាជ្ញាប័ណ្ណធ្វើប្រតិបត្តិការជីករ៉ែ លើដីនោះដោយមានការព្រមព្រៀងគ្នាជាមុនដោយម្ចាស់ដី នឹងទទួលបានសំណងត្រឹមត្រូវ និងយុត្តិធម៌។"

ចាប់ពីកថាខណ្ឌបន្ទាប់ពីការបង្កើតសិទ្ធិនេះ វាអាចត្រូវបានសម្គាល់ឃើញថា ប្រសិនបើ "កិច្ចព្រមព្រៀងគ្នា" នេះ (សន្មតថាសម្រាប់ចំនួនទឹកប្រាក់ និង/ឬប្រភេទនៃសំណង) មិនអាចសម្រេចបាន នោះយន្តការ ដោះស្រាយភាពជាប់គាំង នេះត្រូវពាក់ព័ន្ធនឹងអន្តរាគមន៍របស់ក្រសួង ឬការបញ្ជូនវិវាទឱ្យគណៈកម្មាធិការដោះស្រាយ។ ប្រសិនបើអ្វីៗបរាជ័យ វិវាទនឹងត្រូវបានធ្វើមជ្ឈត្តកម្មដោយប្រព័ន្ធតុលាការកម្ពុជា ដែលត្រូវបានធ្វើឱ្យពាក់ព័ន្ធនឹងនយោបាយ។ មិនមានសញ្ញាបង្ហាញថាតើតម្លៃដីគួរត្រូវបានវាយតម្លៃដោយរបៀបណា និងតើគណៈកម្មាធិការ ដោះស្រាយវិវាទដែលបានស្នើឡើងត្រូវធ្វើមជ្ឈត្តកម្មលើរឿងក្តីដោយរបៀបណានោះដែរ។ មានរឿងមួយដែលច្បាស់លាស់ គឺ មានគម្រូជាច្រើនទាក់ទងនឹងម្ចាស់ដីនៅជនបទដែលត្អូញត្អែរពីការបាត់បង់ដី ហើយមិនទទួលបានសំណងពីប្រតិបត្តិការជីករ៉ែនៅទូទាំងប្រទេស ដោយធ្វើឱ្យពួកគេជ្រើសរើសធ្វើការតវ៉ាជាសាធារណៈ ដែលបន្ទាប់មកត្រូវបានដោះស្រាយដោយមិនមានលក្ខណៈជាប្រព័ន្ធ និងតាមរយៈបញ្ចប់រឿងលឿនដោយគ្មានការគ្រោងទុក។ នេះផ្តល់ជាឧទាហរណ៍ដ៏ល្អមួយអំពី គ្រោងការណ៍ច្បាប់ដែល ត្រូវបានរៀបចំឡើងមិនទាន់រឹងមាំ ដែលត្រូវគិតគូរ ពីការបកស្រាយ ប្រកបដោយ ភាពច្នៃប្រឌិតនៃច្បាប់ឱ្យសមស្របនឹងផលប្រយោជន៍ដែលផ្តល់ឱ្យ ឬដែលត្រូវបានមិនអើពើដោយសារភាព មិនច្បាស់លាស់។ មាត្រា ២៦ គឺកាន់តែស្មុគស្មាញទៅទៀត។ វាហាក់ដូចជាបង្កើតសិទ្ធិនៃសំណងសម្រាប់ "ប្រជាជន (ដែល) កំពុងរស់នៅក្នុងតំបន់ប្រតិបត្តិការដែលមានអាជ្ញាប័ណ្ណ" ដែលចែងថានីតិវិធីដែលត្រូវអនុវត្តតាមគឺដូចគ្នាទៅនឹងនីតិវិធីក្នុងមាត្រា ២៥ ខាងលើ។ វាស្រពិចស្រពិលថាតើការកាន់កាប់ដីធ្លីនៅកម្រិតណាឱ្យពិតប្រាកដដែលពួកគេនឹងត្រូវការដើម្បីបញ្ជាក់ថាពួកគេ "រស់នៅ" នៅក្នុងតំបន់នេះ។ ចំពោះទិដ្ឋភាពដ៏សំខាន់ និងស្មុគស្មាញនៃការកំណត់សិទ្ធិដីធ្លីបែបនេះ បទប្បញ្ញត្តិច្បាប់ និងការការពារផ្នែកច្បាប់គឺគ្មានទាល់តែសោះ ។

ការអនុវត្តសិទ្ធិដីធ្លីជាច់ស្រេចទាំងនេះមានភាពមិនស៊ីសង្វាក់គ្នាខ្លាំង ហើយអត្ថបទព័ត៌មានជាច្រើន និងការពិនិត្យមើលរបស់សង្គមស៊ីវិល បានបញ្ជាក់ភស្តុតាងពីការរំលោភម្តង ហើយម្តងទៀតលើ

បទប្បញ្ញត្តិទាំងនេះ ។
របាយការណ៍ឆ្នាំ ២០១០ ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ថ្លែងថា ការសម្ភាសជាមួយម្ចាស់សម្បទានបានបង្ហាញពី "ការលំបាកក្នុងការទទួលបានបញ្ជីឈ្មោះអ្នកកាន់កាប់ដី" ហើយដោយឡែក ពោលពី "អ្នកកាន់កាប់ដីខុសច្បាប់"។ នេះបង្ហាញឱ្យឃើញយ៉ាងច្បាស់៖ វិស័យឯកជនត្រៀមខ្លួនលុបចោលការទទួលខុសត្រូវចំពោះការចាត់ទុកសិទ្ធិដីធ្លីស្របច្បាប់ជាកង្វល់ស្នូលនៃឧស្សាហកម្មទៅឱ្យខាងណាមួយ ដែលការទទួលខុសត្រូវនោះប្រហែលអាចត្រូវបានប្រគល់ឱ្យទៅការិយាល័យធិបតេយ្យរដ្ឋបាលដែលគ្មានប្រសិទ្ធភាពមួយ។

## សិទ្ធិជនជាតិដើមភាគតិច

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ក្នុងឆ្នាំ ២០១៧ រយៈពេលប្រាំមួយឆ្នាំបន្ទាប់ពីការអនុម័តច្បាប់នេះ។ ប៉ុន្តែមិនទាន់មានវិសោធនកម្មចំពោះច្បាប់នោះ ដែលនឹងរក្សាការទទួលស្គាល់សិទ្ធិជនជាតិដើមទៅក្នុងដំណើរការតាមវិស័យទេ ហើយមិនមានគម្រូច្បាស់លាស់អំពីការផ្លាស់ប្តូរនិយតកម្មដើម្បីទទួលស្គាល់សិទ្ធិទាំងនេះទេ។
តាមប្រវត្តិសាស្ត្រ ក្រុមជនជាតិដើមក្នុងប្រទេសកម្ពុជាបានចូលរួមក្នុងការជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូច និងមិនប៉ះពាល់ដល់បរិស្ថាន ។ ប៉ុន្តែចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក ពួកគេត្រូវបានរុញច្រានចេញពីតំបន់ជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចបែបប្រពៃណីទាំងនេះ ជាពិសេសនៅក្នុងខេត្តមណ្ឌលគិរី ក្រចេះ រតនគិរី និងព្រះវិហារ ដែលជាតំបន់ដែលការសិក្សាបច្ចុប្បន្នផ្តោតលើ។
ដោយសារការកាប់បំផ្លាញព្រៃឈើនៅតែបន្តនៅក្នុងតំបន់ទាំងនេះ ជាពិសេសដោយសារតែមានការសាងសង់ផ្លូវថ្នល់ឱ្យកាន់តែប្រសើរឡើងដើម្បីជួយសម្រួលដល់ការពង្រីកប្រតិបត្តិការជីករ៉ែ ក្រុមសង្គមស៊ីវិលជនជាតិដើមភាគតិចមានការព្រួយបារម្ភកាន់តែខ្លាំងឡើងអំពីការកាត់ផ្តាច់ការផ្សារភ្ជាប់វប្បធម៌ទាក់ទងនឹងទំនៀមទម្លាប់ និងប្រពៃណីដែលជនជាតិដើមភាគតិចមានជាមួយព្រៃប្រពៃណី និងព្រៃអារក្ស ជាពិសេសពាក់ព័ន្ធនឹងសាសនាអំពីវិញ្ញាណ និងចំណេះដឹងបែបប្រពៃណី។
របាយការណ៍របស់អង្គការJICAដែលបានលើកឡើងពីមុនក៏សរសេរអំពីជនជាតិដើមភាគតិចកម្ពុជា ដែលរងផលប៉ះពាល់ខ្លាំងជាងគេដោយការរំលោភសិទ្ធិ និងការបំផ្លាញបរិស្ថានទាក់ទងនឹងវិស័យជីកយករ៉ែ។ អ្នកនិពន្ធរបាយការណ៍នេះ បានលើកឡើងពីការសិក្សាមួយពីទសវត្សរ៍ឆ្នាំ ១៩៦០ ក្នុងផ្នែកមួយអំពីសហគមន៍ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា ហើយបានដកស្រង់ឃ្លាថា «មិនមែនជនជាតិខ្មែរទេ ប្រវត្តិជនជាតិដើមរបស់ពួកគេមានលក្ខណៈមិនច្បាស់លាស់។ រដ្ឋាភិបាលកម្ពុជាបានហៅអ្នកខ្ពង់រាបថា ខ្មែរលើ (ខ្មែរនៅដីខ្ពស់) ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ ហើយបានព្យាយាមបញ្ចូលពួកគេជាមួយនឹងប្រជាជនកម្ពុជា»។
ការដឹងមិនស៊ីជម្រៅ និងការកំណត់លក្ខណៈដោយខ្វះការយល់ដឹងអំពី ជនជាតិដើមភាគតិច និងវប្បធម៌នានាបង្ហាញពីការខ្វះខាតការយល់ដឹងពេញលេញអំពីបញ្ហាទាក់ទងនឹងសហគមន៍ជនជាតិ

ដើមភាគតិច។

និយាយពីគោលនយោបាយជាតិស្តីពីធនធានរ៉ែ ២០១៨-២០២៨ ដែលជាការទទួលស្គាល់កម្រិតគោលនយោបាយជាតិលើកដំបូងអំពីសិទ្ធិជនជាតិដើម ទាក់ទិនដោយផ្ទាល់នឹងផលប្រយោជន៍របស់ជនជាតិដើមភាគតិចកម្ពុជាក្រោមផ្នែក "ការអភិវឌ្ឍសហគមន៍" នៃឯកសារ។

ផ្នែកទាំងមូលមានតម្លៃនឹងនិយាយម្តងទៀតនៅទីនេះ៖

*"ជនជាតិដើមភាគតិច និងប្រតិបត្តិការរ៉ែ*

*កន្លែងមានរ៉ែមួយចំនួនស្ថិតនៅក្នុងតំបន់ដែលជនជាតិដើមភាគតិចរស់នៅ។ ដូច្នេះ ប្រតិបត្តិការរ៉ែនៅតំបន់ទាំងនោះមិនត្រូវប៉ះពាល់ដល់សិទ្ធិសេរីភាព ប្រពៃណី ទំនៀមទម្លាប់ ជំនឿ និងសាសនារបស់ជនជាតិដើមភាគតិចក្នុងតំបន់នោះទេ ។ ការបំពានលើកន្លែងគោរពបូជារបស់ជនជាតិដើមភាគតិចត្រូវបានហាមឃាត់។ ក្រុមហ៊ុនជីករ៉ែត្រូវយល់អំពីប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ ជំនឿ និងទំនាក់ទំនងរបស់ក្រុមជនជាតិដើមភាគតិចនីមួយៗនៅក្នុងតំបន់រុករករ៉ែរបស់ពួកគេ ដើម្បីជៀសវាងការរំលោភបំពានណាមួយ។*

***ផែនការសកម្មភាព៖***

*ការផ្តល់ការការពារដល់ជនជាតិដើមភាគតិចនៅក្នុងតំបន់អភិវឌ្ឍធនធានរ៉ែ ដោយរក្សាសិទ្ធិ សេរីភាព ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ ជំនឿ និងសាសនារបស់ជនជាតិដើមភាគតិច ស្របតាមគោលនយោបាយ និងច្បាប់របស់រដ្ឋ"។*

គោលនយោបាយនេះមិនមានព័ត៌មានលម្អិតអំពីវិសាលភាពនៃសិទ្ធិ និងប្រពៃណីរបស់ជនជាតិដើមភាគតិចដូចជាការផ្តល់អាទិភាពដល់វប្បធម៌របស់សហគមន៍លើដីព្រៃឈើទេ ហើយក៏មិនព្យាយាមស្វែងយល់ថាតើការការពារជនជាតិដើមភាគតិចគួរមានលក្ខណៈបែបណាដែរ។ ប៉ុន្តែយ៉ាងហោចណាស់គោលនយោបាយទទួលស្គាល់ថាសហគមន៍ជនជាតិដើមភាគតិចមានផលប្រយោជន៍ពិសេសដែលស្របច្បាប់។ មិនទាន់មានសកម្មភាពជាក់លាក់ណាមួយធ្វើឱ្យការអនុវត្តរបស់ឧស្សាហកម្មស៊ីគ្នាជាមួយនឹងការគិតគូរទាំងនោះទេ ជាពិសេសទាក់ទងនឹងការការពារព្រៃឈើ និងការគោរពសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច។

លើកលែងតែផ្នែកដែលបានដកស្រង់ខាងលើ គោលនយោបាយជាតិដែលធំជាងនេះ ជាធម្មតាមិនយកចិត្តទុកដាក់លើកង្វល់ទាក់ទងនឹងសិទ្ធិរបស់ជនជាតិដើមភាគតិចនៅកម្ពុជាទេ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការសិក្សា និងអត្ថបទព័ត៌មានមានប្រសិទ្ធភាពក្នុងការបង្ហាញពីរបៀបដែលភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មជីករ៉ែមិនអើពើដោយចេតនា និង ជាប្រព័ន្ធចំពោះសិទ្ធិពិសេសដែលមានសម្រាប់ជនជាតិដើមភាគតិច។

មន្ត្រីកម្ពុជាចាំបាច់ត្រូវគិតគូរឱ្យបានត្រឹមត្រូវចំពោះបញ្ហាជនជាតិដើមភាគតិច មិនត្រឹមតែជួយកម្ពុជាក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាឱ្យបានថាអ្នកវិនិយោគមិនធ្វើខុសបន្ថែមទៀតចំពោះការគាបសង្កត់ជនជាតិដើមភាគតិចក្នុងប្រទេស។

[៣] របាយការណ៍ឆ្នាំ ២០១០ ពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)៖ សូមចូលទៅកាន់តំណ: https://openjicareport.jica.go.jp/pdf/12006003_01.pdf




*ស្ត្រីជនជាតិដើមភាគតិចចាប៉ាយដងទឹកប្រើប្រាស់សំរាប់គ្រួសារ*

## ដំណើរការពិភាក្សាប្រកបដោយតម្លាភាព

ការពិគ្រោះយោបល់ជាសាធារណៈត្រឹមត្រូវនៅតែមានបញ្ហាជាប្រព័ន្ធជាពិសេសនៅក្នុងឧស្សាហកម្មនិស្សារណកម្ម។ ច្បាប់នេះមានលក្ខខណ្ឌតម្រូវច្បាស់លាស់ទាក់ទងនឹងនីតិវិធីវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គម (ESIA)។ ប៉ុន្តែ នៅក្នុងការអនុវត្ត ការដាក់ឱ្យដំណើរការនីតិវិធីវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានគេមើលឃើញថា គ្រាន់តែជាការធ្វើតាមលំដាប់លំដោយច្បាប់ដោយក្រុមហ៊ុនឧស្សាហកម្ម ហើយជារឿយៗត្រូវបានអនុម័តដោយមិនចាំបាច់ពិនិត្យមើលឡើងវិញ ឬកែតម្រូវអ្វីនោះទេ។ ពុំមានឧទាហរណ៍ គម្រូណាមួយដែលបានបង្ហាញជាសាធារណៈ ពីលទ្ធផលសិក្សានៅក្នុងនីតិវិធីវាយតម្លៃហេតុផលប៉ះពាល់ បរិស្ថាន និងសង្គមធ្វើឱ្យមានការបដិសេធគម្រោង ឬការផ្លាស់ប្តូរក្នុងការរៀបចំគម្រោងនោះទេ។“ចន្លោះប្រហោង” នៅក្នុងក្របខណ្ឌច្បាប់ជុំវិញការពិគ្រោះយោបល់ជាសាធារណៈត្រូវបានវែកញែកយ៉ាងលម្អិតនៅក្នុងរបាយការណ៍ របស់អង្គការតម្លាភាពអន្តរជាតិ ពីឆ្នាំ ២០២១[៥] ។ បន្ទាប់ពីការវិភាគដ៏វែងឆ្ងាយ អ្នកនិពន្ធរបាយការណ៍បានសន្និដ្ឋានថា បញ្ហាដែលទាក់ទងនឹងការចូលរួម ជាសាធារណៈនិងការវាយតម្លៃហេតុផលប៉ះពាល់ បរិស្ថាន និងសង្គម កើតឡើងពីការអសមត្ថភាព របស់រដ្ឋាភិបាល ក្នុងការយល់អំពីក្របខណ្ឌច្បាប់របស់ខ្លួន និងអនុវត្តវាឱ្យបានត្រឹមត្រូវ។

វាក៏មានភាពមិនច្បាស់លាស់ផងដែរ នៅក្នុងការវែកញែករបស់របាយការណ៍អំពីប្រសិទ្ធភាពនៃវេទិកាអភិបាលកិច្ចឧស្សាហកម្មនិស្សារណកម្ម ដែលជាវេទិកាសន្ទនាជាមួយសង្គមស៊ីវិល ថាតើវេទិកានេះអាចចូលរួមប្រកបដោយអត្ថន័យក្នុងន័យស្ថាបនា ឬ

យ៉ាងណា។ ជាពិសេសថាតើវេទិកានេះអាចមានការពិភាក្សាពិតប្រាកដជាមួយក្រសួងរ៉ែ និងថាមពល ទាក់ទងនឹងបញ្ហាជាមួយនឹងការពិគ្រោះយោបល់ជាសាធារណៈដែរឬទេ។

ជាសំខាន់ អ្នកនិពន្ធបានកប់ផ្នែកមួយនៃរបាយការណ៍នៅទំព័រទី២៤ ដែលបង្ហាញពីចន្លោះប្រហោងដ៏ធ្ងន់ធ្ងរនៅក្នុងក្របខ័ណ្ឌច្បាប់ ដែលជាការសំដៅទៅលើកង្វះលក្ខខណ្ឌតម្រូវការសម្រាប់ធ្វើការពិគ្រោះយោបល់បន្តបន្ទាប់ជាមួយសហគមន៍ក្នុងមូលដ្ឋាន។


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍

ស្តីពី

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង

INITIAL ENVIRONMENTAL & SOCIAL IMPACT ASSESSMENT (IESIA) REPORT

លើគំរោងសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែមាស នៅតំបន់ភ្នំទ្រមិ្ញកខ្មៅ ឃុំក្បាលដំរី ស្រុកសំបូរ និងឃុំសំបុក ស្រុកចិត្របុរី ខេត្តក្រចេះ

នៅលើផ្ទៃដីសរុប ២.០៥០ហិកតា

ក្រុមហ៊ុន ស៊ីង យន្ត គ័ង យិក ខូ អិលធីឌី

XING YUAN KANNG YEAK Co., Ltd.

អាស័យដ្ឋានក្រុមហ៊ុន: អាគារលេខ១ កាច់ជ្រុង ផ្លូវលេខ ២១១ និង ផ្លូវលេខ ១៣៨ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: ០៩៧-៦៤២ ៧០៧៨/០១១-២៣២ ៩១១

អ៊ីមែល: twc007@msn.com

ខែ ឧសភា ឆ្នាំ ២០១១

*ទំព័រគម្របនៃ EISA ឆ្នាំ 2011 ដែលធ្វើឡើងដោយទីតាំងអណ្តូងរ៉ែ Xing Yuan Kang Yeak ក្នុងខេត្តក្រចេះ។ ទោះបីជាត្រូវបានធ្វើឡើង 10 ឆ្នាំមុនពេលចាប់ផ្តើមប្រតិបត្តិការ វាគឺជាឧទាហរណ៍ដ៏កម្រនៃ EISA ដែលមានជាសាធារណៈ*

[៤] គោលនយោបាយជាតិស្តីពីធនធានរ៉ែ ២០១៨-២០២៨៖ សូមចូលទៅកាន់តំណ: http://www.mme.gov.kh/documents/255/ MME_National_Mineral_Policy-EN.pdf

## សិប្បកម្មរ៉ែខ្នាតតូច

មាត្រា១១ នៃច្បាប់បង្កើត ក្របខណ្ឌច្បាប់មួយសម្រាប់អាជ្ញាប័ណ្ណសិប្បកម្មរ៉ែ(ជីករ៉ែដោយដៃ)។ វាដាក់កំហិតលើបុគ្គលដែលមានប្រតិបត្តិការសិប្បកម្មរ៉ែឱ្យមាន "ជំនួយពីគ្រួសារដែលមានមនុស្សមិនលើសពី ៧ នាក់" និងកំណត់ទំហំនៃកន្លែងចម្រាញ់យករ៉ែមិនឱ្យលើសពី ១ ហិកតា និងជម្រៅអតិបរមា ៥ ម៉ែត្រ។

ក្នុងឆ្នាំ ២០០៤ អង្គការអុកស្វាម (Oxfam) បានចេញផ្សាយរបាយការណ៍[៦] មួយ ដែលផ្តោតលើប្រតិបត្តិករជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូច និងបទពិសោធន៍របស់ពួកគេទាក់ទិននឹងការកើនឡើងនូវបទប្បញ្ញត្តិនានា ។ បុព្វកថារបស់របាយការណ៍នេះដែលត្រូវបាននិពន្ធដោយនាយកប្រតិបត្តិអង្គការអុកស្វាម នៅពេលនោះគឺ លោកឃីតស្លែក (Keith Slack) បានកត់សម្គាល់ថា "មិនថាជាទ្រង់ទ្រាយធំ ឬតូច ការជីកយករ៉ែត្រូវបានកំណត់និយមន័យថាជាសកម្មភាពដែលមិនប្រកបដោយនិរន្តភាព ។ នៅពេលដែលរ៉ែមាស ឬរ៉ែលោហៈផ្សេងទៀតត្រូវបានយកចេញពីក្នុងដី វាមិនអាចកកើតឡើងវិញបានទេ។ ដូច្នេះ ការជីកយករ៉ែមិនអាចជាប្រភពនៃ 'ការអភិវឌ្ឍប្រកបដោយនិរន្តរភាព' ក្នុង រយៈពេលវែងនោះទេ។ វាជាការពិតដែលថា នៅក្នុងប្រទេសក្រីក្រខ្លាំង ដូចជាប្រទេសកម្ពុជាមានជម្រើសក្នុងការបង្កើតប្រាក់ចំណូលផ្សេងទៀតតិចតួចសម្រាប់សហគមន៍ក្រីក្រ"។

របាយការណ៍នេះបានប៉ាន់ប្រមាណថា ប្រជាជនកម្ពុជាប្រមាណ ៥០០០នាក់ពឹងផ្អែកលើការជីកយករ៉ែដោយដៃជាធនធានចិញ្ចឹមជីវិតដ៏សំខាន់មួយ គិតត្រឹមឆ្នាំ ២០០៤។ របាយការណ៍នេះបានលើកឡើងពីសម្ពាធពីសាជីវកម្មដែលមិនស្របច្បាប់លើប្រតិបត្តិកាសិប្បកម្មរ៉ែខ្នាតតូច រួមទាំងការដាក់សម្ពាធលើអ្នកជីកយករ៉ែដោយដៃឱ្យបង់ "កម្រៃ" និង "ពន្ធ" ភ្លាមៗ បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណរុករកទាំងនៅភ្នំព្រឹក ក្នុងខេត្តបាត់ដំបង និងរំដេងក្នុងខេត្តព្រះវិហារ ជាករណីមួយដែលជាអកុសលនៅតែបន្តរហូតដល់សព្វថ្ងៃនេះ។

របាយការណ៍ឆ្នាំ ២០១២ ពីអង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (Development Partners in Action) និយាយពីករណីមួយចំនួនអំពីអ្នកជីករ៉ែក្នុងមូលដ្ឋានក្នុងខេត្តព្រះវិហារ ដែលទទួលបានការអនុញ្ញាតពីអ្នកពាក់ព័ន្ធថ្នាក់ខេត្តក្នុងការបន្តការរុករករ៉ែដោយដៃរបស់ពួកគេ ប៉ុន្តែស្ថានភាពបានផ្លាស់ប្តូរនៅពេលក្រុមហ៊ុនធំមួយបានចូលមកដល់។ សភាពការណ៍នេះបានប្រែប្រួល ហើយមានការដាក់ទោសទណ្ឌជាបន្តបន្ទាប់លើការជីករ៉ែដោយដៃពីសំណាក់កងកម្លាំងយោធាក្នុងមូលដ្ឋាន ដោយមានសមាជិកសហគមន៍ម្នាក់ក្នុងខេត្តព្រះវិហារត្រូវបានបញ្ជូនទៅពន្ធនាគារ។

ការលើកកម្ពស់ និងការការពាររបស់ការជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចដែលជាប្រភពដ៏សំខាន់នៃប្រាក់ចំណូលប្រកបដោយនិរន្តរភាពរយៈពេលវែងសម្រាប់ប្រជាជនកម្ពុជានៅតាមជនបទកំពុងប្រែក្លាយជាអាក្រក់ទៅ។ ទោះបីជាមានការលើកឡើងពីសារសំខាន់នៃការជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចនៅក្នុងឯកសារគោលនយោបាយជាតិមួយចំនួនក៏ដោយ ក៏និន្នាការនេះគឺច្បាស់ណាស់ថា៖ ការជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចកំពុងត្រូវបានលុបចោល ហើយ ការជីកយករ៉ែក្នុងទ្រង់ទ្រាយធំដោយប្រើសារធាតុគីមីកំពុងត្រូវបានរីកសាយភាយយ៉ាងខ្លាំង។

[៦] របាយការណ៍របស់អង្គការOxfam ចេញផ្សាយឆ្នាំ២០០៤៖ សូមចូលទៅកាន់តំណ: https://data.laos.opendevelopmentmekong.net/library_record/small-scale-gold-mining-in-cambodia-a-situation-assessmentv



រណ្ដៅជីករ៉ែនៅតេនគិរីដែលអ្នកស្រាវជ្រាវអាចមើលបាន

## ការផ្ដល់អាជ្ញាប័ណ្ណរ៉ែ

ច្បាប់នេះបាន បង្កើតរបបថ្មីមួយ នៃការផ្ដល់អាជ្ញាប័ណ្ណ ដោយផ្ដល់នូវអាជ្ញាប័ណ្ណ ចំនួនប្រាំមួយប្រភេទគឺ៖

* អាជ្ញាប័ណ្ណជីករ៉ែដោយដៃ៖ នេះអាចត្រូវបានចេញសម្រាប់តែ "ជនជាតិខ្មែរ" ប៉ុណ្ណោះដូចនេះ មិនរាប់បញ្ចូលជនជាតិមិនមែនខ្មែរ ដូចជាជនជាតិវៀតណាមជាដើម។

* អាជ្ញាប័ណ្ណរុករក៖ នេះសន្មតថារួមបញ្ចូលការរុករកមាស ប៉ុន្តែមិនមានបញ្ជីដែលបានផ្ដល់ឱ្យនៅក្នុងច្បាប់ទេ។

* អាជ្ញាប័ណ្ណជីករ៉ែជាលក្ខណៈឧស្សាហកម្ម៖ នេះត្រូវបានគេហៅថាជាទូទៅអាជ្ញាប័ណ្ណអាជីវកម្ម។ យ៉ាងណា ចន្លោះប្រហោងជាក់លាក់ត្រូវបានលាតត្រដាងនៅក្នុងក្របខ័ណ្ឌនេះ។

មាត្រា ១២ នៃច្បាប់ចែងថា "ការស្នើសុំអាជ្ញាប័ណ្ណរុករក ឬជីកយករ៉ែបង្ហាញអំពីគម្រោងទ្រង់ទ្រាយធំរបស់កិច្ចការជាតិពិសេស ... ត្រូវមានកិច្ចព្រមព្រៀងបន្ថែមស្ដីពីការវិនិយោគរ៉ែបញ្ចូលជាឧបសម្ព័ន្ធទៅនឹងអាជ្ញាប័ណ្ណនោះ"។

មិនមានគម្រូនៃកិច្ចព្រមព្រៀងបន្ថែមទាំងនេះត្រូវបានបង្ហាញជាសាធារណៈនោះទេ។

មាត្រា ១៧ បង្កើតសិទ្ធិនៃការកែប្រែ ឬការប្រគល់អាជ្ញាប័ណ្ណបែបនេះណាមួយ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើការផ្ទេរអាជ្ញាប័ណ្ណរបស់ពួកគេទៅឱ្យក្រុមហ៊ុន ឬបុគ្គលផ្សេងទៀតយ៉ាងងាយស្រួល ដោយមិនចាំបាច់គិតគូរលើហានិភ័យដែលការផ្ទេរទាំងនេះអាចបង្កឡើងនោះទេ។

មាត្រា ៣១ ចែងអំពី "របបពន្ធពិសេស... សម្រាប់អនុវត្តចំពោះផលទិន្នផល និងចំណូលដែលទទួលបានពីប្រភេទទាំង ៦ (ប្រាំមួយ)"។ នេះជាបញ្ហាមិនត្រឹមតែដោយសារតែរបបពន្ធពិសេសទាំងនេះមិនមានលក្ខណៈសាធារណៈ ឬតម្លាភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយសារតែអាជ្ញាប័ណ្ណរុករកគួរកំណត់កម្រិតផលរបរ ឬប្រាក់ចំណូលដែលមិនជាប់ពន្ធផងដែរ។

ផ្អែកលើចំណុចនៃការប្រមូលចំណូលរដ្ឋ របាយការណ៍របស់អង្គការអុកស្វាម ឆ្នាំ ២០០៤ សំដៅលើ "ការបាត់បង់ប្រាក់ចំណូលរបស់រដ្ឋ ដោយសារក្រុមហ៊ុនរកប្រាក់ចំណេញ ខណៈពេលដែលមិនមានអាជ្ញាប័ណ្ណអាជីវកម្មចាំបាច់ ដែលនឹងបង្កើតឱ្យមានការបង់ថ្លៃសួយសារអាករ និងពន្ធបាន"។

របាយការណ៍ឆ្នាំ ២០០៩ របស់អង្គការ Global Witness[៧] គឺជាធនធានដ៏ល្អមួយក្នុងការស្វែងយល់ពីភាពមិនតម្លាភាពជាប្រព័ន្ធ និងសំណព្វនិយមនៅក្នុងវិស័យជីកយករ៉ែ។ របាយការណ៍នេះបានបង្ហាញពីទំនាក់ទំនងយ៉ាងទូលំទូលាយរវាងមន្ត្រីជាន់ខ្ពស់របស់គណបក្សកាន់អំណាច និងមន្ត្រីយោធា និងរលកទីមួយនៃសម្បទានរុករកដែលត្រូវបានផ្តល់តទៅឱ្យ ប្រតិបត្តិករទ្រង់ទ្រាយធំដែលកំពុងរុករករ៉ែមាស។ របាយការណ៍នេះចង្អុលលើការចូលរួមរបស់លោក ចម បូរី ដែលជាបង/ប្អូនប្រុសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លោក ចម ប្រសិទ្ធ ក្នុងក្រុមហ៊ុនបណ្តាក់ទុនជីកយករ៉ែជាច្រើន ដែលក្រុមហ៊ុនទាំងនោះមិនធ្លាប់ធ្វើប្រតិបត្តិការជោគជ័យឡើយ ទោះបីជាមានប្រវត្តិកំណត់ត្រានេះក៏ដោយ ក៏កំណត់ត្រាបង្ហាញពីការបន្តចូលរួមរបស់លោក ចម បូរី ជាមួយក្រុមហ៊ុនបណ្តាក់ទុនជីករ៉ែផ្សេងទៀតនៅឆ្នាំបន្ទាប់ៗដែរ។ គ្មានមន្ត្រីពីគណបក្សកាន់អំណាចណាម្នាក់ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងរបាយការណ៍ថាជាអ្នកគាំទ្រពីក្រោយនៃប្រតិបត្តិការជីកយករ៉ែបានផ្តល់ការឆ្លើយតបណាមួយដែលបដិសេធនឹងការជាប់ពាក់ព័ន្ធនោះទេ។

គួរឱ្យសោកស្តាយ នីតិវិធី និងបទប្បញ្ញត្តិនានាទាក់ទងនឹងអាជ្ញាប័ណ្ណគ្រប់ប្រភេទទើបត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៦ ប្រហែល ១៥ ឆ្នាំបន្ទាប់ពីច្បាប់ឆ្នាំ ២០០១ ត្រូវបានអនុម័ត។ នេះអាចកើតឡើងជាការឆ្លើយតបទៅនឹងការរិះគន់ជាច្រើនដែលសំដៅទៅលើមន្ត្រីជាន់ខ្ពស់ផ្នែកនយោបាយ និងមន្ត្រីក្រសួងផ្សេងៗទាក់ទងនឹងស្ថានភាពទូទៅនៃវិស័យនេះ។ ក្នុងអំឡុងពេលនោះ សារព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់បានបញ្ជាំងអំពីលក្ខណៈគ្រោះថ្នាក់នៃឧស្សាហកម្មនេះ និងការគ្រប់គ្រងមិនត្រឹមត្រូវនៃសិទ្ធិមនុស្ស និងហានិភ័យបរិស្ថាន។

យ៉ាងណាក្តី បទប្បញ្ញត្តិនៃអនុក្រឹត្យនេះបានក្លាយជាប្រធានបទនៃការរិះគន់មួយចំនួនពីសង្គមស៊ីវិល រួមទាំងរបាយការណ៍របស់អង្គការតម្លាភាពអន្តរជាតិ (Transparency International) ពីឆ្នាំ ២០១៧[៨] ដែលទោះបីជាមានភាពវិជ្ជមានក្នុងការវាយតម្លៃលើការកាត់បន្ថយហានិភ័យមួយចំនួននៃអំពើពុករលួយតាមរយៈអនុក្រឹត្យលេខ ៧២ ក៏ដោយ ក៏នៅតែលើកឡើងពីហានិភ័យជាក់លាក់ចំនួន ១៤ ដែលមិនត្រូវបានដោះស្រាយឱ្យបានគ្រប់គ្រាន់។

[៧] របាយការណ៍ឆ្នាំ២០០៩របស់អង្គការGlobal Witness៖ សូមចូលទៅកាន់តំណ: https://data.laos.opendevelopmentmekong.net/library_record/small-scale-gold-mining-in-cambodia-a-situation-assessmentv

## គោលការណ៍ណែនាំអន្តរជាតិសម្រាប់ឧស្សាហកម្មរ៉ែ

គំនិតផ្តួចផ្តើមអំពីតម្លាភាពរបស់ឧស្សាហកម្មនិស្សារណកម្ម (EITI)

គំនិតផ្តួចផ្តើមអំពី តម្លាភាព របស់ឧស្សាហកម្មនិស្សារណកម្មត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០២ ក្នុងកិច្ចប្រជុំកំពូលពិភពលោកស្តីពីការអភិវឌ្ឍធនធានប្រកបដោយនិរន្តរភាព។ គំនិតផ្តួចផ្តើមនេះផ្តល់ និងធ្វើបច្ចុប្បន្នភាព "ស្តង់ដារ" នៃអភិបាលកិច្ចឆ្នាំ ២០២៣ ដែលកំណត់ "គោលការណ៍ និងលក្ខខណ្ឌតម្រូវការ" ទូលំទូលាយសម្រាប់សមាជិកនៃគំនិតផ្តួចផ្តើមនេះ។ គោលការណ៍ទាំងនេះណែនាំពីទំនាក់ទំនងរវាងភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងឧស្សាហកម្មនិស្សារណកម្ម និងបង្ហាញពីឧត្តមានុវត្តសម្រាប់វិស័យនេះ ដើម្បីធានាថាកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រត្រូវបានផ្តល់អាទិភាព ក្នុងគោលបំណងជៀសវាងមានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គម។ ទោះបីជាមានការរិះគន់ពីទាំងវិស័យឯកជន (ថាគំនិតផ្តួចផ្តើមនេះបានងាកចេញឆ្ងាយពីអាណត្តិដំបូងរបស់ខ្លួនក្នុងការលើកកម្ពស់តម្លាភាព) និងទាំងសង្គមស៊ីវិលក៏ដោយ (ថាសមាជិកកំពុងបំពានកាតព្វកិច្ចរបស់ពួកគេក្រោមគោលការណ៍ដោយមិនប្រឈមមុខនឹងសំណងតាមផ្លូវច្បាប់ណាមួយ) គោលការណ៍នេះមានតួនាទីជាគោលការណ៍ណែនាំដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងពេញលេញសម្រាប់វិស័យនេះ។

មិនដូចប្រទេសដែលមានចំណូលមធ្យមកម្រិតទាបដទៃទៀតទេ នៅពេលកំពុងសរសេរនេះ កម្ពុជាមិនទាន់ជាប្រទេសកំពុងអនុវត្តនៅឡើយទេ បើទោះបីជាមានសញ្ញាខ្លះថាកម្ពុជាមានបំណងចូលរួមក៏ដោយ។ ការមិនចូលជាសមាជិករបស់កម្ពុជាអាចទាក់ទងនឹងបញ្ហាមួយចំនួន។ សមាជិកត្រូវបានតម្រូវឱ្យអនុវត្តក្រុមពហុភាគីពាក់ព័ន្ធជាតិដែលរួមមានតំណាងរដ្ឋាភិបាល ឧស្សាហកម្ម និងសង្គមស៊ីវិល។ ការវិវត្តន៍របស់ សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT) នាពេលថ្មីៗនេះអាចនឹងធ្វើឱ្យប្រទេសកម្ពុជាមានលក្ខខណៈមិនគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវ។ សមាជិកក៏ត្រូវបានតម្រូវឱ្យមានគោលនយោបាយ "ទិន្នន័យបើកចំហ" ហើយដោយសារ របាយការណ៍ជាច្រើនបានចង្អុលបង្ហាញថា តម្លាភាពក្នុងការផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងដែលមានអត្ថប្រយោជន៍គឺជាផ្នែកមួយដ៏លំបាកសម្រាប់ប្រទេសកម្ពុជាក្នុងការកែលម្អ។

### *គោលការណ៍ណែនាំរបស់ប្រទេសចិន*

សភាពាណិជ្ជកម្មចិននៃអ្នកនាំចូល និងនាំចេញលោហធាតុ រ៉ែ និងសារធាតុគីមី គឺជាសមាគមឧស្សាហកម្មដែលដឹកនាំព្យាយាមរៀបចំការត្រួតពិនិត្យភាពស្របច្បាប់លើឧត្តមានុវត្តសម្រាប់សាជីវកម្មដែលពាក់ព័ន្ធនឹង "តំបន់ហានិភ័យខ្ពស់" នៅទូទាំងពិភពលោក។ គោលការណ៍ណែនាំភាគច្រើនឆ្លុះបញ្ចាំងពីគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ធុរកិច្ច និងសិទ្ធិមនុស្ស ហើយប្រើប្រាស់ក្របខណ្ឌនៃការត្រួតពិនិត្យលើភាពស្របច្បាប់ ៥ ជំហានរបស់

[៨] របាយការណ៍របស់អង្គការTransparency International ពីឆ្នាំ២០១៧៖ សូមចូលទៅកាន់តំណ: https://ticambodia.org/library/wpcontent/files_mf/1507521680MiningReporttSmallsize100917.pdf

OECD[៩] ហើយដូចទៅនឹងគំនិតផ្តួចផ្តើមអំពីតម្លាភាពរបស់ឧស្សាហកម្មនិស្សារណកម្មផងដែរ ដែលបង្កើតទម្រង់ "ស្តង់ដារ"មួយ។ ទោះបីមានគោលការណ៍ណែនាំត្រូវបានបង្កើតឡើងដោយទីភ្នាក់ងារចិនដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលក៏ដោយ ក៏គោលការណ៍ណែនាំគួរតែមានទម្ងន់លើក្រុមហ៊ុនចិនដែលកំពុងប្រតិបត្តិការនៅបរទេស។ ដូចគំនិតផ្តួចផ្តើមអំពីតម្លាភាពរបស់ឧស្សាហកម្មនិស្សារណកម្មដែរ ការរិះគន់ចម្បងរបស់វាគឺថាមិនមានយន្តការដោះស្រាយបញ្ហាទុក្ខកង្វល់ ឬសំណងតាមផ្លូវច្បាប់ដែលមាននៅក្នុងគោលការណ៍ណែនាំទេ ប៉ុន្តែមិនដូចគំនិតផ្តួចផ្តើមអំពីតម្លាភាពរបស់ឧស្សាហកម្មនិស្សារណកម្មទេ វាមិនមែនជាគំនិតផ្តួចផ្តើមដែលផ្អែកលើមូលដ្ឋានសមាជិកភាពដោយសមាជិកត្រូវបណ្តេញចេញដោយសារការមិនគោរពតាមនោះទេ។ ត្រូវបានគេនិយាយថា គោលការណ៍ណែនាំរបស់ចិនបានកំណត់វិធានការសំខាន់ៗចំនួនប្រាំពីរសម្រាប់កាត់បន្ថយ "បញ្ហាសុវត្ថិភាព និងបញ្ហាពាក់ព័ន្ធនានា" សម្រាប់ក្រុមហ៊ុន "រុករក/ចម្រាញ់រ៉ែ"។ វិធានការគួរកត់សម្គាល់ទាំងនេះរួមមានៈ "នៅក្នុងតំបន់ដែលរ៉ែត្រូវបានបង់ពន្ធ ឬជំរិតយកប្រាក់ ដោយខុសច្បាប់ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីធានាថា អន្តរការីរុករក/ចម្រាញ់រ៉ែ និងក្រុមហ៊ុនដឹកជញ្ជូនទំនិញបន្ត(-consolidator) បង្ហាញពីការបម្លែងរ៉ែទៅជាផលិតផលសម្រេច (downstream) ឬបង្ហាញជាសាធារណៈនូវចំនួនទឹកប្រាក់ (sic) ដែលទូទាត់ឱ្យកងកម្លាំងសន្តិសុខសាធារណៈ ឬឯកជនសម្រាប់ការផ្តល់សន្តិសុខ"។ នេះជារឿងគួរឱ្យភ្ញាក់ផ្អើល ដែលក្រុមហ៊ុនរុករក/ចម្រាញ់រ៉ែ ជាទូទៅដឹងពីការយកពន្ធ ឬការជំរិតយកប្រាក់ខុសច្បាប់ពីដៃគូខ្សែសង្វាក់ផ្គត់ផ្គង់ការបម្លែងរ៉ែទៅជាផលិតផលសម្រេច (downstream supply chain) របស់ពួកគេ ពេលការអំពាវនាវឱ្យបញ្ចេញព័ត៌មានជាសាធារណៈគឺជាការកោតសរសើរមួយ។

វិធានការវិជ្ជមានផ្សេងទៀតក្នុងការកាត់បន្ថយហានិភ័យរួមមានៈ "គាំទ្រការបង្កើតវេទិកាសហគមន៍ដើម្បីចែករំលែក និងបញ្ជ្រាបព័ត៌មាន។ ផ្នែកមួយដែលទាក់ទងនឹងវិធានការកាត់បន្ថយហានិភ័យពាក់ព័ន្ធទៅនឹងការការពារការជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចស្នើណែនាំវិធានការមួយគឺ៖ "កាត់បន្ថយហានិភ័យនៃការប៉ះពាល់ដល់អ្នកជីករ៉ែដោយដៃទៅនឹងការអនុវត្តបំពានតាមរយៈការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលម្ចាស់ប្រទេស សម្រាប់បង្កើនជំនាញវិជ្ជាជីវៈ និងបង្កើតជាផ្លូវការជាលំដាប់នូវវិស័យរុករករ៉ែដោយដៃ តាមរយៈការបង្កើតសហករណ៍ សមាគម ឬរចនាសម្ព័ន្ធសមាជិកភាពផ្សេងទៀត"។ ការគាំទ្រប្រភេទនេះសម្រាប់ការជីកយករ៉ែដោយដៃគឺជាការរួមចំណែកដ៏ល្អមួយចំពោះការយល់ដឹងជាសកលអំពីឧត្តមានុវត្តយ៉ាងណាក្តីគោលការណ៍ណែនាំទាំងនេះកាត់បន្ថយក្នុងវិសាលភាពធំនូវការចំណាំថាតួអង្គរដ្ឋាភិបាលអាចពាក់ព័ន្ធនឹងការអនុវត្តមិនល្អទាក់ទងនឹងវិស័យនេះ តាមរយៈគោលនយោបាយ ឬការអនុវត្ត។ មានន័យថា គោលការណ៍ណែនាំទាំងនេះផ្តល់សារដ៏រឹងមាំជុំវិញការអនុវត្តលើការត្រួតពិនិត្យភាពស្របច្បាប់យ៉ាងត្រឹមត្រូវ នៅទូទាំងសង្វាក់ផ្គត់ផ្គង់យ៉ាងទូលំទូលាយ ។

[៩] ការណែនាំអំពីភាពឧស្សាហ៍ព្យាយាមរបស់ OECD សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលទទួលខុសត្រូវនៃរ៉ែពីតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ និងហានិភ័យខ្ពស់៖ សូមចូលទៅកាន់តំណ: http://dx.doi.org/10.1787/9789264111110-en

# ករណីសិក្សាទី១

## ទីតាំង: ភូមិពាក និងភូមិផ្លាង ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី

## ក្រុមហ៊ុនជីកយករ៉ែ៖ អង្គរហ្គោល ខប មេសកូហ្គោល

## ( Angkor Gold Corp, Mesco Gold)

## សង្ខេបមតិត្រលប់ពីអ្នកភូមិពាក និងភូមិផ្លាង

១. អ្នកភូមិព្រួយបារម្ភបំផុតអំពីការបន្តបាត់បង់ធនធានធម្មជាតិ និងដីរបស់ពួកគាត់ ដែលជាកត្តាចាំបាច់ក្នុងការទ្រទ្រង់ ការចិញ្ចឹមជីវិតបែបប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច។ នេះបានបន្ថែមពីក្តីកង្វល់ជុំវិញការបន្តកាប់បំផ្លាញព្រៃឈើ និងដីស្រែចម្ការដែលមានសារសំខាន់ដល់ការរស់រានរបស់ពួកគេ។

២. ប្រជាពលរដ្ឋចង់បានការគ្រប់គ្រងកាកសំណល់ពុលរបស់ក្រុមហ៊ុនមេសកូ (Mesco) និងក្រុមហ៊ុនអង្គរហ្គោល (Angkor Gold) ប្រសើរឡើង និងបង្កើនការគាំទ្រសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធរបស់សហគមន៍ រួមទាំងការបញ្ចប់ផ្លូវធ្វើដំណើរ និងការជួសជុលប្រព័ន្ធទឹករបស់សហគមន៍ដែលបានស្នើឡើងផងដែរ។

៣. ពួកគេក៏ចង់ឱ្យក្រុមហ៊ុនបង្កើតបរិយាកាសការងារដែលមានសុវត្ថិភាព និងយុត្តិធម៌ជាងនេះនៅការដ្ឋានអណ្តូងរ៉ែ ស្របតាមស្តង់ដារសុវត្ថិភាពការងារ និងសិទ្ធិការងារ រួមទាំងការផ្តល់ឱ្យកម្មករអណ្តូងរ៉ែនូវសិទ្ធិទទួលបានសេវាវេជ្ជសាស្ត្រ។

៤. សរុបមក ពួកគេបានជឿថា ការវិនិយោគលើការជីកយករ៉ែនេះ មិនបានមកដើម្បីវិនិយោគលើនាពេលអនាគតរបស់ពួកគេទេ ហើយក៏មិនបានបង្កើតតម្លៃពិតប្រាកដ និងយូរអង្វែងសម្រាប់សហគមន៍ដែរ។



ផ្ទះកម្មករក្នុងការដ្ឋានជីករ៉ែរបស់ក្រុមហ៊ុន

## ប្រវត្តិក្រុមហ៊ុន និងការដ្ឋានអណ្តូងរ៉ែ

ក្រុមហ៊ុនអង្គរហ្គោល ខប (ខេមបូឌារ) Angkor Gold Corp (Cambodia) Ltd. ពីពេលនេះហៅថា("ក្រុមហ៊ុនអង្គរហ្គោល Angkor Gold") គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់អង្គររីសូស ខប (Angkor Resources Corp.) ដែលជាក្រុមហ៊ុនចុះបញ្ជីជាសាធារណៈ នៅប្រទេសកាណាដា។ ក្រុមហ៊ុនអង្គរហ្គោល (Angkor Gold) ត្រូវបានផ្តល់អាជ្ញាប័ណ្ណរុករករ៉ែលើផ្ទៃដីជាង ១៥០.០០០ ហិកតានៅក្នុងស្រុកអូយ៉ាដាវ ខេត្តរតនគិរី ក្នុងឆ្នាំ ២០០៨។ បន្ទាប់ពីបានបញ្ជាក់នូវលទ្ធភាពអាចផ្តល់ផលចំណេញនៃអណ្តូងរ៉ែមាសនៅជិតភូមិពាក ក្នុងឆ្នាំ ២០១៥ ក្រុមហ៊ុនអង្គរហ្គោល (Angkor Gold) បានលក់ចំណែកដីទំហំ ១,២០០ ហិកតាពីអាជ្ញាប័ណ្ណរបស់ខ្លួនក្នុងតម្លៃ ១.៨ លានដុល្លារទៅឱ្យក្រុមហ៊ុនមេសស្កូហ្គោល (ខេមបូឌារ) (Mesco Gold (Cambodia) Ltd.) ចាប់ពីពេលនេះតទៅហៅថា("ក្រុមហ៊ុនមេសស្កូ Mesco")។ គេហទំព័ររបស់ក្រុមហ៊ុនអង្គហ្គោល រៀបរាប់លម្អិតអំពី "កិច្ចព្រមព្រៀងការរំលាយលោហធាតុសុទ្ធ (net smelter agreement) " ជាមួយក្រុមហ៊ុនមេសស្កូ ដោយក្រុមហ៊ុនអង្គរហ្គោល មានសិទ្ធិរហូតដល់ ៧,៥% (អត្រាដែលបច្ចុប្បន្នជាធរមាន) នៃប្រាក់ចំណេញទាំងអស់ដែលទាក់ទងនឹងការដ្ឋានជីកយករ៉ែ។ក្រុមហ៊ុនមេសស្កូ គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់ក្រុមហ៊ុនមីតអេស អ៊ិនធ័ហ្គ្រេត ស្ទីល អិលធីឌី (Mideast Integrated Steels Ltd.) ដែលត្រូវបានចុះបញ្ជីនៅក្នុងប្រទេសឥណ្ឌា។ ថ្មីៗនេះ ក្រុមហ៊ុនមីតអេស អ៊ិនធ័ហ្គ្រេត ស្ទីល ប្រឈមនឹងការព្យួរការជួញដូរ[១០] ដោយសារតែការមិនអនុលោមតាមបទប្បញ្ញត្តិស្តីពីមូលបត្រនៅក្នុងប្រទេសឥណ្ឌា១។ ក្រុមហ៊ុននេះក៏កំពុងប្រឈមមុខនឹងការត្រួតពិនិត្យផងដែរ ទាក់ទងនឹងការចោទប្រកាន់ពីការចាប់យកដី[១១] សម្រាប់ការសាងសង់រោងចក្រដែក២នៅក្នុងរដ្ឋអូឌីសា (Odissa) នៃប្រទេសឥណ្ឌា។

ការដ្ឋានអណ្តូងរ៉ែមានរណ្តៅមាសចំនួន ៣ ដែលរណ្តៅនីមួយៗមានជម្រៅប្រហែល ៣០០ ម៉ែត្រ។ រណ្តៅមួយផ្សេងទៀតលែងដំណើរការទៀតហើយ។ រណ្តៅនីមួយៗត្រូវបានបំពាក់ដោយភ្លើង និងជណ្តើរយោងខ្សែកាបដែលប្រើដើម្បីចូលទៅកាន់ការដ្ឋានបំផុះ ហើយកម្មករបន្លឺសម្លេងពីចម្ងាយទៅកាន់ប្រតិបត្តិករជណ្តើរយោងខ្សែកាបដោយការចុចកណ្តឹង។ មុនពេលការរាតត្បាតនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ ២០២០ ក្រុមហ៊ុនចាត់ឱ្យបុគ្គលិកឱ្យធ្វើការបីវេនក្នុងមួយថ្ងៃ ដោយឱ្យធ្វើការពេញមួយថ្ងៃ។ ប៉ុន្តែប្រតិបត្តិការឥឡូវនេះត្រូវបានកាត់បន្ថយមកត្រឹមពីរវេនប៉ុណ្ណោះ។ បច្ចុប្បន្នគម្រោងនេះបានផ្តល់ការងារដល់កម្មករជនជាតិដើមខ្មែរប្រមាណ ២០ នាក់ឱ្យធ្វើការក្នុងរណ្តៅ និងជនជាតិឥណ្ឌា ៥ នាក់ ដែលធ្វើការក្នុងតួនាទីជាន់ខ្ពស់។

វាត្រូវបានគេរាយការណ៍[១២] នៅក្នុងប្រព័ន្ធផ្សព្វផ្សាយថាក្រុមហ៊ុនអង្គរហ្គោល ទទួលបានអាជ្ញាប័ណ្ណរុករកផ្សេងទៀតនៅជុំវិញប្រទេសកម្ពុជា៣ ដែលធ្វើឱ្យវាក្លាយជាករណីសិក្សាដ៏ល្អមួយសម្រាប់ការដាក់ក្រោមការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ននៃប្រតិបត្តិការរបស់ក្រុមហ៊ុនជីកយករ៉ែនានានៅក្នុងប្រទេស។

[១០] សូមចូលទៅកាន់តំណ: https://www.angelone.in/announcements/market/suspension-of-trading-in-securities-of-6-companies-2
[១១] សូមចូលទៅកាន់តំណ: https://www.orissapost.com/landless-former-mesco-workers-suffer-in-silence/
[១២] សូមចូលទៅកាន់តំណ: https://www.phnompenhpost.com/business/canada-firms-exploring-andong-bor-copper-gold-licence







## តំបន់ធ្វើអាជីវកម្មរ៉ែមាសរបស់ក្រុមហ៊ុន មេសក្លូហ្គោល ខេត្តរតនគិរី ប្រទេសកម្ពុជា

**សញ្ញាសំគាល់**

- តំបន់ធ្វើអាជីវកម្មរ៉ែមាសមេសក្លូហ្គោល
- ភូមិស្ថិតនៅក្បែរ
- ភូមិដែលបានសំភាសន៍
- ផ្លូវ
- អូរ
- សម្បទានរ៉ែក្រុមហ៊ុនមេសក្លូហ្គោល
- តំបន់ធ្វើអាជីវកម្មក្រុមហ៊ុមេសក្លូហ្គោល

មាត្រដ្ឋាន: 1:150,000

ប្រព័ន្ធកូអរដោណេ: W.G.S 1984

ប្រភពទិន្នន័យ:
Opendevelopment.net, Esri SatelliteImagery, Google Earth, Handhelp GPS

# ប្រវត្តិភូមិ

ភូមិពាកមានទីតាំងប្រមាណបួនគីឡូម៉ែត្រពីការដ្ឋានអណ្តូងរ៉ែរបស់ក្រុមហ៊ុនអង្គរហ្គោល ។ ភូមិនេះមានប្រជាពលរដ្ឋប្រមាណ ២២០គ្រួសារ ដែលភាគច្រើនជាជនជាតិដើមភាគតិចចារ៉ាយ។ ចាប់តាំងពីឆ្នាំ ២០១៣ មក ជនជាតិដើមខ្មែរប្រហែល ៤០ គ្រួសារបានចំណាកស្រុកមកភូមិនេះ និងទិញដីស្រែចំការពីសហគមន៍ក្នុងមូលដ្ឋាន។ អ្នកភូមិនិយាយថា ពួកគេរកប្រាក់បានជាចម្បងពីការដាំដំឡូងមី ស្វាយចន្ទី និងដំណាំផ្សេងទៀត ដោយរកចំណូលជាមធ្យមចន្លោះពី ២០០ ទៅ ៥០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ពួកគេក៏បានបន្ថែមប្រាក់ចំណូលរបស់ពួកគេជាមួយនឹង ការលក់ផលិតផល អនុផលព្រៃឈើ (NTFP) ទោះជាយ៉ាងណាក៏ដោយ អ្នកភូមិរាយការណ៍ថាប្រាក់ចំណូលពីការលក់អនុផលព្រៃឈើដែលមិនមែនជាឈើបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំកន្លងមកដោយសារការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់នេះ។ អ្នកភូមិមួយចំនួនបានរាយការណ៍ថា ពួកគេធ្លាប់ធ្វើការជីករ៉ែមាសក្នុងទ្រង់ទ្រាយតូច ដោយប្រើដៃពីមុនមក ជាប្រតិបត្តិការដែលកម្មករជីករណ្តៅជម្រៅ ៨ ម៉ែត្រ ត្រងប្រោះមាស ហើយលក់នៅទីផ្សារក្នុងមូលដ្ឋាន ។



*ផ្ទះសមាជិកសហគមន៍ក្នុងភូមិពាក*

*"នឹងមិនទទួលបានសូម្បីតែប៊ីចេងអាជីណូម៉ូតូ មួយកញ្ចប់ នៅពេលក្រោយប្រសិនបើអ្នកមិនយល់ស្របនឹងចំនួននេះ» ។ សមាជិកសហគមន៍ដកស្រង់ពីមន្ត្រីមូលដ្ឋាន*

## ការពិគ្រោះយោបល់ជាសាធារណៈ និងការបាត់បង់ដីធ្លី

អ្នកភូមិជាច្រើននាក់មកពីភូមិពាកបាននិយាយថា ពួកគេមានបញ្ហាយ៉ាងធំចាប់តាំងពីគម្រោងជីករ៉ែត្រូវបានបើកភ្លើងបៃតងមក។ ពួកគេបានបង្ហាញពីកង្វះនៃដំណើរការពិគ្រោះយោបល់ជាសាធារណៈពេញលេញមួយ (មុនពេលចាប់ផ្តើមប្រតិបត្តិការជីកយករ៉ែ និងការលក់ដីដោយបង្ខំដើម្បីបើកផ្លូវទៅកាន់អណ្តូងរ៉ែ ដែលបានបង្កឱ្យមានការតវ៉ាជាច្រើននៅជុំវិញពេលដែលការរុករកបានចាប់ផ្តើម។

ទាក់ទិននឹងកង្វះនៃដំណើរការពិគ្រោះយោបល់ជាសាធារណៈ អ្នកផ្តល់បទសម្ភាសបាននិយាយថា មិនមានកិច្ចប្រឹងប្រែងរៀបចំដំណើរការពិគ្រោះយោបល់ពេញលេញពីសំណាក់រដ្ឋាភិបាល ឬក្រុមហ៊ុននោះទេ។ អ្នកភូមិជាច្រើនបាននិយាយថា ពួកគេត្រូវបានបំបាំងពីទីតាំងអណ្តូងរ៉ែ និងប្រតិបត្តិការដែលអាចប៉ះពាល់ដល់ពួកគេ។

ផ្ទុយទៅវិញ ក្រុមហ៊ុនពឹងផ្អែកលើអាជ្ញាធរមូលដ្ឋានឱ្យផ្តល់ដំណឹងដល់ម្ចាស់ដីដែលនឹងទទួលរងផលប៉ះពាល់ពីប្រតិបត្តិការជីកយករ៉ែ។ ប៉ុន្តែអន្តរកម្មទាំងនេះជារឿយៗពាក់ព័ន្ធនឹងការគំរាមកំហែង ឬឧបាយកលបំភិតបំភ័យដើម្បីឱ្យអ្នកភូមិចាកចេញពីដីរបស់ពួកគេដោយទទួលបានកញ្ចប់សំណងតិចតួច។ អ្នកផ្តល់បទសម្ភាសម្នាក់បានរៀបរាប់ថាត្រូវបានឆ្មាំក្រុមហ៊ុនគំរាមកំហែងឱ្យបោះបង់ចោលដីស្រែចំនួន ២ ហិកតាក្នុងឆ្នាំ ២០០៩ រួមទាំងការប្រើឆ្មាំក្រុមហ៊ុនមានប្រដាប់អាវុធដើម្បីគំរាមកំហែងអ្នកភូមិនេះផងដែរ។ នាងត្រូវបានគេប្រាប់ឱ្យបោះបង់ដី ឬគេយកដីរបស់នាងដោយបង្ខំហើយមិនបានផ្តល់សំណងអ្វីឡើយ។

ស្រដៀងគ្នានេះដែរ អ្នកភូមិម្នាក់ទៀតបាននិយាយថា កម្មករក្រុមហ៊ុនអង្គរហ្គោល និងក្រុមហ៊ុនមេសស្កូ បានគំរាមគាត់ឱ្យផ្តល់ដីចំនួន ៤ ហិកតាដល់ក្រុមហ៊ុនក្នុងតម្លៃទាប ត្រឹម៤០០០ ដុល្លារអាមេរិក។ ប្រសិនបើគាត់បដិសេធ កម្មករនោះបាននិយាយថាគាត់ "លើកក្រោយនឹងមិនទទួលបានអ្វីសូម្បីតែប៊ីចេងអាជីណូម៉ូតូ (Ajinomoto) មួយកញ្ចប់ ប្រសិនបើអ្នកមិនយល់ព្រមចំពោះចំនួនទឹកប្រាក់នេះ"។ ពេលដែលគាត់ចាកចេញពីភូមិទៅឆ្ងាយ ប្រពន្ធរបស់គាត់បានយល់ព្រមលើសំណងនោះ ព្រោះគាត់ខ្លាចក្រុមហ៊ុនយកដីរបស់ពួកគាត់ដោយមិនផ្តល់ប្រាក់ដែលបានសន្យាដល់គ្រួសារគាត់។

យោងតាមអ្នកចូលរួមការពិភាក្សាជាក្រុម បុគ្គលិកក្រុមហ៊ុនតែងតែអះអាងថា សហគមន៍មិនត្រូវបានអនុញ្ញាតឱ្យជីកយករ៉ែក្រោមជម្រៅជាក់លាក់មួយនោះទេ គឺមានតែក្រុមហ៊ុនប៉ុណ្ណោះ ដូច្នេះហើយ នេះផ្តល់ជាហេតុផលសម្រាប់ការយកដី។

បន្ទាប់ពីដំណើរការពិគ្រោះយោបល់ទូលំទូលាយត្រូវបានព្រមព្រៀងគ្នាក្នុងឆ្នាំ ២០១៥ កិច្ចព្រមព្រៀងផ្សេងៗត្រូវបានជាប់គាំងរវាងសមាជិកសហគមន៍មួយចំនួន ។ នេះរួមបញ្ចូលកិច្ចសន្យាជាលាយលក្ខណ៍អក្សរពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៥ ដែលផ្តល់ការគាំទ្រ CSR តូចតាចមួយចំនួន ដូចជាអណ្តូងទឹក និងមណ្ឌលសុខភាព។ ទោះបី កិច្ចព្រមព្រៀងកិច្ចសន្យានេះមានឥទ្ធិពលបរិបូរណ៍សម្រាប់ភូមិទាំងមូលក៏ដោយ ក៏អ្នកភូមិមិនត្រូវបានផ្តល់ជម្រើសអ្វីក្រៅពីបង្កការតវ៉ាឡើយ។ នេះបណ្តាលឱ្យមន្ត្រីយោធាធ្វើការចុះល្បាតក្នុងភូមិដែល

[១៣] សូមចូលទៅកាន់គំណ: https://english.cambodiadaily.com/news/indian-mining-firm-prepares-dig-deep-ratanakkiri-117474/

ជាយុទ្ធសាស្ត្របំភិតបំភ័យមួយទៀតដែលរដ្ឋាភិបាលប្រើលើអ្នកភូមិក្នុងមូលដ្ឋានជុំវិញជម្លោះដីធ្លី។ បន្ទាប់ពីមាន ភាពតានតឹងទាំងនេះ ក្រុមហ៊ុនបានស្នើកិច្ចព្រមព្រៀងផ្តល់សំណងមួយទៀតជូនដល់ អ្នកភូមិនូវចំនួនទឹកប្រាក់ពី ៥០០ ដុល្លារទៅ ១៨,០០០ ដុល្លារអាមេរិកសម្រាប់ដីរបស់ពួកគេ តែអ្នកផ្តល់បទសម្ភាសបានរាយការណ៍ថារូបមន្តដែលប្រើសម្រាប់គណនាសំណងនេះមិនត្រូវបានបង្ហាញដល់សហគមន៍ឡើយ ហើយក៏មិនច្បាស់ថាអ្នកណានឹងមានសិទ្ធិនៅក្រោមកិច្ចព្រមព្រៀងនេះដែរ។ ជាមួយគ្នានេះ ក្រុមហ៊ុនមេសស្កូ បានបន្តកាប់ឆ្ការដីព្រៃជុំវិញភូមិ ដែលបង្កជម្លោះជាមួយម្ចាស់ដី។ ក្រុមហ៊ុនមេសស្កូ បានបញ្ឈប់សកម្មភាពទាំងនេះនៅពេលសកម្មភាពដោះស្រាយជម្លោះត្រូវបានធ្វើ ឡើង។ ក្រោយមក នៅឆ្នាំ ២០២១ អ្នកភូមិបាននិយាយថាក្រុមហ៊ុនមេសស្កូបានធ្វើ "ការខ្វះហួសហេតុ" លើផ្ទៃដី ៣៨ ហិកតា[១៣] ដោយរំលោភលើព្រំដែនដែលបានកំណត់ក្នុងកិច្ចសន្យាឆ្នាំ ២០១៥ ។ ការតវ៉ាបន្ថែមទៀតបានផ្ទុះឡើង ដោយនៅទីបំផុត ក្រុមហ៊ុនមេសស្កូ បានយល់ព្រមយកឧបករណ៍របស់ពួកគេចេញពីតំបន់ជម្លោះនោះ។ យោងតាមអ្នកផ្តល់បទសម្ភាសម្នាក់ តំណាងក្រុមហ៊ុនបានជូនដំណឹងដល់ប្រជាពលរដ្ឋចំនួនប្រាំមួយគ្រួសារនៅក្នុងខែមីនា ឆ្នាំ ២០២២ ថា ដីរបស់ពួកគេជាទីតាំងសម្រាប់សកម្មភាពរុករកបន្ថែមទៀត ប៉ុន្តែមិនមានគម្រោងសម្រាប់ការការចម្រាញ់នោះទេ។មានតែមួយគ្រួសារប៉ុណ្ណោះក្នុងចំណោមគ្រួសារទាំងអស់ បានបដិសេធសំណើនេះ។ ចាប់តាំងពីពេលនោះមក ក្រុមហ៊ុនបានធ្វើសំណើជាច្រើនបន្ថែមទៀតទៅកាន់អ្នកភូមិដើម្បី "ជីករណ្តៅ" នៅលើដីរបស់ពួកគេ ហើយយោងទៅតាមអ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា "ពួកគេអាចបញ្ឈប់ក្រុមហ៊ុនបាន"។ បន្ទាប់ពីស្ងប់ស្ងាត់ធ្វើប្រតិបត្តិការរយៈពេលបីឆ្នាំដោយសារការរាតត្បាតជំងឺកូវីដ-១៩ ប្រតិបត្តិការជីករ៉ែបានចាប់ផ្តើមឡើងវិញនៅខែឧសភា ឆ្នាំ២០២៣។នៅថ្ងៃទី៦ ឧសភា ក្រុមហ៊ុនមេសស្កូ បានបិទផ្លូវ ទៅកាន់ផ្លូវធំមួយ ដែលអ្នកភូមិធ្លាប់ធ្វើដំណើរទៅដល់ដីស្រែចម្ការរបស់ពួកគេដែលជាធនធានព្រៃឈើ និងប្រភពទឹកនៅក្បែរនោះ រួមទាំខ្សែទឹកអូរទ្រើរ (O'Trer) ។ នេះប៉ះពាល់យ៉ាងខ្លាំងដល់សមត្ថភាពរបស់អ្នកភូមិក្នុងការធ្វើស្រែចម្ការយកទឹកសម្រាប់ងូត ចូលព្រៃដើម្បីប្រមូលអនុផលព្រៃឈើដែលមិនមែនជាឈើ និងនេសាទត្រី ឬឱ្យសត្វរបស់ពួកគេស៊ីចំណី។ ចាប់តាំងពីការបិទផ្លូវមក អ្នកភូមិបានរាយការណ៍ថាមានការកើនឡើងនូវអសន្តិសុខស្បៀង និងការថយចុះនូវប្រាក់ចំណូល។ ក្រុមហ៊ុនបានយល់ព្រមឈូសឆាយ និងពង្រីកផ្លូវមួយទៀតសម្រាប់អ្នកភូមិ យោងតាមកិច្ចព្រមព្រៀងថ្មីៗនេះចាប់ពីខែកក្កដា ឆ្នាំ ២០២៣។ ខណៈដែលផ្លូវថ្មីនេះនឹងបែរជាប៉ះពាល់ដល់ការកាន់កាប់ដីរបស់គ្រួសារចំនួនបី អ្នកភូមិបាននិយាយថា ម្ចាស់ដីបានយល់ព្រមក្នុងការរៀបចំសំណងសម្រាប់ដីនេះ។ ប្រជាពលរដ្ឋនៅភូមិផ្លាងបាននិយាយថា ពួកគេបារម្ភថា ក្រុមហ៊ុននឹងព្យាយាមបណ្តេញពួកគេដោយបង្ខំឱ្យចេញពីដីប្រពៃណីរបស់ពួកគេ ហើយការបាត់បង់ដីនេះនឹងធ្វើឱ្យជីវភាពកាន់តែយ៉ាប់យ៉ឺន។ ក្រុមហ៊ុនបានផ្តល់ឱ្យអ្នកភូមិធ្វើការនៅការដ្ឋានជីកយករ៉ែក្នុងតម្លៃ ៣០០ ដុល្លារក្នុងមួយខែ ប៉ុន្តែអ្នកភូមិភាគច្រើនបានច្រានចោលសំណើនេះ ហើយនិយាយថាពួកគេចង់បន្តរស់នៅបែបប្រពៃណីរបស់ពួកគេដដែល។

## ផលប៉ះពាល់សង្គម និងបរិស្ថាន

ជាប្រពៃណី អ្នកភូមិពាកបាន ប្រើប្រាស់ប្រភពទឹកធម្មជាតិហៅថាជ្រោះសម្រាប់ផឹក និងសម្រាប់ងូត។ ប៉ុន្តែចាប់តាំងពី ប្រតិបត្តិការជីករ៉ែបានចាប់ផ្តើមមក អ្នកភូមិមានការស្ទាក់ស្ទើរក្នុងការប្រើប្រាស់ទឹកជុំវិញនោះ ដោយសារតែហានិភ័យនៃការបំពុល និងការស្រុតដី។ ផ្ទុយទៅវិញ ពួកគេទិញទឹកដែលបង្កើននូវការចំណាយប្រចាំខែរបស់គ្រួសារពួកគេ។ បច្ចុប្បន្នក្រុមហ៊ុន កំពុងសាងសង់រណ្តៅចាក់កាកសំណល់ ដែលមានចម្ងាយប្រហែល ២០០ម៉ែត្រ ពីខ្សែទឹកអូរត្រើរ ហើយអ្នកភូមិព្រួយបារម្ភថា ទឹកហូរចេញពី រណ្តៅនឹងធ្វើឱ្យខូចគុណភាពទឹកចេញ ពីទឹកអូរថែមទៀត។ អ្នកភូមិបាននិយាយថា ពួកគេចង់ឱ្យរណ្តៅកាកសំណល់នៅឆ្ងាយពីអូរ។

## បរិយាបន្នសង្គម សិទ្ធិការងារ និងសុខភាព និងសុវត្ថិភាពការងារ

អ្នកភូមិជាច្រើនបាននិយាយថា ពួកគេចង់ធ្វើការនៅលើដីស្រែចម្ការរបស់ពួកគេជាជាងធ្វើការឱ្យក្រុមហ៊ុន ដែលការងារខ្ពស់ផុតពីដីអាចរកប្រាក់បានពី ៥ដុល្លារអាមេរិក ទៅ ៨ ដុល្លារអាមេរិកក្នុងមួយថ្ងៃ។ ក្រៅពីការលើកឡើងពី "គ្រោះថ្នាក់ និងហានិភ័យ" ដែលអាចកើតមាននៅពេលធ្វើការងារនៅការដ្ឋានអណ្តូងរ៉ែ អ្នកភូមិមិនបានរៀបរាប់លម្អិតអំពីការស្ទាក់ស្ទើររបស់ពួកគេចំពោះប្រាក់ឈ្នួលប្រចាំថ្ងៃខ្ពស់ពី ១៧ ដុល្លារទៅ ២០ ដុល្លារនោះទេ។

អ្នកផ្តល់បទសម្ភាសបាននិយាយថា ការស្លាប់របស់កម្មករខ្មែរពីរនាក់បន្ទាប់ពីការដាច់ខ្សែកាបជណ្តើររយោងនៅឆ្នាំ ២០២០ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបថរបស់អ្នកភូមិចំពោះគម្រោងនេះ។ តាមការចុះផ្សាយរបាយការណ៍នេះ មានតែអ្នកភូមិពាក បីនាក់ប៉ុណ្ណោះដែលធ្វើការឱ្យក្រុមហ៊ុនជាជាងបូមទឹកនៅក្នុងរណ្តៅ។

កម្មករពីរនាក់នៅការដ្ឋានអណ្តូងរ៉ែបាននិយាយថា ពួកគេមិនមានកិច្ចសន្យាពេញម៉ោង និងមិនបានដឹងពីគោលនយោបាយការងាររបស់ក្រុមហ៊ុនមេសស្តូទេ ដែលនយោបាយការងារគួរតែស្របតាមច្បាប់ការងាររបស់កម្ពុជា ហើយ សូម្បីតែការស្នើសុំច្បាប់ឈប់សម្រាកដែលមានប្រាក់ឈ្នួលក៏នឹងនាំឱ្យមានការគំរាមកំហែង នៃការកាត់ ប្រាក់ឈ្នួលផងដែរ។ ពួកគេក៏បានបង្ហាញផងដែរអំពីកង្វះពិធីការសុវត្ថិភាពច្បាស់លាស់របស់ក្រុមហ៊ុនមេសស្តូ និងក្រុមហ៊ុនអង្គរហ្គោល ទោះបីការងារមានលក្ខណៈគ្រោះថ្នាក់ និងសក្តានុពលនៃការរអិលបាក់ដីដែលបង្កឡើងដោយប្រតិបត្តិការជីកយករ៉ែក៏ដោយ។

អ្នកភូមិបាននិយាយថា កម្មករក្រុមហ៊ុនអាចទទួលបានអន្តេវាសិកដ្ឋានសាមញ្ញមួយដែលមានទឹកស្អាត និងអនាម័យ។ លើសពីនេះ កម្មករត្រូវបានផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ធម្មតាៗដោយក្រុមហ៊ុន ហើយការដ្ឋានអណ្តូងរ៉ែមិនមានគ្រូពេទ្យសង្គ្រោះបឋមដែលទទួលបានការបណ្តុះបណ្តាល ឬសេវាវេជ្ជសាស្ត្រឡើយ មិនសូម្បីតែមាន ស្តុកឧបករណ៍សង្គ្រោះបឋមគ្រប់មុខ។ កម្មករបាននិយាយថា ពួកគេ មិនដែលឃើញ មន្ត្រីរដ្ឋាភិបាលធ្វើការ

ត្រួតពិនិត្យលក្ខខណ្ឌការងារនៅអណ្តូងរ៉ែ ហើយ ពួកគេក៏មិនមានឱកាសលើកបញ្ហាសុវត្ថិភាពការងារ ដល់នរណាម្នាក់ក្រៅពីក្រុមហ៊ុន ដែលជារឿយៗមិនអើពើនឹងក្តីកង្វល់របស់ពួកគេ។

*“យើងចង់ឱ្យរណ្តៅកាកសំណល់ (ទឹក) ស្ថិតនៅឆ្ងាយជាងនេះពីអូរ”*
*សមាជិកសហគមន៍*

## ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ

អ្នកភូមិបាននិយាយថា ពួកគេត្រូវបានសន្យានឹងផ្តល់ការគាំទ្រដោយផ្ទាល់នូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពីក្រុមហ៊ុន រួមទាំងថវិកាចំនួន ៦០.០០០ដុល្លារអាមេរិកសម្រាប់ស្ពានមួយសម្រាប់ជួយអ្នកភូមិធ្វើដំណើរទៅកាន់ដីស្រែចម្ការ និងព្រៃសហគមន៍របស់ពួកគេ។ ទឹកប្រាក់បន្ថែមចំនួន ១០០.០០០ ដុល្លារអាមេរិកត្រូវបានសន្យាសម្រាប់ការសាងសង់អណ្តូងឱ្យ គ្រប់គ្រួសារនីមួយៗ ប៉ុន្តែការសន្យាទាំងពីរនេះ មិនបានសម្រេចឡើយ គិតត្រឹមការចេញផ្សាយរបាយការណ៍នេះ។ ការសាងសង់អណ្តូងត្រូវបាន បោះបង់ចោលនៅឆ្នាំ ២០១៦ បន្ទាប់ពី ថ្មក្រានីតក្រោមដី ត្រូវបានរកឃើញដោយក្រុមហ៊ុន ដែលរារាំងការបន្តជីកកាយ ។ ក្រុមហ៊ុនបានផ្តល់ឱ្យអ្នកភូមិនូវពាងទឹកធំសម្រាប់ផ្ទុកទឹក ដែលអ្នកភូមិនិយាយថាមានប្រយោជន៍ក្នុងរដូវវស្សា ប៉ុន្តែបានផ្តល់ជាប្រយោជន៍តិចតួចក្នុងរដូវក្តៅ។ អ្នកភូមិបានបន្ថែមថា ក្រុមហ៊ុនបានស្នើសុំជីកអាងស្តុកទឹក ដែលនឹងតភ្ជាប់ទៅផ្ទះសមាជិកសហគមន៍ដោយគិតថ្លៃ។ ក្រុមហ៊ុនមិនបានសាងសង់អាងស្តុកទឹកនេះទេ ហើយក៏មិនច្បាស់ដែរថាតើក្រុមហ៊ុន បានបោះបង់សំណើនេះឬយ៉ាងណាទេ។

ក្រុមហ៊ុនអង្គរហ្គោល បានជួលគ្រូភាសាអង់គ្លេសសម្រាប់សាលារៀនក្នុងមូលដ្ឋាន។ ទោះយ៉ាងណាក៏ដោយ ជំនួយនេះមានរយៈពេលខ្លីប៉ុណ្ណោះ។ ក្រុមហ៊ុនក៏បានផ្តល់កុំព្យូទ័រយួរដៃមួយដល់សាលារៀនក្នុងមូលដ្ឋានសម្រាប់ឱ្យគ្រូបង្រៀនចែកគ្នាប្រើផងដែរ។

# ករណីសិក្សាទី ២

## ទីតាំង៖ ឃុំចុងផ្លាស ស្រុកកែវសីមា ខេត្តមណ្ឌលគិរី
## ក្រុមហ៊ុនរ៉ែ៖
## ក្រុមហ៊ុនរុងឆេង អ៊ីនដាសស្ទ្រៀល អ៊ិនវេសមិន (ខេមបូឌារ) រីណេសិនមីនីរ៉ល (ខេមបូឌារ)
## សេចក្តីសង្ខេបនៃមតិត្រលប់ពីអ្នកផ្តល់បទសម្ភាស

១. ទីតាំងអណ្តូងរ៉ែចំនួន ៣កន្លែង នៅជុំវិញព្រៃមាស និងអូរខ្វាវ ផ្តល់នូវការឆ្លើយតបចម្រុះទាំងវិជ្ជមាន និងអវិជ្ជមាន និងផ្តល់នូវភាពផ្ទុយគ្នាស្រឡះរវាងក្រុមហ៊ុនមួយដែលកំពុងអនុវត្តតិចតួចបំផុតដែលបានសន្យាចំពោះសហគមន៍ និងក្រុមហ៊ុនមួយដែលមិនយកចិត្តទុកដាក់ចំពោះសុខុមាលភាពរបស់សហគមន៍។

២. អ្នកភូមិសប្បាយចិត្តជាខ្លាំងជាមួយក្រុមហ៊ុនរីណេសិន មីនីរ៉ល (Renaissance Minerals) លើកលែងតែការទន្ទ្រានរបស់ក្រុមហ៊ុនលើដីប្រពៃណីរបស់ពួកគេ និងកង្វះតម្លាភាពជុំវិញផែនការ និងសកម្មភាពរបស់ក្រុមហ៊ុនកាលពីដំបូង ។

៣. អ្នកឆ្លើយសំណួរបានជឿថាក្រុមហ៊ុនរុងឆេង (Rong Cheng) គួរតែពិនិត្យឡើងវិញ និងកែលម្អប្រតិបត្តិការរបស់ពួកគេនៅក្នុងតំបន់នេះឱ្យបានច្រើន ហើយបញ្ឈប់សកម្មភាពរុករកនៅក្នុងព្រៃសហគមន៍។

៤. ទោះបីជាមានអាថ៌កំបាំងជុំវិញប្រតិបត្តិការរបស់ក្រុមហ៊ុនយូនីធី (Unity) ក៏ដោយ ក៏ក្រុមហ៊ុនក៏គួរតែបញ្ឈប់សកម្មភាពរុករកបន្ថែមទៀតទាំងអស់នៅក្នុងព្រៃសហគមន៍ផងដែរ។

៥. ការសិក្សាលទ្ធភាព និងការវាយតម្លៃហេតុ ប៉ះពាល់បរិស្ថាន ចាំបាច់ត្រូវតែអាចធ្វើបានយ៉ាងងាយស្រួល និងរួមបញ្ចូលសំឡេងសហគមន៍ឱ្យបានកាន់តែច្រើន។

៦. ក្រុមហ៊ុនទាំងបីត្រូវតែគោរពជីវភាពបែបប្រពៃណីរបស់សហគមន៍ដោយអនុញ្ញាតឱ្យអ្នកជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចបែបប្រពៃណីបន្តប្រតិបត្តិការរបស់ពួកគេ ដោយអនុញ្ញាតឱ្យប្រជាជនប្រមូលអនុផលព្រៃឈើដែលមិនមែនជាឈើ និងបញ្ឈប់ការរឹតបន្តឹងកសិករមិនឱ្យធ្វើស្រែចម្ការពនេចរ (shifting cultivation)។

## ប្រវត្តិក្រុមហ៊ុន និងទីតាំងអណ្តូងរ៉ែ

### *ក្រុមហ៊ុនរុងឆេង Rong Cheng*

ក្រុមហ៊ុនរុងឆេង អ៊ីនដាសស្រ្ទៀល អ៊ិនវេសមិន (ខេមបូឌារ) Rong Cheng Industrial Investment (Cambodia) Co. Ltd ត្រូវបានចុះបញ្ជីនៅក្នុងឆ្នាំ ២០១៥ នេះបើយោងតាមក្រសួងពាណិជ្ជកម្ម កម្ពុជា។ មិនច្បាស់ទេថាក្រុមហ៊ុនបានដំណើរការនៅការដ្ឋានរយៈពេលប៉ុន្មានមកហើយ និងមិនមានតម្លាភាពជាមួយនឹងរចនាសម្ព័ន្ធសាជីវកម្មរបស់ខ្លួន។

មេឃុំក្នុងមូលដ្ឋានបានបង្ហើបកាលពីឆ្នាំ ២០១៥ ថា ក្រុមហ៊ុននេះពីមុនហៅថាក្រុមហ៊ុនចុងចេង (Chung Cheng) ហើយត្រូវបានអនុញ្ញាតឱ្យធ្វើការសិក្សាអំពីលទ្ធភាពនៅឆ្នាំ ២០០៤។ ប៉ុន្តែនៅឆ្នាំ ២០១២ មន្ត្រីរដ្ឋាភិបាល បានបិទការដ្ឋាននេះ បន្ទាប់ពីធ្វើការវាយតម្លៃថា ក្រុមហ៊ុនកំពុងរុករកមាស ដោយខុសច្បាប់។ អាជ្ញាប័ណ្ណជីកយករ៉ែរបស់ក្រុមហ៊ុនរុងឆេង និងឯកសារពាក់ព័ន្ធ អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនមានជាសាធារណៈទេ។

បន្ទាប់ពីមានការ រាយការណ៍ថា មានការស្លាប់ដោយសារការបំពុលក្នុងឆ្នាំ ២០១៨ ក្រុមហ៊ុនរុងឆេង បានធ្វើការប្រកែកដែលថាខ្លួនមិនបានធ្វើការជីករ៉ែ នៅកំឡុងពេលដែលមានអ្នកស្លាប់នោះទេ។ វាត្រូវបានដកស្រង់នៅក្នុងអត្ថបទ ព័ត៌មានមួយ[១៤] ដោយចុះថា "ក្រុមហ៊ុនមិនប្រើប្រាស់សារធាតុគីមីទេ ដោយសារក្រុមហ៊ុនមិនទាន់ដំណើរការ ការជីកយករ៉ែមាសនៅឡើយ យើងទើបតែ កំពុងសាងសង់ហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះ" និយាយដោយតំណាងក្រុមហ៊ុន។ លោកបន្ថែមថា៖ «ពួកយើងស្វាគមន៍អាជ្ញាធរជាតិចុះមកពិនិត្យយើងរកសារធាតុគីមី»។ សេចក្តីថ្លែងការណ៍ជាសាធារណៈពីមន្ត្រីរដ្ឋាភិបាលនៅពេលនោះ គឺផ្ទុយស្រឡះពីប្រភពនៃសារធាតុពុល ដោយរដ្ឋមន្ត្រីមួយរូបបានប៉ាន់ស្មានថា ការបង្ហូរជាតិពុលចេញពីអណ្តូងរ៉ែ របស់ក្រុមហ៊ុនរុងឆេង ត្រូវទទួលខុសត្រូវ។ នេះក្រោយមកត្រូវបានបដិសេធដោយមន្ត្រីមកពីក្រសួងផ្សេងទៀត ដែលបានភ្ជាប់មូលហេតុនៃ ការស្លាប់នោះទៅ នឹងការស្លាប់ដោយសារផឹកស្រាសរហួសកម្រិត។

នាយកក្រុមហ៊ុនរុងឆេង ម្នាក់ៗមកពីតំបន់ផ្សេងៗគ្នានៃប្រទេសចិន៖ ទីក្រុងប៉េកាំង ខេត្តហឺណាន និងទីក្រុងសិនជិន នេះបើយោងតាមព័ត៌មានស្តីពីបញ្ជីឈ្មោះក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មកម្ពុជា។ លោកយ៉ាង សុជុន (Yang Shujun) ដែលជាអតីតប្រធានក្រុមហ៊ុន គឺជាម្ចាស់ភាគហ៊ុននៅក្រុមហ៊ុនហ្សុង ស៊ីន អ៊ិនដាសស្រ្ទៀល អ៊ិនវេសមិន (ខេមបូឌារ) Zhong Xin Industrial Investment (Cambodia) Co., Ltd ដែលក៏បានចុះបញ្ជីសមាជិកព្រឹទ្ធសភាកម្ពុជាដ៏មានឥទ្ធិពល ឈ្មោះឡៅម៉េងឃិន (Lau Ming Khin) ជាម្ចាស់ភាគហ៊ុនម្នាក់ផងដែរ។ ពួកគេត្រូវបានកត់ត្រាថាផ្ទេរភាគហ៊ុនរបស់ពួកគេទៅបុគ្គលផ្សេងទៀតក្នុងឆ្នាំ ២០០៥ ។

យោងតាមរបាយការណ៍ របស់ប្រព័ន្ធផ្សព្វផ្សាយ ក្រុមហ៊ុនហ្សុង ស៊ីន ពីមុនមានឈ្មោះ ក្រុមហ៊ុនជីងឈូមីនើរ៉ល (Jinqu Mineral) ដែលមានអាសយដ្ឋានក្នុងបញ្ជីដែលត្រូវនឹងអាសយដ្ឋានផ្លូវការរបស់ក្រុមហ៊ុនពហុផលិតផលរបស់ប្រទេសកម្ពុជា ឈ្មោះ ក្រុមហ៊ុន

[១៤] សូមចូលទៅកាន់តំណ: https://www.khmertimeskh.com/494101/miners-flee-amid-compliance-push/

ភាពប៊ីម៉ិច (Pheapimex) ដែលជាកម្មសិទ្ធិរបស់គ្រួសារលោក ឡៅ ម៉េងឃិន ។ ក្រុមហ៊ុនហ្សុង ស៊ីន ចាប់ពីពេលនោះមកត្រូវបានដកចេញពីបញ្ជីឈ្មោះក្រុមហ៊ុន។

អតីតនាយកម្នាក់របស់ក្រុមហ៊ុនរុងឆេង ឈ្មោះជីង គងឆៃ (Jin Guangcai) បានចុះបញ្ជីអាសយដ្ឋានផ្លូវការរបស់ពួកគេជា " អគារលំនៅដ្ឋាននៃក្រុមហ៊ុន ហេណាន លីងប៉ាវ ហ្គោល គ្រុប (Henan Lingbao Gold Group Co., Ltd) ប្រទេសចិន" ដែលអាចជាក្រុមហ៊ុនមេរបស់ក្រុមហ៊ុនរុងឆេង ។ យោងតាមព័ត៌មានថ្មីៗឆ្នាំ ២០១៦ ពីក្រសួងពាណិជ្ជកម្មរបស់ប្រទេសចិន ក្រុមហ៊ុនលីងប៉ាវ ហ្គោល និងក្រុមហ៊ុនរុងឆេង បានចុះហត្ថលេខា លើលិខិតស្តីពីគោលបំណងរួមគ្នាអភិវឌ្ឍអណ្តូងរ៉ែមាស "MESAM" ហើយត្រូវបានចេញឱ្យនូវអាជ្ញាប័ណ្ណអភិវឌ្ឍន៍រ៉ែនៅប្រទេសកម្ពុជា។

ការវិភាគបឋមនៃទស្សនៈវិស័យអំពីអណ្តូងរ៉ែមាស MESAM ត្រូវបានបោះពុម្ពផ្សាយដោយបុគ្គលិករបស់ក្រុមហ៊ុនលីនប៉ាវ ក្នុងឆ្នាំ ២០១៧ ប៉ុន្តែក្រុមហ៊ុនលីនប៉ាវ មិននិយាយអំពីគម្រោង ឬទ្រព្យសកម្មណាមួយនៅក្នុងប្រទេសកម្ពុជានៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួននោះទេ។ លើសពីនេះ ឯកសារសិក្សាស្តីពីការរុករករ៉ែមាស MESAM ដោយវិទ្យាស្ថានស្រាវជ្រាវជាច្រើនដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាលខេត្តហឺណានក្នុងប្រទេសចិនត្រូវបានបោះពុម្ពនៅឆ្នាំ ២០២២ ដែលបង្ហាញថាអណ្តូងរ៉ែមាស MESAM ស្ថិតនៅក្នុងខេត្តមណ្ឌលគិរី។ ការរុករក MESAM គឺជាគម្រោងដ៏សំខាន់មួយនៃ "ការស្វែងរកធនធានរ៉ែខ្សែក្រវ៉ាត់ និងផ្លូវខេត្តហឺណាន" ដែលត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាល។

ក្រុមហ៊ុនលីនប៉ាវ ហ្គោល មកពីខេត្តហឺណាន ហើយត្រូវបានចុះបញ្ជីនៅក្នុងផ្សារហ៊ុនហុងកុង។ ក្រុមហ៊ុននេះពីមុនជាសហគ្រាសខេត្តដែលត្រូវបានគ្រប់គ្រងដោយរដ្ឋ ហើយភាគហ៊ុនភាគច្រើនដែលត្រូវបានគ្រប់គ្រងដោយរដ្ឋត្រូវបានលក់ក្នុងឆ្នាំ ២០១៦ ទៅឱ្យក្រុមហ៊ុន D&R Asset Management Group Co. Ltd. ដែលជាក្រុមហ៊ុនហ៊ុនឯកជនដ៏ល្បីរបស់ប្រទេសចិន។ ក្រុមហ៊ុន D&R កំពុងស្ថិតក្នុងដំណើរការទិញភាគហ៊ុនបន្ថែមទៀតរបស់ក្រុមហ៊ុនលីងប៉ាវ ហើយនៅពេលដែលប្រតិបត្តិការបានបញ្ចប់ក្រុមហ៊ុនD&R នឹងក្លាយជាម្ចាស់ភាគហ៊ុនដែលមានសិទ្ធិគ្រប់គ្រង របស់ក្រុមហ៊ុនលីនប៉ាវ ហ្គោល ជាមួយនឹងភាគហ៊ុន ៤២,៧%។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនD&R ត្រូវបានទទួលរងនូវចំណាត់ការវិន័យដោយសមាគមគ្រប់គ្រងទ្រព្យសកម្មនៃប្រទេសចិនចំពោះការបំពានបទប្បញ្ញត្តិផ្សេងៗ។

មានជម្លោះជាច្រើននៅក្នុងប្រទេសចិនទាក់ទងនឹងភាគហ៊ុនរបស់ក្រុមហ៊ុនរុងឆេង និង/ឬអណ្តូងរ៉ែ។ របាយការណ៍មាននៅលើមូលដ្ឋានទិន្នន័យបង់ថ្លៃ (paywalled databases) របស់ក្រុមហ៊ុន។

បច្ចុប្បន្នក្រុមហ៊ុនរុងឆេង ធ្វើប្រតិបត្តិការលើរណ្តៅមាសចំនួន ៤ ដែលរណ្តៅនីមួយៗមានជម្រៅប្រហែល ៣០០ ម៉ែត្រ។ មានរណ្តៅស្តុកទឹកកាកសំណល់ធំមួយ។



*អណ្តូងខួងរបស់ក្រុមហ៊ុន រុងឆេង (Rong Cheng)*



*រូបថតពីលើអាកាសនៃទីតាំងអណ្តូងរ៉ែ រុងធេង ដែលបង្ហាញពីរណ្តៅទឹកស្អុយពណ៌ត្នោត ។*

*“ ប៉ូលីសសហព័ន្ធអូស្ត្រាលីបានរាយការណ៍ថាក្រុមហ៊ុនបានយល់ព្រមលើដំណោះស្រាយមួយ ជាមួយក្រុមហ៊ុន អូស៊ី មីនើរ៉ល ( Oz Minerals) ដោយខ្លួនបានសារភាពថាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួននៅកម្ពុជាបានផ្តល់សំណូកដល់មន្ត្រីកម្ពុជាដើម្បីទទួលបានអាជ្ញាប័ណ្ណរ៉ែ”*

### ***ក្រុមហ៊ុនរីណេសិន មីនីរ៉ល*** *( Renaissance Minerals)*



*ទិដ្ឋភាពពីលើអាកាសនៃប្រតិបត្តិការក្រុមហ៊ុនរីណេសិន នៅក្នុងព្រៃ*

ក្រុមហ៊ុនរីណេសិន មីនីរ៉ល (ខេមបូឌារ) ( Renaissance Minerals (Cambodia) Ltd.) ត្រូវបានបង្កើតក្នុងឆ្នាំ ២០០៦ ជាក្រុមហ៊ុនសាខារបស់ក្រុមហ៊ុនអូស៊ីនអាណា លីមីតធីត Oxiana Limited ដែលជាក្រុមហ៊ុនចុះបញ្ជីនៅផ្សារហ៊ុនប្រទេសអូស្ត្រាលី[១៥]។ ក្រោយមក ក្រុមហ៊ុនមេបានបញ្ចូលគ្នាជាមួយក្រុមហ៊ុនមួយទៀត ហើយដាក់ឈ្មោះថ្មីថា ក្រុមហ៊ុនអូស៊ី មីនីរ៉ល។ ក្រុមហ៊ុនអូស៊ី មីនីរ៉ល ក្រោយមកបានលក់ផលប្រយោជន៍ទាំងអស់របស់ខ្លួននៅកម្ពុជាទៅឱ្យក្រុមហ៊ុនអូស្ត្រាលីមួយទៀត ឈ្មោះក្រុមហ៊ុនអ៊ីមីរ៉ល រីសូស អិនអិល (Emerald Resources NL) ដែលជាក្រុមហ៊ុនដែលបានចុះបញ្ជីផ្សារភាគហ៊ុន ប្រទេសអូស្ត្រាលី មួយផ្សេងទៀត នៅក្នុងខែឧសភា ឆ្នាំ ២០១២។ ការរួមបញ្ចូលគ្នាជាផ្លូវការជាមួយក្រុមហ៊ុនរីណេសិន ត្រូវបានបញ្ចប់នៅឆ្នាំ ២០១៦ ។ ការចម្រាញ់យកមាសនៅការដ្ឋានជីករ៉ែអូរខ្វាវរបស់ខ្លួនបានចាប់ផ្ដើមនៅក្នុងឆ្នាំ ២០២១ និងបានបង្កើនផលិតកម្មយ៉ាងឆាប់រហ័សក្នុងការក្លាយជាអ្នកផលិតមាសដ៏ធំបំផុតរបស់ប្រទេសកម្ពុជា។

កាលពីខែសីហា ឆ្នាំ ២០២៣ ប៉ូលីសសហព័ន្ធអូស្ត្រាលីបានរាយការណ៍ថាក្រុមហ៊ុនបានយល់ព្រមលើដំណោះស្រាយមួយ ជាមួយក្រុមហ៊ុន អូស៊ី មីនីរ៉ល (Oz Minerals) ដោយខ្លួនបានសារភាពថាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួននៅកម្ពុជាបានផ្ដល់សំណូកដល់មន្ត្រីកម្ពុជាដើម្បីទទួលបានអាជ្ញាប័ណ្ណរ៉ែ។ ក្រុមហ៊ុនអូស៊ី មីនីរ៉ល បានបោះបង់ប្រាក់ពីការលក់ទាំងអស់របស់ខ្លួនពីក្រុមហ៊ុនរីណេសិន ទៅឱ្យ

[១៥] សូមចូលទៅកាន់តំណ: https://www.afp.gov.au/news-centre/media-release/australian-mining-company-investigated-afp-over-alleged-foreign- bribery

ក្រុមហ៊ុន អ៊ីមីរ៉ល រីសូស (៩,៣ លានដុល្លារអូស្ត្រាលី) និងការពិន័យជាប្រាក់ ចំនួន ៣,៦៥ លានដុល្លារអូស្ត្រាលី។ នេះជាករណីដំបូងដែលប្រតិបត្តិកររ៉ែ បានសារភាពថាបានបង់ប្រាក់សំណូកដល់មន្ត្រីកម្ពុជា ប៉ុន្តែដោយសារការពិចារណាលើផ្នែកការទូត នគរបាលសហព័ន្ធប្រទេសអូស្ត្រាលីមិនបានរាយការណ៍ពីចំនួនទឹកប្រាក់ពិតប្រាកដដែលបានបង់ឱ្យមន្ត្រីទាំងនោះទេ ។ ដោយការពារអាជ្ញាប័ណ្ណរបស់ខ្លួនឱ្យបានជាប់លាប់ ទោះបីជាតាមរយៈមធ្យោបាយពុករលួយក៏ដោយ ក្រុមហ៊ុនរីណោសិន មីនីរ៉ល បានបង្ហាញពីការប្តេជ្ញាចិត្តមួយចំនួនចំពោះតម្លាភាព និងគណនេយ្យភាព ហើយត្រូវបានកោតសរសើរពីសំណាក់មន្ត្រីក្រសួងកម្ពុជាថាជាអ្នកដឹកនាំក្នុងវិស័យនេះ។

ក្រុមហ៊ុនរីណោសិន បានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់អណ្តូងរ៉ែអូរខ្វាវរបស់ខ្លួននៅក្នុងខែកក្កដា ឆ្នាំ ២០១៧ ដែលរបាយការណ៍ការ វាយតម្លៃនេះអាចរកបានជាសាធារណៈ។ ប៉ុន្តែរបាយការណ៍នេះធ្វើឡើងដោយក្រុមហ៊ុនកម្ពុជាមួយដែលមិនមានវត្តមានតាមប្រព័ន្ធអ៊ីនធឺណែត និងរួមជាមួយនឹងក្រុមហ៊ុនអូស្ត្រាលីមួយដែលហាក់ដូចជាមិនបានចូលរួមក្នុងការងារចុះផ្ទាល់ណាមួយទេ ហើយផ្ទុយទៅវិញបានធ្វើសុពលកម្មលើព័ត៌មានដែលបាន ផ្ទៀងផ្ទាត់ដោយដៃគូកម្ពុជា។ ការវាយតម្លៃហេតុប៉ះពាល់ដល់បរិស្ថាន និងសង្គមថ្លែងថា "ប្រជាពលរដ្ឋដែលអាចរងផលប៉ះពាល់ និងអាជ្ញាធរមូលដ្ឋានបានចូលរួមជាទៀងទាត់តាមរយៈការពិគ្រោះយោបល់លើព័ត៌មាន និងជាផ្លូវការនៅក្នុងដំណើរការវាយតម្លៃ" និងរៀបរាប់ពីកិច្ចប្រជុំចំនួនបីដែលមានព័ត៌មានលម្អិតដូចជា៖ កិច្ចប្រជុំជាមួយមន្ត្រីស្រុកដើម្បីពិភាក្សាអំពី "ផលប៉ះពាល់" កិច្ចប្រជុំមួយផ្សេងទៀតជាមួយមន្ត្រីខេត្ត និង បុគ្គលិក PPWS ដើម្បីពិភាក្សាអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងកិច្ចប្រជុំចុងក្រោយជាមួយមន្ត្រីថ្នាក់ខេត្តដើម្បីពិភាក្សាអំពី "ការតាំងទីលំនៅថ្មីរបស់ប្រជាជនអូរខ្វាវ"។

## *ក្រុមហ៊ុនយូនីធី មេតាល (Unity Metals)*

ក្រុមហ៊ុនមួយផ្សេងទៀតដែលជារឿយៗ ត្រូវបានហៅដោយអ្នកស្រុកថា ក្រុមហ៊ុនយូនីធី "Unity" ត្រូវបានរាយការណ៍ ថាកំពុងធ្វើ ការសិក្សាមួយចំនួនអំពីលទ្ធភាព នៅក្នុងតំបន់នេះ ប៉ុន្តែវិសាលភាពច្បាស់លាស់នៃ ការស៊ើបអង្កេតរបស់ពួកគេមិនទាន់ដឹងនៅឡើយទេ។ ក្រុមហ៊ុនយូនីធី បានជួបប្រជុំជាច្រើនលើកជាមួយមន្ត្រីមូលដ្ឋាន ហើយនៅក្នុងកិច្ចប្រជុំមួយក្នុងខែមេសា ឆ្នាំ ២០២៣ ក្រុមហ៊ុនយូនីធី បានផ្តល់ជូនសមាជិកគណៈកម្មាធិការព្រៃឈើសហគមន៍មួយនូវ អង្ករ មីកញ្ចប់ ត្រី សាប៊ូ និងទឹកស៊ីអ៊ីវ។ ក្នុងកិច្ចប្រជុំនេះ មន្ត្រីក្រសួងបរិស្ថានបានអះអាងជាថ្មីចំពោះអ្នកមានវត្តមានថា ក្រុមហ៊ុននឹងធ្វើសកម្មភាព នៅក្រោមដីតែប៉ុណ្ណោះ។ ការលើកឡើងនេះបង្កក្តីព្រួយបារម្ភដល់ អ្នកភូមិដែលយល់ឃើញថា ពាក្យសំដីនេះ "នៅក្រោមដី" គឺដីនៅពីក្រោមផ្ទាល់ដីព្រៃសហគមន៍ របស់ពួកគាត់។ ការស្នើសុំរបស់ តំណាងក្រុមហ៊ុន ដើម្បីរុករករ៉ែ ត្រូវបានច្រានចោលទាំងស្រុង ដោយសមាជិកគណៈកម្មាធិការសហគមន៍ ហើយមិនមានកិច្ចប្រជុំផ្សេងទៀតត្រូវបានធ្វើឡើងទេ ហើយក៏មិនមានសកម្មភាពរុករកណាមួយត្រូវបានរាយការណ៍ពីតំបន់នោះដែរ។



*ស្ថាបនិកក្រុមហ៊ុន អូស៊ីអាណា អិលធីឌី គ្រុប (Oxiana Ltd Group,) លោក អូវិន ហេហ្គាធី (Owen Hegarty Oxiana Ltd) បានយល់ព្រមលើដំដោះស្រាយក្រៅតុលារឿងសូកប៉ាន់មន្ត្រីកម្ពុជា ។*

## ប្រវត្តិភូមិ

ភូមិទាំងបីក្នុងឃុំចុងផ្លាស់ត្រូវបានរស់នៅភាគច្រើនដោយជនជាតិដើមភាគតិចពួងជាមួយនឹងជនជាតិខ្មែរដើមមួយចំនួនបានផ្លាស់ទីលំនៅមកក្នុងភូមិតាំងពីទសវត្សរ៍ឆ្នាំ ១៩៩០ មក ដោយផ្លាស់ប្តូរសមាសធាតុជនជាតិដើមភាគតិចរបស់ភូមិ។ ភូមិពូតុងគឺជាការដ្ឋាននៃការជីកយករ៉ែខ្នាតតូចរបស់សហគមន៍ជនជាតិដើមភាគតិចជាច្រើនជំនាន់មកហើយ។ រហូតមកដល់ទសវត្សរ៍ឆ្នាំ ១៩៩០ ស្ទើរតែគ្មានជនជាតិដើមខ្មែររស់នៅភូមិពូតុងទៀតទេ។ ដោយសារតែប្រជាពលរដ្ឋខ្មែរកាន់តែច្រើនបានផ្លាស់ទីលំនៅទៅតំបន់នោះ ពួកគេបានផ្តល់ប្រាក់ពី ២៥០ ដុល្លារអាមេរិកទៅ ៥០០ ដុល្លារអាមេរិកសម្រាប់ដីជាច្រើនឡូតិ៍នៅក្នុងតំបន់ជីករ៉ែដោយដៃដែលធ្វើឱ្យជនជាតិដើមភាគតិចមួយចំនួនបោះបង់តំបន់នោះចោលដោយខ្លាចអ្នកចំណូលថ្មី។ តំបន់នោះត្រូវបានគេហៅថាជា "ព្រៃមាស" ដោយសារធនធានមាសដ៏ច្រើនសន្ធឹកសន្ធាប់នៅទីនោះ។ មុនពេលការប្រើប្រាស់មេកានិកម្មក្នុងប្រតិបត្តិការជីករ៉ែក្នុងទសវត្សរ៍ឆ្នាំ ២០០០ អ្នកភូមិប្រើឧបករណ៍សាមញ្ញៗដូចជាចបកាប់ និងប៉ែល ដើម្បីជីករណ្តៅ។ ពួកគេនឹងដុតគំនរដីដែលបានជីកដើម្បីបំបែកថ្មរកមាសនៅខាងក្នុង។

តំបន់នេះត្រូវបានកត់សម្គាល់ថាជាតំបន់ព្រៃស្រោងដែលមានជីវៈចម្រុះមានតម្លៃខ្ពស់ ដែលស្ថិតនៅក្នុងតំបន់ការពារចំនួនពីរនៅក្បែរនោះ គឺដែនជម្រកសត្វព្រៃភ្នំព្រិច និងដែនជម្រកសត្វព្រៃកែវសីមា។ សហគមន៍ក្នុងភូមិទាំងបីក៏មានតំបន់ការពារសហគមន៍ធំគួរសមមួយដែលមានដើមឈើកៅស៊ូមានតម្លៃ ក្រៅពីនេះក៏ជាប្រភពដ៏សំខាន់នៃអនុផលព្រៃឈើមិនមែនឈើ និងមានការអភិរក្សជីវចម្រុះផងដែរ។ តំបន់ការពារក្នុងមូលដ្ឋាននេះត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការសហគមន៍។ អ្នកភូមិខ្លះមានអត្តសញ្ញាណប័ណ្ណ ដែលបញ្ជាក់ជាផ្លូវការថាពួកគេជាអ្នកថែរក្សាដើមកៅស៊ូ។ ហើយរបាយការណ៍ក៏បង្ហាញថា មានការកាប់ដើមឈើកៅស៊ូដែលត្រូវបានការពារ និងមានតម្លៃទាំងនេះដោយខុសច្បាប់ផងដែរ។

សមាជិកសហគមន៍បានផ្លាស់ប្តូរទៅធ្វើស្រែចម្ការដាំដំឡូងមី និងស្វាយចន្ទីលក់យកប្រាក់ ប៉ុន្តែនៅតែពឹងផ្អែកខ្លាំងលើការប្រមូលផលអនុផលព្រៃឈើ។ ការធ្វើកសិកម្ម ពនេចរតាមបែបប្រពៃណី សម្រាប់ការចិញ្ចឹមជីវិត ត្រូវបានហាមឃាត់ដោយ យោងតាមបទប្បញ្ញត្តិរបស់ដែនជម្រកសត្វព្រៃភ្នំព្រិច។


សេចក្ដីបញ្ជាក់
ព្រំព័ទ្ធជុំវិញតំបន់ប្រតិបត្តិការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុនទីរីណេសង់ គឺជាការគូសដោយប្រហាក់ប្រហែល ដោយសារមិនមានទិន្នន័យជាសាធារណៈផ្លូវការ ។ ព្រំព័ទ្ធជុំវិញនៃតំបន់ធ្វើអាជីវកម្មនេះ គឺគូសឡើងដោយផ្អែកលើទិន្នន័យផ្លូវ និងលក្ខណៈភូមិសាស្ត្រផ្សេងទៀតសំខាន់ៗដែលព័ទ្ធជុំវិញតំបន់រុករករ៉ែ ។
0 0.3 0.6 Kilometers
សេចក្ដីបញ្ជាក់
ព្រំព័ទ្ធជុំវិញតំបន់ប្រតិបត្តិការធ្វើអាជីវកម្មរ៉ែរបស់ក្រុមហ៊ុនរ៉ុងផេង គឺជាការគូសដោយប្រហាក់ប្រហែលដោយសារមិនមានទិន្នន័យជាសាធារណៈផ្លូវការ ។ ព្រំព័ទ្ធជុំវិញនៃតំបន់ធ្វើអាជីវកម្មនេះ គឺគូសឡើងដោយផ្អែកលើទិន្នន័យផ្លូវ និងលក្ខណៈភូមិសាស្ត្រផ្សេងទៀតសំខាន់ៗដែលព័ទ្ធជុំវិញតំបន់រុករករ៉ែ ។
0 0.1 0.2 Kilometers
ព្រែកម៉ាញ់
ព្រែកទេ
ព្រែកទេ
តំបន់អាជីវកម្មរ៉ែ រីណេសង់
តំបន់អាជីវកម្មរ៉ែ រ៉ុងផេង
ពូហ្វូន
ពូទុង
0 5 10 Kilometers
តំបន់ធ្វើអាជីវកម្មរ៉ែមាសរបស់ក្រុមហ៊ុន
រីណេសង់ និងរ៉ុងផេង ខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា
សញ្ញាសំគាល់
ភូមិដែលបានសំភាសន៍
អាងស្តុកទឹកកខ្វក់ដែលអាចមានជាតិពុល
តំបន់ធ្វើអាជីវកម្មរ៉ែ រីណេសង់
តំបន់ធ្វើអាជីវកម្មរ៉ែ រ៉ុងផេង
ផ្លូវ
អូរ
តំបន់ធ្វើអាជីវកម្មរ៉ែក្រុមហ៊ុនរ៉ុងផេង
តំបន់ធ្វើអាជីវកម្មរ៉ែក្រុមហ៊ុនរីណេសង់
សម្បទានរ៉ែក្រុមហ៊ុនរីណេសង់
សម្បទានរ៉ែក្រុមហ៊ុនរ៉ុងផេង
មាត្រដ្ឋាន: 1:260,000
ប្រព័ន្ធកូអរដោណេ: W.G.S 1984
ប្រភពទិន្នន័យ: Opendevelopment.net, Esri SatelliteImagery, Google Earth, Handhelp GPS

## ការពិគ្រោះយោបល់ជាសាធារណៈ

អ្នកផ្តល់បទសម្ភាសមកពីភូមិទាំងបីបានរាយការណ៍ថា មានតែក្រុមហ៊ុនរីណេសិន មីនីរ៉ល ប៉ុណ្ណោះដែលធ្លាប់ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដែលត្រូវបានសម្របសម្រួលដោយអាជ្ញាធរមូលដ្ឋាន។ ទោះជាយ៉ាងណាក្តី កិច្ចប្រជុំពិគ្រោះយោបល់មួយនេះត្រូវបានរៀបចំឡើងជាការបង្ហាញអំពីអ្វីដែលត្រូវបានគ្រោងទុកសម្រាប់តំបន់ ជាជាងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យដែលគិតគូរពីមតិកែលម្អ និងការឆ្លើយតបរបស់សហគមន៍។ កិច្ចប្រជុំពិគ្រោះយោបល់នេះធ្វើឡើងនៅសាលាឃុំចម្ងាយប្រហែល ៧គីឡូម៉ែត្រពីភូមិពូគុង ប៉ុន្តែអ្នកភូមិជាច្រើន រួមទាំងអ្នកផ្តល់បទសម្ភាសម្នាក់មិនបានដឹងអ្វីទាល់តែសោះពីការប្រជុំនោះ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយមិនដែលត្រូវបានបង្ហាញដល់សមាជិកសហគមន៍ដែលរងផលប៉ះពាល់ សម្រាប់ការពិចារណា ឬមតិកែតម្រូវលប់របស់ពួកគេឡើយ។

អ្នកផ្តល់បទសម្ភាសបាននិយាយថាក្រុមហ៊ុនរុងឆេង មិនបានរៀបចំព្រឹត្តិការណ៍ពិគ្រោះយោបល់ជាសាធារណៈទេកន្លងមក មិនដូចក្រុមហ៊ុនរីណេសិន មីនីរ៉ល ទេ ហើយមិនអនុញ្ញាតឱ្យអ្នកភូមិណាម្នាក់ចូលទៅកាន់ការដ្ឋានអណ្តូងរ៉ែរបស់ពួកគេដើម្បីសង្កេតមើលប្រតិបត្តិការទេ។

## បរិយាបន្នសង្គម សិទ្ធិការងារ សុខភាព និងសុវត្ថិភាពការងារ

ទាំងក្រុមហ៊ុនរីណេសិន មីនីរ៉ល និងក្រុមហ៊ុនរុងឆេង បានផ្តល់ឱកាសការងារដល់អ្នកភូមិក្នុងមូលដ្ឋាន ប៉ុន្តែអ្នកភូមិភាគច្រើននិយាយថា ពួកគេចូលចិត្តធ្វើស្រែចម្ការជាង ។ ក្រុមហ៊ុនរីណេសិន មីនីរ៉ល បានផ្តល់ការងារយ៉ាងសកម្មសម្រាប់សហគមន៍មូលដ្ឋាន ដោយធានាថាការផ្តល់ជូនការងារត្រូវបានផ្សព្វផ្សាយយ៉ាងត្រឹមត្រូវ ។ ពួកគេតម្រូវឱ្យអ្នកដាក់ពាក្យសុំបញ្ជាក់ថាពួកគេជាអ្នករស់នៅក្នុងមូលដ្ឋានដោយស្នើសុំអត្តសញ្ញាណប័ណ្ណរបស់ពួកគេ ហើយបានចាប់ផ្តើមកម្មវិធីការងារដោយលើកកម្ពស់ការងារសម្រាប់ស្ត្រី។ អ្នកផ្តល់បទសម្ភាសបានផ្តល់មតិត្រលប់វិជ្ជមានអំពីបរិយាកាសការងារទូទៅនៅការដ្ឋានអណ្តូងរ៉ែ។ ក្រុមហ៊ុនបានផ្តល់ថ្ងៃឈប់សម្រាកសម្រាប់ថ្ងៃបុណ្យជាតិ និងផ្តល់លក្ខខណ្ឌការឈប់សម្រាកដែលមានលក្ខណៈអំណោយផល។ ក្រុមហ៊ុនរីណេសិន មីនីរ៉ល ក៏បានផ្តល់គ្រឿងបរិក្ខារពេទ្យល្អៗនៅនឹងកន្លែង បានធ្វើការត្រួតពិនិត្យរាងកាយជាប្រចាំសម្រាប់បុគ្គលិក និងត្រូវបានបំពាក់ដោយរថយន្តសង្គ្រោះបន្ទាន់ក្នុងករណីមានអាសន្នផ្នែកវេជ្ជសាស្ត្រ។ អ្នកភូមិបានបន្ថែមថាក្រុមហ៊ុនរីណេសិន ក៏ផ្តល់កញ្ចប់ជំនួយសុខភាពមាតាផងដែរ។

ផ្ទុយទៅវិញ ក្រុមហ៊ុនរុងឆេង មានលក្ខណៈអាក្រក់ទាក់ទងនឹងការផ្តល់របស់ពួកគេដល់បុគ្គលិក។ អ្នកផ្តល់បទសម្ភាសបានរាយការណ៍ថាមិនមានការរៀបចំថ្ងៃឈប់សម្រាកដែលមានប្រាក់ឈ្នួលទេ ហើយមានជំនួយផ្នែកវេជ្ជសាស្ត្រ ឬការព្យាបាលសង្គ្រោះបឋមត្រឹមត្រូវតិចតួច ឬគ្មានទាល់តែសោះនៅការិយាល័យ ឬការដ្ឋានអណ្តូងរ៉ែ។ អ្នកផ្តល់បទសម្ភាសម្នាក់បានរាយការណ៍ថាយ៉ាងហោចណាស់មានកម្មករម្នាក់បានស្លាប់នៅការដ្ឋានអណ្តូងរ៉ែក្នុងព្រៃមាស ហើយបានផ្តល់នូវទស្សនៈអវិជ្ជមានលើស្ថានភាពសុវត្ថិភាពនៅអណ្តូងរ៉ែ។

## ផលប៉ះពាល់សង្គម និងបរិស្ថាន

អ្នកជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចជាច្រើន ត្រូវបានច្រានចេញបន្តិចម្តងៗពីតំបន់ព្រៃមាស ជាកន្លែងដែលក្រុមហ៊ុនរុងឆេង ធ្វើប្រតិបត្តិការ និងតំបន់អូរខ្វាវ ដែលក្រុមហ៊ុនរីណេសិន មីនីរ៉ល បានរាយការណ៍ថាបានបង់ប្រាក់សំណងស្តួចស្តើងដល់កម្មកររ៉ែដែលត្រូវបានបង្ខំឱ្យផ្លាស់ទី។

អ្នកជីករ៉ែទ្រង់ទ្រាយតូច ដែលបាននិងកំពុងប្រើប្រាស់បច្ចេកទេសបែបបុរាណក្នុងព្រៃមាស ត្រូវបានមន្ត្រីមូលដ្ឋានហាមឃាត់ បន្ទាប់ពីក្រុមហ៊ុនរុងឆេង បានចាប់ផ្តើមសកម្មភាពរុករកទ្រង់ទ្រាយធំនៅឆ្នាំ២០-១៧។ ទោះជាយ៉ាងណា អ្នកជីករ៉ែទ្រង់ទ្រាយតូចមួយចំនួនត្រូវបានអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រៃមាស ប៉ុន្តែលក្ខណៈវិនិច្ឆ័យសម្រាប់ការអនុញ្ញាតឱ្យបន្តការជីកយករ៉ែទ្រង់ទ្រាយតូចមិនមានលក្ខណៈច្បាស់លាស់ទេ។ អ្នកផ្តល់បទសម្ភាសបានពោលថា កាលពីមុន អ្នកជីករ៉ែទ្រង់ទ្រាយតូចឯកជន និងក្រុមហ៊ុនរុងឆេង បានព្រងើយកន្តើយនឹងការអំពាវនាវជាផ្លូវការឱ្យផ្អាកប្រតិបត្តិការ និងសកម្មភាពបន្តជីកយករ៉ែនៅតំបន់នោះ។

ក្នុងអំឡុងពេលសម្ភាស សមាជិកសហគមន៍បាននិយាយថា ក្រុមហ៊ុនរីណេសិន មីនីរ៉ល បានសាងសង់ផ្លូវមួយដែលកាត់ព្រៃសហគមន៍របស់ពួកគេ ដោយបានបំផ្លាញ ដើមជ័រឈើប្រហែល ២០០ដើម។ ក្រុមហ៊ុនបានរាយការណ៍ ថាបានបង់ប្រាក់សំណងស្តួចស្តើងដល់ អ្នកភូមិដែលបានបាត់បង់ដើមជ័រឈើ។

អ្នកជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចដែលរស់នៅក្នុងតំបន់នោះ ហើយត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅ ទទួលបានសំណងចន្លោះពី ១.០០០ ដុល្លារអាមេរិក ទៅ ៥.០០០ ដុល្លារអាមេរិក អាស្រ័យលើទំហំដីរបស់ពួកគេ ហើយឥឡូវនេះត្រូវបានតាំងទីលំនៅនៅក្នុងតំបន់ដែលនៅជាប់នឹងព្រៃមាស។ អ្នកភូមិទាំងនេះរាយការណ៍ថា ទោះបីជាប្រាក់សំណងសមរម្យក៏ដោយ ក៏ការប្រកបរបរចញ្ចឹមជីវភាពរបស់ពួកគេត្រូវបានកាត់បន្ថយយ៉ាងខ្លាំងតាំងពីផ្លាស់មក។ ប្រជាជនជាច្រើនដែលបាត់បង់ដើមឈើកៅស៊ូក្នុងអំឡុងពេលសាងសង់ផ្លូវនៅមិនទាន់ទទួលបានសំណងនៅឡើយទេ។

អ្នកជីករ៉ែទ្រង់ទ្រាយតូចមកពីតំបន់ព្រៃមាសបាននិយាយថា ពួកគេត្រូវបានបង្ខិតបង្ខំឱ្យលក់ដីរបស់ពួកគេដោយប្រតិបត្តិករខុសច្បាប់ដែលមានទ្រព្យសម្បត្តិច្រើន ហើយពួកគេត្រូវបានបង្ខំឱ្យចាកចេញពីតំបន់នោះ។ អ្នកឆ្លើយសំណួរម្នាក់បាននិយាយថា "នៅព្រៃមាស នៅពេលដែលមានជម្លោះរវាងអ្នកមាន និងអ្នកភូមិ អ្នកមានជាងនឹងឈ្នះ ដោយសារពួកគេនឹងចែកដីខ្លះជាមួយមន្ត្រីរដ្ឋាភិបាលមួយចំនួន ហើយអ្នកចាញ់តែងតែជាជនជាតិព្នងជានិច្ច។"

ក្រៅពីការបាត់បង់ដើមឈើកៅស៊ូ អ្នកស្រុកជនជាតិដើមភាគតិច នៅតំបន់ទាំងពីរ បាននិយាយថា សកម្មភាពសាងសង់ផ្លូវបានប៉ះពាល់ដល់ព្រៃឈើអារក្ស និងផ្នូរដូនតារបស់ពួកគេ។ អ្នកផ្តល់បទសម្ភាសរាយការណ៍ថា ការប្រើប្រាស់គ្រឿងញៀនកាន់តែក្លាយជាបញ្ហានៅក្នុងសហគមន៍ ដោយសាររបៀបរស់នៅបែបប្រពៃណីរបស់សហគមន៍ត្រូវបានរំខាន។

អ្នកផ្តល់បទសម្ភាសន៍បាននិយាយថា មានការ

កើនឡើងគួរឱ្យកត់សម្គាល់នៃការកាប់ឈើខុសច្បាប់នៅក្នុងតំបន់នេះ ដោយសារផ្លូវថ្មីដែលសាងសង់ដោយក្រុមហ៊ុនរីណេសិន មីនីរ៉ល តភ្ជាប់ពីព្រៃមាសទៅអូរខ្វាវ។ អ្នកភូមិបាននិយាយថា នេះជារឿងធម្មតាមួយ ដែលនៅពេលដែលមានការសាងសង់ផ្លូវផ្លូវថ្មីកាត់ព្រៃឈើ ការកាប់ឈើខុសច្បាប់នឹងកើនឡើង។

អ្នកផ្តល់បទសម្ភាសបាននិយាយថាក្រុមហ៊ុនរីណេសិន មីនីរ៉ល ក៏បានដាក់កម្រិតសកម្មភាពបរបាញ់បែបប្រពៃណីនៅក្នុងតំបន់ព្រៃជុំវិញអូរខ្វាវផងដែរ។ អ្នកផ្តល់បទសម្ភាសម្នាក់បានលើកឡើងថា អាចមានការឃុបឃិតគ្នារវាងអ្នកកាប់ឈើខុសច្បាប់ និងមន្ត្រីក្រសួងដើម្បីជួយសម្រួលដល់ការកាប់បំផ្លាញព្រៃឈើខុសច្បាប់។ រាល់ពេលដែលអ្នកភូមិនេះលើកបញ្ហានេះជាមួយមន្ត្រី គាត់ត្រូវបានគេចោទថាជាអ្នកប្រឆាំងនយោបាយ។ ជារឿយៗមន្ត្រីចង់ឱ្យអ្នកភូមិធ្វើការចោទប្រកាន់ជាក់លាក់អំពីការកាប់ឈើខុសច្បាប់ រួមទាំងការកំណត់អត្តសញ្ញាណអ្នកដែលពាក់ព័ន្ធផងដែរ។ ប៉ុន្តែអ្នកភូមិស្ទាក់ស្ទើរក្នុងការបញ្ចេញឈ្មោះអ្នកពាក់ព័ន្ធព្រោះខ្លាចមានការសងសឹក។ អ្នកផ្តល់បទសម្ភាសមិនបានចោទប្រកាន់ពីបទកាប់ឈើខុសច្បាប់លើក្រុមហ៊ុននោះទេ គ្រាន់តែថាវត្តមានផ្លូវថ្មីនេះធ្វើឱ្យមានការធ្វើអាជីវកម្មព្រៃឈើកាន់តែងាយស្រួលដោយអ្នកកាប់ឈើខុសច្បាប់។

អ្នកផ្តល់បទសម្ភាសជាច្រើនបានអះអាងថាក្រុមហ៊ុនរុងឆេង បានចូលរួមក្នុងការអនុវត្តបរិស្ថានមិនល្អ រួមទាំង ការគ្រប់គ្រងទឹកកាកសំណល់ ដែលមានជាតិពុលដែលបណ្តាលឱ្យមានហេតុការណ៍ជាច្រើនដែលមានការរាយការណ៍ថាត្រីជាច្រើនងាប់ នៅក្នុងអូរ ជាពិសេសអូរតេ។

*សមាជិកសហគមន៍ជនជាតិដើមភាគតិចម្នាក់បាននិយាយថា៖ «នៅតំបន់ព្រៃមាស នៅពេលដែលមានជម្លោះរវាងអ្នកមាននិងអ្នកភូមិ អ្នកមានតែងតែឈ្នះ ដោយសារពួកគេមានការបែងចែកចំណែកដីខ្លះដទៅឱ្យមន្ត្រីមូលដ្ឋាន ចំណែកអ្នកដែលចាញ់ជនជាតិពួងយើង»*

## ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ

អ្នកផ្តល់បទសម្ភាសយល់ស្របថាក្រុមហ៊ុនរីណេសិន មីនីរ៉ល បានធ្វើច្រើនជាងដើម្បីរួមចំណែកដល់ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន។ ក្នុងនោះរួមមានការសាងសង់ផ្លូវថ្មី ការបរិច្ចាគសម្រាប់ការជួសជុលស្ពាន និងសាលារៀនក្នុងភូមិចំនួនបី ការជួយដល់ព្រឹត្តិការណ៍ដាំដើមឈើ ការផ្តល់ជំនួយដល់ការខូចខាតដោយសារព្យុះ និងការផ្តល់ជំនួយសម្រាប់កម្មវិធីសុខភាព។

ក្រុមហ៊ុនរីណេសិន មីនីរ៉ល ក៏សកម្មក្នុងការគាំទ្រសហគមន៍មូលដ្ឋានដែរដោយរួមចំណែកជារៀងរាល់ឆ្នាំដល់មូលនិធិអភិវឌ្ឍន៍សហគមន៍ យ៉ាងណាក្តី អ្នកផ្តល់បទសម្ភាសជាច្រើនមិនច្បាស់ថា តើអ្នកអាចទទួលបានមូលនិធិទាំងនេះ ហើយពួកគេមិនអាចផ្តល់ឧទាហរណ៍ណាមួយអំពីអ្នកដែលបានទទួលមូលនិធិនោះដោយជោគជ័យទេ។

ប៉ុន្តែ អ្នកឆ្លើយសំណួរជាច្រើនបាននិយាយថាសកម្មភាពវិជ្ជមានទាំងនេះចាំបាច់ត្រូវថ្លឹងថ្លែងធៀបទៅនឹងការកាប់បំផ្លាញព្រៃឈើនាពេលបច្ចុប្បន្ន និងអនាគតដែលបណ្តាលមកពីផ្លូវថ្មីដែលត្រូវបានសាងសង់ដោយក្រុមហ៊ុនរីណេសិន មីនីរ៉ល ។

ផ្ទុយទៅវិញ ក្រុមហ៊ុនរុងធេង ហាក់ដូចជាបានរួមចំណែកតិចតួចដល់សហគមន៍មូលដ្ឋាន។ មិនមានអ្នកឆ្លើយសំណួរណាម្នាក់បានរាយការណ៍ពីសកម្មភាពអភិវឌ្ឍន៍ជាវិជ្ជមានដោយក្រុមហ៊ុនរុងធេង នៅក្នុងតំបន់នោះទេ។



*ផ្លូវចូលទៅកាន់ព្រៃមាស បង្ហាញមជ្ឈមណ្ឌលថែទាំសុខភាពអូរគ្លៀ*

# ករណីសិក្សាទី៣

## ទីតាំង៖ ភូមិត្រពាំងទទឹម និងភូមិរំដេង ស្រុករវៀង | ភូមិបង្កើនផល (Bangkeum Phal) ខេត្តព្រះវិហារ

## ក្រុមហ៊ុនជីករ៉ែ៖ ក្រុមហ៊ុនឌែលខម កម្ពុជា ភីធីអី (Delcom, Kampuchea PTE) ស៊ិនហ្សាន អ៊ិនដាសស្រ្ទៀល ខេមបូឌារ (Xinshan Industrial, Cambodia)

## សេចក្តីសង្ខេបអំពីមតិត្រលប់ពីអ្នកផ្តល់បទសម្ភាស

១. សមាជិកសហគមន៍ចង់ឱ្យប្រតិបត្តិការជីករ៉ែបញ្ឈប់ការពង្រីកជាបន្ទាន់ ដើម្បីឱ្យក្រុមហ៊ុនទាំងនោះប្រគល់ដីប្រពៃណីមកវិញ ដូច្នោះ ប្រជាពលរដ្ឋអាចត្រឡប់ទៅធ្វើស្រែចម្ការ និងសកម្មភាពជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចវិញ។

២. ក្រុមហ៊ុនដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងតំបន់នេះ គួរតែត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់សម្រាប់ការងាររបស់ពួកគេលើការគ្រប់គ្រងកាកសំណល់ពុល។

៣. អាជ្ញាធរមូលដ្ឋានគួរតែដើរតួនាទីឱ្យបានល្អជាងនេះក្នុងការចែករំលែកព័ត៌មានជាមួយអ្នកមកពីក្រុមហ៊ុន រួមទាំងការធ្វើឱ្យឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម មានជាសាធារណៈ ដូច្នេះសមាជិកសហគមន៍អាចដើរតួនាទីកាន់តែប្រសើរក្នុងការគ្រប់គ្រងសកម្មភាពបង្គ្រោះថ្នាក់ដោយក្រុមហ៊ុន។

៤. ក្រុមហ៊ុនគួរតែចូលរួមក្នុងការដោះស្រាយវិវាទនៃការទិញយកដីដោយស្មោះត្រង់ ជៀសវាងការប្រើការគំរាមកំហែង ឬឧបាយកលបំភិតបំភ័យ ហើយត្រូវប្រាកដថាមានការពិគ្រោះយោបល់ជាសាធារណៈសម្រាប់សកម្មភាពថ្មីណាមួយពីសំណាក់ក្រុមហ៊ុន។

៥. អនុញ្ញាតឱ្យសមាជិកសហគមន៍បន្តរបៀបរស់នៅបែបប្រពៃណីរបស់ពួកគេ ជាពិសេសជនជាតិដើមភាគតិច រួមទាំងការប្រមូលផលអនុផលព្រៃឈើដែលមិនមែនជាឈើ និងការជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូច ដែលមានផលប៉ះពាល់តិចតួចដល់អេកូឡូស៊ី។

# ប្រវត្តិក្រុមហ៊ុន និងការដ្ឋាន អណ្ដូងរ៉ែ

## ក្រុមហ៊ុន ឌែលខម ខេមបូឌា (Delcom Kampuchea)

ក្រុមហ៊ុន ឌែលខម ខេមបូឌា Delcom (Kampuchea) PTE. Ltd ត្រូវបានបង្កើតឡើងដំបូងដោយសមាជិករដ្ឋសភាឈ្មោះ ថាវី ញ៉ែម ជាមួយនឹងជនជាតិម៉ាឡេស៊ី ឈ្មោះវីវេខាណាថាន ណាថាន (Vivekanathan Nathan) ដែលជាអភិបាលនៃក្រុមហ៊ុនពហុផលិតផលម៉ាឡេស៊ីដែលឥឡូវនេះឈ្មោះថាក្រុមហ៊ុនឌែលើម ប៊ែរហាដ (Deleum Berhad)។ លោកណាថាន (Nathan) ក៏ស្ថិតក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនឌែលខម នៅពេលបង្កើតក្រុមហ៊ុនផងដែរ។ ការផ្លាស់ប្ដូរកម្មសិទ្ធិដ៏ស្មុគស្មាញជាច្រើនបានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ២០០០ និងដើមទស្សវត្សរ៍ឆ្នាំ ២០១០ ដែលបណ្ដាលឱ្យមានការចូលរួមពីសាជីវកម្មម៉ាឡេស៊ី និងអាមេរិកផ្សេងទៀតនៅក្នុងគម្រោងនេះ។

មួយក្នុងចំណោមក្រុមហ៊ុនអាមេរិក ឈ្មោះក្រុមហ៊ុន អិលរ៉ាយ រីសូស (Elray Resources) ដែលត្រូវបានបង្កើតឡើង ក្នុងរដ្ឋនេវាដា (Nevada) សហរដ្ឋអាមេរិក។ ក្រុមហ៊ុនបានចុះបញ្ជីឈ្មោះលោក ចម ប៉ូរី ជាអភិបាលក្រុមហ៊ុនម្នាក់។ លោក ប៉ូរី ជាបង/ប្អូនប្រុសរបស់លោក ចម ប្រសិទ្ធ ដែលជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅពេលនោះ។

ក្រុមហ៊ុនមួយផ្សេងទៀតដែលបានចុះបញ្ជីនៅសហរដ្ឋអាមេរិក ឈ្មោះក្រុមហ៊ុនអង្គរវត្ត មីនីរ៉ល អិនខបភើរេតធីត (Angkor Wat Minerals Incorporated) បានបង្កើតក្រុមហ៊ុនសាខាសញ្ជាតិកម្ពុជាដែលមានឈ្មោះថាក្រុមហ៊ុ អង្គរវត្ត មីនីរ៉ល លីមីតធីត (Angkor Wat Minerals Limited) (AWML) ដោយលោកចម ប៉ូរី ត្រូវបានចុះបញ្ជីជាសមាជិកក្រុមប្រឹក្សាភិបាលជាថ្មីម្ដងទៀត។ ក្រុមហ៊ុនអាមេរិកគឺជាក្រុមហ៊ុនសាខារបស់ក្រុមហ៊ុន អិលរ៉ាយ រីសូស។ AWML បានកាន់កាប់ភាគហ៊ុន ៦០% ក្នុងក្រុមហ៊ុនបណ្ដាក់ទុនរួមគ្នាជាមួយក្រុមហ៊ុនឌែលខម ដែលបានកាន់កាប់ អាជ្ញាប័ណ្ណរុករក។

ដើម្បីបំពេញ លក្ខខណ្ឌតម្រូវ នៃច្បាប់ប្រទេសកាណាដាសម្រាប់ ការអនុលោមភាពរបស់អ្នកវិនិយោគ របាយការណ៍បច្ចេកទេសឯករាជ្យមួយត្រូវបានធ្វើឡើងដោយក្រុមហ៊ុន AWML ។របាយការណ៍បានបញ្ជាក់ថា ក្រុមហ៊ុនមិនបាន "អនុវត្តការពិនិត្យតាមផ្លូវច្បាប់ណាមួយលើភាពស្របច្បាប់ ឬ នៃដីរ៉ែនៅកម្ពុជា... (ហើយក៏មិន) បានស៊ើបអង្កេតហានិភ័យដែលគម្រោង អាចមានទាក់ទងនឹងតម្រូវការច្បាប់ថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់ស្រុកជាក់លាក់បញ្ហាម្ចាស់ដី/អ្នកកាន់កាប់ដី ឬបញ្ហាបរិស្ថានដែរ"។ ទោះបីជាមាន ការទទួលស្គាល់នេះក៏ដោយ របាយការណ៍ បានបន្ត ធ្វើការវាយតម្លៃទាក់ទងនឹងការផ្ដល់អាជ្ញាប័ណ្ណ និងចំណុចគោលអំពី ការផ្ដល់អាជ្ញាប័ណ្ណដែលសម្រេចបាន រហូតមក ដល់បច្ចុប្បន្ន។

## ក្រុមហ៊ុនអង្គរវត្ត មីនីរ៉ល លីមីតធីត AWML

ក្រុមហ៊ុន AWML ត្រូវបានទិញដោយក្រុមហ៊ុនហ្គោលម៉ាញ រីសូស ភីអិលស៊ី (Goldmine Resources Plc) ដែលជាក្រុមហ៊ុនចុះបញ្ជីនៅចក្រភពអង់គ្លេស ដែលបានផ្តល់ភាគហ៊ុនដល់ម្ចាស់កម្មសិទ្ធិពីមុនពេលគឺ ក្រុមហ៊ុនអិលវ៉ាយ រីសូស ដោយមានលោក ចម បូរី នៅតែស្ថិត ក្នុងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនដដែល។ បន្ទាប់ពីមានការចោទប្រកាន់ជាច្រើនថា អ្នកជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចត្រូវបានបណ្តេញចេញដោយបង្ខំនៅពាក់កណ្តាលឆ្នាំ ២០១១ លោក ចម បូរី បានលក់ភាគហ៊ុនរបស់គាត់នៅក្នុងក្រុមហ៊ុនអិលវ៉ាយ រីសូស។ ក្នុងឆ្នាំ ២០១២ ក្រុមហ៊ុនហ្គោលម៉ាញ រីសូស ត្រូវបានរំលាយ ហើយអស់រយៈពេលពីរបីឆ្នាំ ជោគវាសនានៃអាជ្ញាប័ណ្ណមានសភាពមិនច្បាស់លាស់ឡើយ។

ជម្លោះបន្ថែមទៀតត្រូវបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយរវាងតំណាងក្រុមហ៊ុន និងសហគមន៍មូលដ្ឋាននៅក្នុងឆ្នាំ ២០១៥។ បន្ទាប់មក ក្រុមហ៊ុនខៃលខម បានចាប់ដៃគូជាមួយសមាជិករដ្ឋសភាជាតិនៅពេលនោះ គឺលោក ងួន ញ៉ិល ដើម្បីបន្តសកម្មភាពរុករករបស់ខ្លួន ទោះបីជាភាគហ៊ុនរបស់គាត់ត្រូវបានលក់ជាបន្តបន្ទាប់ក្នុងឆ្នាំ ២០១៥ ទៅឱ្យ លោក ហ៊ិន ប៊ុនហៀង ដែលជាប្រធានអង្គភាពអង្គរក្សរបស់នាយករដ្ឋមន្ត្រីក៏ដោយ។

លោក ស សេរីវិចិត្រ ជាមន្ត្រីក្រោមឱវាទរបស់លោក ហ៊ិន ប៊ុនហៀង បន្ទាប់មកត្រូវបានគេមើលឃើញថាទទួលតួនាទីជា អ្នកទំនាក់ទំនងសហគមន៍នាពេលនេះ។ លោក ស សេរីវិចិត្រ ចូលរួមយ៉ាងសកម្មជាមួយអង្គភាពសម្ព័ន្ធនៅសហរដ្ឋអាមេរិករបស់គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច ។ អាជ្ញាប័ណ្ណដើមរបស់ក្រុមហ៊ុនខៃលខម បន្ទាប់មកផុតកំណត់នៅឆ្នាំ ២០១៦។ នៅឆ្នាំ ២០១៧ បណ្តឹងការចាប់យកដីស្រស់ៗត្រូវបានធ្វើឡើងដោយមានការចោទប្រកាន់ជាច្រើនថាពេលនោះលោក ហ៊ីង ប៊ុនហៀង កំពុងគ្រប់គ្រងក្រុមហ៊ុន ដែលនោះត្រូវបានបដិសេធដោយក្រសួងរ៉ែ និងថាមពល។

វិវាទជាក់លាក់រវាងអ្នកភូមិ និងក្រុមហ៊ុនដែលលើកឡើងដោយក្រុមបរិស្ថានចលនាមាតាធម្មជាតិ ត្រូវបាន ដោះស្រាយដោយមានការចូលរួមពីសមាជិកនៃអង្គភាពអង្គរក្សនាយករដ្ឋមន្ត្រី។ កលល្បិចនៅពីក្រោយឆាកជាបន្តបន្ទាប់ បានបណ្តាលឱ្យមានការណែនាំឱ្យស្គាល់ម្ចាស់ភាគហ៊ុនជនជាតិចិន និងប្រតិបត្តិកររ៉ែ ដូចជាអភិបាលក្រុមហ៊ុនខៃលខម បច្ចុប្បន្នជាលោកលី យីគុយ (Li Yikui) និងឈ្មោះលោកលី សុខថៃ ជាអភិបាលជំនួស។

### ក្រុមហ៊ុនស៊ិនហ្សាន Xinshan

ក្រុមហ៊ុនស៊ិនហ្សាន អ៊ិនដាសស្ទ្រៀល ខេមបូឌារ ខូ អិលធីឌី (Xinshan Industrial, Cambodia Co. Ltd) ត្រូវបានចុះបញ្ជីក្នុងខែមីនា ឆ្នាំ ២០១៥ នេះបើយោងតាមបញ្ជីអាជីវកម្មរបស់ប្រទេសកម្ពុជា។ ក្រុមហ៊ុនចុះឈ្មោះអភិបាលពីររូបដែលជាជនជាតិចិន។ ពួកគេម្នាក់ៗផ្តល់អាសយដ្ឋានផ្លូវការនៅក្នុងខេត្តហៃណាន អានហួយ (Hainan Anhui) ក្នុងប្រទេសចិន។ មានព័ត៌មានតិចតួចដែលរាយការណ៍អំពីក្រុមហ៊ុន លោក ស សេរីវិចិត្រ ដែលតំណាងឱ្យក្រុមហ៊ុនខៃលខម ជាអ្នកទំនាក់ទំនងសហគមន៍បានចូលរួមក្នុងការពិគ្រោះយោបល់ជាច្រើនជាមួយអ្នកភូមិតាងនាមឱ្យក្រុមហ៊ុនស៊ិនហ្សាន ។

### *ក្រុមហ៊ុនដែលត្រូវបានគ្រប់គ្រងដោយជនជាតិវៀតណាម*

អ្នកផ្តល់បទសម្ភាសបានលើកឡើងទាក់ទងជាមួយក្រុមហ៊ុនវៀតណាមដែលមិនត្រូវបានស្គាល់ផ្សេងទៀតដែលកំពុងធ្វើប្រតិបត្តិការគម្រោងខ្នាតតូចនៅក្នុងតំបន់នេះ។

*អភិបាលស្រុកបានថ្លែងថា «កុំធ្វើអាកប្បកិរិយាដូចជនជាតិកួយអី ព្រោះវាអាចជាទង្វើល្ងង់ខ្លៅ» ។*

## ប្រវត្តិភូមិ

តំបន់មួយធ្លាប់មានសុទ្ធតែជនជាតិដើមភាគតិចកួយរស់នៅច្រើន សមាជិកសហគមន៍នៅក្នុងភូមិទាំងពីរដែលបានផ្តល់បទសម្ភាសបាននិយាយថា ប្រជាជនក្នុងមូលដ្ឋានឥឡូវនេះភាគច្រើនជាជនជាតិខ្មែរ។ កាលពីមុន អ្នកភូមិជនជាតិដើមភាគតិចរស់នៅជិតព្រៃស្រោង ហើយពឹងផ្អែកលើផលិតផលអនុផលដែលមិនមែនជាឈើដើម្បីផ្គត់ផ្គង់ជីវភាព។ ឥឡូវនេះ អ្នកភូមិភាគច្រើនពឹងផ្អែកលើវិស័យកសិកម្មជាប្រភពចំណូលចម្បងរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋជាច្រើននៅតែប្រកបរបរជីកយករ៉ែមាសដោយដៃទ្រង់ទ្រាយតូច ជាពិសេសបន្ទាប់ពីការកាប់បំផ្លាញព្រៃឈើយ៉ាងឆាប់រហ័សបានដាក់កំហិតលើសមត្ថភាពរបស់ពួកគេក្នុងការពឹងផ្អែកលើការប្រមូលផលិផលអនុផលព្រៃឈើដែលមិនមែនជាឈើតែមួយមុខ។ អ្នកភូមិបានរាយការណ៍អំពីក្រុមហ៊ុនដែលកំពុងរុករកតំបន់នេះក្នុងឆ្នាំ ១៩៩៤ ដែលត្រូវបានបន្តដោយរលកនៃអ្នករុករកខ្នាតតូចនៅពេលក្រោយមកក្នុងទសវត្សរ៍នោះ។ ប្រតិបត្តិការជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចនៅក្នុងតំបន់នេះ ភាគច្រើនមានទីតាំងនៅជុំវិញភ្នំអន្លង់ ដែលជាភ្នំមួយនៅខាងកើតការដ្ឋានអណ្តូងរ៉ែរបស់ក្រុមហ៊ុនខៃលខម។ មានការជម្រុញខ្លាំងពីអាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ស្រុក ដើម្បីឱ្យសហគមន៍ជនជាតិ

ដើមភាគតិចទម្លាក់ចោលទំនៀមទម្លាប់វប្បធម៌របស់ពួកគេ។ អាជ្ញាធរមូលដ្ឋានបានធ្វើអត្ថាធិប្បាយជាច្រើននាពេលថ្មីៗនេះអំពីជនជាតិដើមភាគតិចនិងរបៀបរស់នៅបែបប្រពៃណីរបស់ពួកគេ ដោយបង្ហាញពីការមិនយកចិត្តទុកដាក់ឥតក្រែងរបស់មន្ត្រីចំពោះវប្បធម៌របស់ជនជាតិដើមភាគតិច និងអាចជាហេតុផលដែលស្ទាក់ស្ទើរក្នុងការជួយជនជាតិដើមភាគតិចក្នុងជម្លោះ។

អ្នកឆ្លើយសំណួរម្នាក់បាននិយាយថា ក្នុងអំឡុងពេលតវ៉ាឆ្នាំ ២០២១ដែលទាមទារឱ្យសហគមន៍ទទួលបានការគ្រប់គ្រងលើព្រៃបម្រុងវិញ មេឃុំរងបានមានប្រសាសន៍ថា "[របៀបរស់នៅរបស់ជនជាតិដើមភាគតិច] ហួសសម័យហើយ ហើយឥឡូវនេះយើងត្រូវរស់នៅតាមរបៀបទំនើបវិញ។"

ការធ្វើចំណាកស្រុកគឺជាចំណុចកត់សម្គាល់មួយនៅក្នុងសហគមន៍ ដោយមានប្រជាពលរដ្ឋជាច្រើនជាពិសេសស្ត្រីផ្លាស់ទៅប្រទេសថៃ ឬទីក្រុងភ្នំពេញដើម្បីទទួលបានឱកាសការងារដែលប្រសើរជាង។ អ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា នាងបានទៅធ្វើការនៅប្រទេសថៃ ១៥ ឆ្នាំមកហើយ ដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ។

អ្នកផ្តល់បទសម្ភាសទាំងអស់បានរាយការណ៍ថា ទាំងតំណាងក្រុមហ៊ុនឌៃលខម និងក្រុមហ៊ុនស៊ិនហ្សាន កំពុងដាក់សម្ពាធលើអ្នកភូមិឱ្យលក់ដីរបស់ពួកគេ ដោយផ្តល់សំណងទាបជាងតម្លៃទីផ្សារខ្លាំងប្រមាណពី ៥០០ ដុល្លារអាមេរិកទៅ ១.០០០ ដុល្លារក្នុងមួយហិកតា។ ប្រជាពលរដ្ឋត្រូវបានគំរាមកំហែងជាមួយនឹងការបណ្តេញចេញដោយបង្ខំ និងគ្មានសំណង ប្រសិនបើពួកគេមិនអនុវត្តតាម។

ពាក្យបណ្តឹងអំពីសិទ្ធិមនុស្សត្រូវបានដាក់ទៅអាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់ជាតិនៅឆ្នាំ ២០២១ រួមទាំងទៅកាន់ការិយាល័យរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នាពេលនោះផងដែរ ប៉ុន្តែហាក់ដូចជាមិនមានការឆ្លើយតបអ្វីច្រើនទេ។







# តំបន់ធ្វើអាជីវកម្មរ៉ែមាសរបស់ក្រុមហ៊ុន ដេលខំ និងស៊ីនសាន ខេត្តព្រះវិហារ ប្រទេសកម្ពុជា

**សញ្ញាសំគាល់**

- តំបន់ធ្វើអាជីវកម្មរ៉ែ ដេលខំ និងស៊ីនសាន
- អាងស្តុកទឹកកខ្វក់ដែលអាចមានជាតិពុល
- ភូមិស្ថិតនៅក្បែរ
- ភូមិដែលបានសំភាសន៍
- ផ្លូវ
- អូរ
- ព្រំប្រទល់ខេត្ត
- តំបន់ធ្វើអាជីវកម្មរ៉ែក្រុមហ៊ុនដេលខំ
- តំបន់ធ្វើអាជីវកម្មរ៉ែក្រុមហ៊ុនស៊ីនសាន
- សម្បទានរ៉ែក្រុមហ៊ុនដេលខំ និងស៊ីនសាន
- តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន: 1:420,000
ប្រព័ន្ធកូអរដោណេ: W.G.S 1984
ប្រភពទិន្នន័យ:
Opendevelopment.net, Esri SatelliteImagery, Google Earth, Handhelp GPS

## ការពិគ្រោះយោបល់ជាសាធារណៈ

វាហាក់ដូចជាមិនទាន់ធ្វើការពិគ្រោះយោបល់ជាសាធារណៈនៅឡើយ ក្រៅពីការប្រើប្រាស់យន្តការដោះស្រាយវិវាទ ដែលត្រូវបានសម្របសម្រួលដោយអាជ្ញាធរមូលដ្ឋាន ហើយយន្តការនេះត្រូវបានចុះផ្សាយតាមសារពត៌មាន។

ផ្ទុយទៅវិញ អ្នកផ្ដល់បទសម្ភាសភាគច្រើនបាននិយាយថា ការទិញយកដីកើតឡើងតាមរយៈការបំភិតបំភ័យ ឬការលក់ដីដោយបង្ខំ។ អ្នកផ្ដល់សម្ភាសម្នាក់បាននិយាយថា នៅពេលដែលប្រជាពលរដ្ឋព្យាយាមនិយាយទៅកាន់តំណាងក្រុមហ៊ុន តំណាងក្រុមហ៊ុនបានប្រាប់មកសហគមន៍វិញថា "យើងមិនចាំបាច់និយាយជាមួយអាជ្ញាធរមូលដ្ឋានទេ ព្រោះយើងមានអាជ្ញាប័ណ្ណពីថ្នាក់ជាតិ ពីក្រសួងរ៉ែ និងថាមពល" ។

កិច្ចប្រជុំពិគ្រោះយោបល់មួយត្រូវបានធ្វើឡើងនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ដោយមានការចូលរួមពីអភិបាលស្រុក សមាជិកក្រុមប្រឹក្សាស្រុក មន្ត្រីម្នាក់មកពីក្រសួងរ៉ែ និងថាមពល និងលោក ស សេរីវិចិត្រ និងអង្គរក្សប្រមាណ៥នាក់របស់គាត់។ នៅក្នុងកិច្ចប្រជុំនោះ ប្រជាពលរដ្ឋមកពីភូមិរំដេង និងត្រពាំងទទឹង ត្រូវបានប្រាប់ថា "ក្រុមហ៊ុនខៃលខម បានទទួល ផ្ទៃដីទំហំ ១.៨០០ ហិកតាសម្រាប់ការរុករក ហើយក្រុមហ៊ុនក៏មានអាជ្ញាប័ណ្ណចម្រាញ់ដីផងដែរ"។

ក្នុងកិច្ចប្រជុំនោះ មន្ត្រីបានណែនាំដល់អ្នកចូលរួមប្រជុំថា សកម្មភាពជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូច នៅជុំវិញភ្នំអន្លង់ឥឡូវជាសកម្មភាពខុសច្បាប់។ នៅពេលអ្នកភូមិព្យាយាមពិភាក្សារកដំណោះស្រាយដោយសម្រុះសម្រួល អភិបាលស្រុកបានថ្លែងថា «កុំធ្វើអាកប្បកិរិយាដូចជនជាតិកួយអី ព្រោះវាអាចជាទង្វើល្ងង់ខ្លៅ»។

ដំណើរការពិគ្រោះយោបល់ចាំបាច់ដូចកិច្ចប្រជុំថ្ងៃទី២៦ ខែមេសា គឺធម្មតាៗ ជាពិសេសអាជ្ញាប័ណ្ណផ្លាស់ប្ដូរដៃគ្នាជាញឹកញាប់ និងបន្តពង្រីកតំបន់រុករក។ ក្នុងស្ថានភាពបែបនេះ ប្រជាពលរដ្ឋត្រូវពឹងផ្អែកលើអាជ្ញាធរមូលដ្ឋានដើម្បីចរចាជាមួយភាគីពាក់ព័ន្ធក្រុមហ៊ុន។ ប៉ុន្តែមន្ត្រីឃុំ និងស្រុកក្នុងមូលដ្ឋាននៅក្នុងសហគមន៍មានការស្ទាក់ស្ទើរក្នុងការជម្រុញមតិរបស់អ្នកភូមិឱ្យខ្លាំង។ ទោះជាយ៉ាងនេះក្ដី ថ្មីៗនេះ មេឃុំក្នុងមូលដ្ឋានបានបង្ហាញឆន្ទៈបន្ថែមទៀតក្នុងការចូលរួមជាមួយមន្ត្រីក្រុមហ៊ុន តាងនាមឱ្យអ្នកភូមិ ប៉ុន្តែបន្ទាប់ពីនាងដឹងថា នាងអាចនឹងបាត់បង់ដីរបស់ខ្លួនទៅឱ្យ ក្រុមហ៊ុនទាំងនោះប៉ុណ្ណោះ។

វិវាទទាំងនេះក៏កើតឡើងផងដែរ ដោយសារតែអ្នកភូមិមានត្រឹមតែប្លង់ទន់ ប័ណ្ណកម្មសិទ្ធិដីដែលផ្ដល់ដោយមន្ត្រីក្នុងមូលដ្ឋាន និងមិនសូវមានសុវត្ថិភាព ដូចប្លង់រឹង ចំពោះដីធ្វើស្រែចម្ការ របស់ពួកគេ។ តំណាងក្រុមហ៊ុន និងបក្សពួករបស់លោក ស សេរីវិចិត្រ បាននិយាយថា អាជ្ញាប័ណ្ណរ៉ែដែលផ្ដល់ដោយក្រសួងមានឥទ្ធិពលជាងប្លង់ដីទន់។ អ្នកផ្ដល់បទសម្ភាស និយាយថា មិនមានការព្យាយាមពិតប្រាកដក្នុងការពិភាក្សាវែកញែក បញ្ហាស្មុគស្មាញទាំងនេះជាមួយ អ្នកភូមិទេ ផ្ទុយ ទៅវិញពួកគេកំពុងប្រឈមមុខនឹងការបំភិត បំភ័យ និងការគំរាមកំហែងពីសំណាក់មន្ត្រីអាជ្ញាធរមូលដ្ឋាន និងតំណាងក្រុមហ៊ុន។

# បុគ្គលិកក្រុមហ៊ុននិយាយទៅកាន់សមាជិកសហគមន៍ថា “យើងមិនចាំបាច់និយាយជាមួយអាជ្ញាធរមូលដ្ឋានទេ ព្រោះយើងមានអាជ្ញាប័ណ្ណពីថ្នាក់ជាតិ ពី ក្រសួងរ៉ែ និងថាមពល”

រឿងកាន់តែអាក្រក់ទៅទៀតនោះគឺ មិនមានយន្តការដោះស្រាយការខូចខាតជាផ្លូវការដែលត្រូវបានបង្កើតឡើងដោយក្រុមហ៊ុនឌែលខម ឬ ក្រុមហ៊ុនស៊ិនហ្សាន នោះទេ។ ក្រុមហ៊ុនកំពុងដោះស្រាយវិវាទដីធ្លីតាមករណីនីមួយៗ ដែលនាំឱ្យទទួលបានលទ្ធផលចំនួនពីរ៖ ប្រជាពលរដ្ឋដែលមានការទាមទារស្មុគស្មាញមិនត្រូវបានអើពើ ហើយមានតែអ្នកដែលមានការគាំទ្រខ្លាំងពីអង្គការក្រៅរដ្ឋាភិបាលក្នុងមូលដ្ឋានប៉ុណ្ណោះដែលអាចចរចាទាមទារសំណងបាន។

ឥឡូវនេះ ប្រជាពលរដ្ឋចំនួន ២០គ្រួសារបានរួមគ្នាដាក់ពាក្យបណ្តឹងរួមផ្លូវការស្របច្បាប់មួយ ទៅសាលាដំបូងខេត្តព្រះវិហារ។ មានតែដើមបណ្តឹងត្រឹមតែប្រាំបួននាក់ប៉ុណ្ណោះដែលនៅតែតតាំងនឹងរឿងក្តីនេះពួកគេត្រូវការពេលវេលា និងធនធានដ៏ច្រើន លើសលប់ដើម្បីទ្រទ្រង់បណ្តឹងតាមរយៈតុលាការ ដែលគេមើលឃើញថាមិនឯករាជ។

សរុបមក គំរូខាងលើគឺច្បាស់ណាស់៖ ក្រុមហ៊ុនឌែលខម និងក្រុមហ៊ុនស៊ិនហ្សាន បានយកដីរបស់ប្រជាពលរដ្ឋ ហើយបាន ជ្រើសរើសយកវិធីដោះស្រាយ ជម្លោះជាបន្តបន្ទាប់ ។

## ផលប៉ះពាល់សង្គម និងបរិស្ថាន

អ្នកអ្នកផ្តល់បទសម្ភាសបាននិយាយថា មានការបំផ្លិចបំផ្លាញខ្លាំងលើដីសហគមន៍ តំបន់ព្រៃឈើ និងដីកប់សពរបស់សហគមន៍ ដែលជាផ្នែកមួយនៃទំហំដីប្រតិបត្តិការជីករ៉ែមាសរបស់ក្រុមហ៊ុនទាំងពីរ។ យ៉ាងណាមិញ អ្នកភូមិខ្លះអាចយកដីបានមកវិញបានខ្លះ ហើយពួកគេបានធ្វើការឈូសឆាយសម្រាប់ធ្វើស្រែចម្ការរបស់ពួកគេ។

អ្នកផ្តល់បទសម្ភាសរាយការណ៍ពីការបំផ្លាញបរិស្ថានយ៉ាងខ្លាំងពីការបញ្ចេញសារធាតុគីមីនៅក្នុងប្រភពទឹកនៅក្បែរនោះ និងក្នុងខ្យល់។ អ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា ទឹកសំណល់ពីប្រតិបត្តិការជីករ៉ែគ្រប់គ្រងមិនបានល្អទេ ហើយជារឿយៗបំផ្លាញបរិស្ថានផ្នែកខាងក្រោមនៃប្រភពទឹក និងបំផ្លាញទីជម្រកធម្មជាតិ ។

អ្នកភូមិក៏រាយការណ៍ថា ការកាប់ឈើទ្រង់ទ្រាយធំបានចាប់ផ្តើមនៅឆ្នាំ ២០១៨ ហើយស្ទើរតែគ្មានព្រៃឈើនៅសល់នៅក្នុងតំបន់ជុំវិញភូមិរំចេក។ អ្នកផ្តល់បទសម្ភាសម្នាក់ទៀតបាននិយាយថា៖ «គិតត្រឹមឆ្នាំ ២០២២ សកម្មភាពកាប់ឈើបានឈប់ព្រោះលែងមានព្រៃសម្រាប់កាប់ទៀតហើយ»។

ការថយចុះគុណភាពបន្តិចម្តងៗនៃទឹកអូរ ស្រះ និងប្រឡាយពីការធ្វើប្រតិបត្តិការជីករ៉ែបានចាប់ផ្តើមនៅ

ឆ្នាំ ២០១០។ នេះបានធ្វើឱ្យអាជ្ញាធរស្រុក និងមន្ត្រីមន្ទីរបរិស្ថាននិយាយថាអ្នកភូមិគួរតែចាប់ផ្តើមទិញទឹកបរិសុទ្ធ ដោយសារតែប្រភពទឹកធម្មជាតិមានថ្មអាស៊ីតក្នុងកម្រិតខ្ពស់ ទោះបីជាដាំទឹកកខ្វក់ឱ្យពុះក៏ដោយ ក៏នៅតែមានថ្មអាស៊ីត។ ភូមិទាំងអស់ដែលរស់នៅតាមបណ្តោយផ្នែកខាងក្រោមប្រភពទឹកដែលត្រូវបានបំពុលឱ្យកខ្វក់ដោយក្រុមហ៊ុនខៃលខម បានកត់សម្គាល់ឃើញថា អូរ ដូចជាអូរញ្ញៅ អូរក្រសាំង និងអូរកន្សែងត្រូវបានរងប៉ះពាល់ដោយគុណភាពទឹកកខ្វក់ ដែលប៉ះពាល់ដល់រុក្ខជាតិ និងសត្វក្នុងទឹកក្នុងមូលដ្ឋាន ។ អ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា “គុណភាពទឹកត្រូវបានធ្វើតេស្តនៅរដូវវស្សា។ លទ្ធផលបានបង្ហាញថា កម្រិតនីត្រាត (NO3) ឡើងដល់លើសពី ១.០០០ ម.ក្រ/លីត្រ ដែលជាកម្រិតខ្ពស់ខ្លាំងណាស់ ។ ពណ៌ក្រហម [នៃទឹក] មានន័យថា វាត្រូវបានបំពុលយ៉ាងធ្ងន់ធ្ងរ»។ ប៉ុន្តែក្នុងរដូវវស្សាខ្លះ កម្រិតនីត្រាតមិនខ្ពស់បែបនោះទេ»។

ប្រជាពលរដ្ឋពីភូមិបង្កើនផលបានរាយការណ៍ថា ក្រុមហ៊ុនជីករ៉ែមាសទាំងពីរបានទទួលខុសត្រូវចំពោះការប្រើសារធាតុគីមី និងសារធាតុអាស៊ីតច្រើនសម្រាប់ការចម្រាញ់យកមាស ដែលបន្ទាប់មកហូរចូលខ្សែទឹកអូរធំ និងអូរពោធិ៍។ ខ្សែទឹកទាំងនេះតភ្ជាប់ទៅខ្សែទឹកស្ទឹងព្រៃប្រស់ ទន្លេស្ទឹងសែន និងចុងក្រោយចូលទៅក្នុងទន្លេមេគង្គ។

ស្រដៀងគ្នានេះដែរ ប្រជាពលរដ្ឋក្នុងភូមិត្រពាំងទទឹម និងភូមិរំដេងបានឈប់ប្រើទឹកពណ៌ក្រហមខ្មៅពីអូរ។ ការធ្វើតេស្តទឹកដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន អង្គការផលអនុផលព្រៃឈើ (Non-Timber Forest Products) បង្ហាញលទ្ធផលមិនល្អ និងបញ្ជាក់ពីស្ថានភាពបំពុលនៃអូរ។ សមាជិកសហគមន៍មួយចំនួនបាននិយាយថា ពួកគេនៅតែប្រើប្រាស់ទឹកអណ្តូង ឬទឹកពីជុំវិញភ្នំដែក ប៉ុន្តែពួកគេត្រូវចម្រោះ និងដាំទឹកឱ្យពុះ។ អ្នកភូមិបានព្យាយាមបន្ថែមឱសថរុក្ខជាតិទៅក្នុងទឹក ដើម្បីព្យាយាមកាត់បន្ថយក្លិនក្នុងទឹក។

អ្នកឆ្លើយសំណួរម្នាក់បាននិយាយថា នាងលែងដាំបន្លែទៀតហើយ ព្រោះទឹកឥឡូវនេះមានសារធាតុគីមី វាមានពណ៌ខ្មៅ និងមានរសជាតិជូរខ្លាំង ប៉ុន្តែខ្ញុំទម្លាប់នឹងរសជាតិនោះហើយឥឡូវនេះ » នាងបានបន្ថែមថា ត្រី ខ្យង ក្តាម សត្វល្អិត និងបង្កួយទាំងអស់ក៏ទម្លាប់ដែរ ប៉ុន្តែបានបាត់ខ្លួនពីក្នុង និងជុំវិញអូរហើយ។

ទាក់ទងនឹងទឹកជុំវិញភ្នំអន្លុង ប្រឡាយក្រុមហ៊ុនមួយហូរចូលអូរពោធិ៍ដោយផ្ទាល់។ អ្នកភូមិខ្លះប្រើទឹកនេះសម្រាប់ងូត ហើយបានរាយការណ៍ថាមានបញ្ហាស្បែករមាស់ និងរលាកស្បែក។

ការសម្ភាសបង្ហាញថាសុខភាពសហគមន៍បានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ។ អ្នកភូមិជាច្រើនរាយការណ៍អំពីការកើនឡើងនៃជំងឺមហារីក ការហើម ឈឺពោះ ភ្លេចភ្លាំង រលាកតម្រងនោម និងជុំសាច់នៅក្នុងសហគមន៍។ អ្នកភូមិត្រពាំងទទឹមម្នាក់បាននិយាយថា ចៅរបស់គាត់ដែលរស់នៅជិតក្រុមហ៊ុនជីករ៉ែមាសមួយក្នុងចំណោមក្រុមហ៊ុនទាំងពីរនោះ ត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺឆ្កួតជ្រូក និងគ្រុនក្តៅជាញឹកញាប់។

ស្រដៀងគ្នាដែរ ប្រជាពលរដ្ឋនៅភូមិបង្កើនផល និងភូមិត្រពាំងទទឹម បានឱ្យដឹងថា ក្រុមហ៊ុនជីកមាសបានឈូសឆាយដីផ្ទៃដីធំៗនៃព្រៃ ហើយបានចាប់ផ្តើមបំផ្លាញភ្នំអន្លង់ក្បែរនោះដោយគ្រឿងផ្ទុះ។

អ្នកផ្តល់បទសម្ភាសបានរាយការណ៍ថា អូរធំ ដែល សហគមន៍ប្រើប្រាស់គឺស្ងួតទាំងស្រុង និងមិនអាចប្រើប្រាស់បានទេ។

## បរិយាបន្នសង្គម សិទ្ធិការងារ និងសុខភាព និងសុវត្ថិភាពការងារ

កម្មករអណ្តូងរ៉ែបានកំណត់លក្ខណៈកន្លែងធ្វើការរបស់ពួកគេថាជាក្រុមហ៊ុនជីករ៉ែ"ខុសច្បាប់"មួយក្នុងចំណោមក្រុមហ៊ុនទាំងពីរ ដោយនិយាយថាក្រុមហ៊ុនមួយជាកម្មសិទ្ធិរបស់ជនជាតិចិន ហើយមួយទៀតជាកម្មសិទ្ធិរបស់ជនជាតិវៀតណាម។ អ្នកដែលត្រូវបានសម្ភាសទាំងអស់កំពុងធ្វើការដោយមានកិច្ចសន្យាបើកចំហ ដោយមិនមានកាលកំណត់បញ្ចប់ និងទទួលបានប្រាក់ឈ្នួលដោយបើកប្រាក់ប្រចាំថ្ងៃ។ កម្មករបាននិយាយថាក្រុមហ៊ុន "ខុសច្បាប់" មួយចំនួនបានបើកប្រាក់បន្ថែមម៉ោងឱ្យពួកគេតាមការស្នើសុំ ដោយបន្ថែម ១.៥ ដុល្លារអាមេរិកក្នុងមួយម៉ោងនៅពេលថ្ងៃ និង ២.៥ ដុល្លារអាមេរិកនៅពេលល្ងាច។ កម្មករបាននិយាយថា ពួកគេរកចំណូលបានប្រហែល ៣០០ដុល្លារអាមេរិក ទៅ ៥០០ ដុល្លារអាមេរិកក្នុងមួយខែ អាស្រ័យលើការងារ។

កម្មករបាននិយាយថា ពួកគេត្រូវបានផ្តល់ឧបករណ៍សុវត្ថិភាព ដូចជាស្បែកជើងកវែង មួកសុវត្ថិភាព ស្រោមដៃ ភ្លើងអំពូល/ពិល និងកំបាំងមុខ។ អ្នកដែលកំពុងធ្វើការនៅក្នុងរណ្តៅបានប្រើជណ្តើរយោងខ្សែកាប ហើយចុះទៅជម្រៅពី ៣០ ទៅ ៥០ ម៉ែត្រ ដោយប្រើវិទ្យុទាក់ទងដើម្បីទាក់ទងជាមួយប្រតិបត្តិករជណ្តើរយោងខ្សែកាប។ នៅពេលដែលនៅក្នុងរណ្តៅនោះ កម្មករបាននិយាយថា លក្ខខណ្ឌគឺល្អគួរសម បើទោះជាមានគ្រោះថ្នាក់ដែលអាចកើតមានដូចជាសម្លេងរំខាន ធូលី និងក្លិនដែលមិនស្គាល់ក៏ដោយ។ កម្មករបាននិយាយថា ពួកគេមិនបានទទួលការបណ្តុះបណ្តាលពីរបៀបធ្វើការមុនពេលចាប់ផ្តើមធ្វើការនៅការដ្ឋានអណ្តូងរ៉ែនោះទេ ហើយពួកគេត្រូវ«រៀនពីការងារ»ដោយខ្លួនឯង។ ពួកគេមិនមានថ្ងៃសម្រាកនៅថ្ងៃចុងសប្តាហ៍នោះទេ ហើយត្រូវបានផ្តល់ថ្ងៃឈប់សម្រាកត្រឹមតែមួយថ្ងៃប៉ុណ្ណោះសម្រាប់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលផ្ទុយពីថ្ងៃឈប់សម្រាករយៈពេលបីថ្ងៃដែលចេញដោយរដ្ឋាភិបាល។ កម្មករមិនមានសិទ្ធិទទួលបានការឈប់សម្រាកប្រចាំឆ្នាំ ការឈប់សម្រាកឈឺ ការឈប់សម្រាកលំហែមាតុភាព ប្រាក់បំណាច់អតីតភាពការងារ ឬបេឡាជាតិរបបសន្តិសុខសង្គមដែលអាចប្រើប្រាស់សម្រាប់សេវាការពារសុខភាព សេវាព្យាបាល និងសេវាថែទាំដែលផ្តល់មូលនិធិដោយរដ្ឋនោះទេ។ គួរកត់សម្គាល់ថាបុគ្គលិកម្នាក់បានពោលថានៅពេលដែលកម្មករថ្មីចាប់ផ្តើមធ្វើការជាមួយក្រុមហ៊ុនឌែលខម ពួកគេត្រូវបានពិនិត្យតាមដានដោយនគរបាលយោធាខណៈពេលដែលពួកគេកំពុងស្ថិតក្នុងការសាកល្បងការងារ។

កម្មករបានពោលថា ជាទូទៅក្រុមហ៊ុនឌែលខម គឺជាក្រុមហ៊ុនដ៏ល្អបំផុតក្នុងការធ្វើការជាមួយបើនិយាយពីលក្ខខណ្ឌនៅនឹងកន្លែងការងារ ដោយមានសុវត្ថិភាព និងលក្ខខណ្ឌល្អប្រសើរជាងរាល់ក្រុមហ៊ុន "ខុសច្បាប់" ។

ដោយក្តីកង្វល់ កិច្ចសម្ភាសបានអះអាងថាមានអ្នកស្លាប់នៅការដ្ឋានអណ្តូងរ៉ែដែលមិនត្រូវបានរាយការណ៍ពីមុនមក។ អ្នកផ្តល់បទសម្ភាសម្នាក់

បាននិយាយថា ពួកគេបានឮអំពី "អ្នកជំនាញខាងគីមីដែលធ្វើការឱ្យក្រុមហ៊ុនជីករ៉ែមាស ដែលបានស្លាប់ដោយសារវិធានការសុវត្ថិភាពមិនត្រឹមត្រូវ និងកង្វះឧបករណ៍ការពារ"។ យោងតាមអ្នកឆ្លើយសំណួរផ្សេងទៀត បុគ្គលិកជនជាតិចិនបីនាក់បានស្លាប់កាលពី បី ឆ្នាំមុនដោយសារតែការឆក់ខ្សែភ្លើង ប៉ុន្តែអ្នកផ្តល់បទសម្ភាសមិនច្បាស់ថាតើមានចំណាត់ការដោះស្រាយតាមផ្លូវច្បាប់ណាមួយដើម្បីបង្ការគ្រោះថ្នាក់បែបនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានព្រឹត្តិការណ៍នេះកើតឡើង ឬយ៉ាងណាទេ។

## ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ

អ្នកភូមិបាននិយាយថា ក្រុមហ៊ុនឌែលខម បានជួយសាងសង់អគារសាលាបឋមសិក្សានៅភូមិភ្នំដែក ប៉ុន្តែ ថាមិនមានការឧបត្ថម្ភបន្តសម្រាប់ការអប់រំហើយ ក៏មិនមានការសាងសង់ផ្លូវដែលត្រូវការចាំបាច់នោះទេ។ អ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា ក្រុមហ៊ុនពីមុនធ្លាប់បានថ្លែងបញ្ជាក់ប្រាប់ពួកគេថាផ្លូវនេះមិនត្រូវបានអភិវឌ្ឍទេ ដោយសារតែ "ពួកគេមិនចង់ឱ្យក្រសួង ឬអង្គការក្រៅរដ្ឋាភិបាលណាមួយរិះគន់ពួកគេ [សម្រាប់ការសាងសង់ផ្លូវ]" ។

អ្នកផ្តល់បទសម្ភាសបានរាយការណ៍ថា មានការកើនឡើងនូវតម្រូវការសម្រាប់បដិសណ្ឋារកិច្ច និងអាជីវកម្មខ្នាតតូចដូចជាអ្នកលក់អាហារ និងហាងលក់គ្រឿងទេសតូចៗ ដោយសារការកើនឡើងនូវចំនួនប្រជាជនក្នុងមូលដ្ឋានដែលធ្វើការនៅអណ្តូងរ៉ែ ។ ទោះបីជាមានការកើនឡើងនូវអាជីវកម្មនេះក៏ដោយ ក៏ប្រាក់ចំណូលនៅតែតិចតួច និងគ្រាន់ល្មមសម្រាប់ការចិញ្ចឹមជីវិតប៉ុណ្ណោះ។

# ករណីសិក្សា ទី៤

## ទីតាំង៖ ភូមិអូរត្រុន ខេត្តក្រចេះ

## ក្រុមហ៊ុនជីករ៉ែ៖ ស៊ីងយ័ន កាងយៀក ខូអិលធីឌី (Xing Yuan Kanng Yeak Co. Ltd.)

## សេចក្តីសង្ខេបនៃមតិត្រលប់អ្នកផ្តល់បទសម្ភាស

១. រដ្ឋាភិបាលគួរអនុញ្ញាតឱ្យប្រជាពលរដ្ឋចាប់ផ្តើមសកម្មភាពជីករ៉ែទ្រង់ទ្រាយតូចឡើងវិញនៅតំបន់នោះ និងផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ប្រជាពលរដ្ឋជីកអណ្តូងជម្រៅជ្រៅជាង ៥ ម៉ែត្រ ដើម្បីពួកគេអាចប្រើប្រាស់ទឹកបាននៅរដូវប្រាំង។

២. ប្រាក់ចំណូលមួយចំណែកធំដែលប្រមូលបានដោយរដ្ឋាភិបាលគួរតែយកទៅគាំទ្រសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ជាអវិជ្ជមាននៃប្រតិបត្តិការជីករ៉ែ។

៣. រាល់សកម្មភាពអភិវឌ្ឍន៍បន្ថែមទៀតពីក្រុមហ៊ុនស៊ីងយ័ន កាងយៀក ខូអិលធីឌី Xing Yuan Kanng Yeak ត្រូវតែមានការពិគ្រោះយោបល់ដោយប្រុងប្រយ័ត្នជាមួយសហគមន៍ក្នុងមូលដ្ឋានឱ្យបានទូលាយជាងនេះដោយ មិនត្រឹមតែជាមួយមេភូមិនោះទេ។

៤. ក្រុមហ៊ុនស៊ីងយ័ន កាងយៀក ខូអិលធីឌី (Xing Yuan Kanng Yeak) គួរបង្កើតដំណើរការជាប្រព័ន្ធមួយសម្រាប់ផ្តល់សំណងដល់ប្រជាពលរដ្ឋដែលបានបាត់បង់ដីធ្លីទៅឱ្យក្រុមហ៊ុន។

៥. ក្រុមហ៊ុនស៊ីងយ័ន កាងយៀក ខូអិលធីឌី (Xing Yuan Kanng Yeak) ត្រូវតែមានគ្រូពេទ្យផ្នែកវេជ្ជសាស្ត្រ ប្រព័ន្ធសង្គ្រោះបឋមត្រឹមត្រូវ និងការគាំទ្រផ្នែកថែទាំសុខភាពដែលប្រសើរខ្លាំងសម្រាប់កម្មកររបស់ខ្លួន។

៦. អ្នកជំនាញអណ្តូងរ៉ែឯករាជ្យត្រូវតែមកពិនិត្យការដ្ឋានអណ្តូងរ៉ែ ដើម្បីធានាសុវត្ថិភាពនៅការដ្ឋាន។

៧. ក្រុមហ៊ុនស៊ីងយ័ន កាងយៀក ខូអិលធីឌី (Xing Yuan Kanng Yeak) គួរផ្តល់អាទិភាពដល់អ្នកភូមិក្នុងមូលដ្ឋាន ក្នុងការទទួលបានការងារ។

៨. ក្រុមហ៊ុនគួរតែគោរពតាមបទប្បញ្ញត្តិការងាររបស់កម្ពុជា ដោយផ្តល់ច្បាប់ឈប់សម្រាកឈឺដែលមានប្រាក់ឈ្នួល និងអត្ថប្រយោជន៍នៅកន្លែងធ្វើការផ្សេងទៀត។

៩. អង្គការក្រៅរដ្ឋាភិបាលក្នុងមូលដ្ឋានគួរតែធ្វើការជាមួយប្រជាពលរដ្ឋ និងបង្កើនសមត្ថភាពរបស់ពួកគេក្នុងការយល់ដឹងឱ្យកាន់តែច្បាស់អំពីសិទ្ធិរបស់ពួកគេនៅក្រោមច្បាប់កម្ពុជា។

## ប្រវត្តិក្រុមហ៊ុន និងការដ្ឋានអណ្តូងរ៉ែ

ក្រុមហ៊ុនស៊ីងយ័ន កាងយៀក ខូអិលធីឌី Xing Yuan Kanng Yeak Co. Ltd ត្រូវបានចុះបញ្ជីក្នុងខែសីហា ឆ្នាំ ២០១១។ ក្រុមហ៊ុននេះហាក់ដូចជាមានទំនាក់ទំនងជាមួយសមាជិកព្រឹទ្ធសភារបស់គណបក្សកាន់អំណាចលោក ឡៅ ម៉េងឃីន។ តំបន់ដែលគ្របដណ្តប់លើការដ្ឋានអណ្តូងរ៉ែមួយ មានអាជ្ញាប័ណ្ណ រុករករ៉ែត្រួតគ្នា ដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនមួយឈ្មោះថាក្រុមហ៊ុន ហ្សុង ហ្ស៊ីន (Zhong Xin) ក្នុងពេលតែមួយ ដែលពីមុនត្រូវបានគេហៅថាក្រុមហ៊ុន ជីងហ្គូ មីនីរ៉ល (Jinqu Minerals)។ ក្រុមហ៊ុននេះមានអាសយដ្ឋានចុះបញ្ជីជាការិយាល័យ របស់ក្រុមហ៊ុនភាភីមិច (Pheapimex) ដែលជាក្រុមហ៊ុនពហុផលិតផលកម្ពុជាដែលត្រូវបានគ្រប់ គ្រងដោយគ្រួសាររបស់លោក ឡៅ ម៉េងឃីន (Lau Meng Khin)។

យ៉ាង ស៊ុភីងYang Shuping ត្រូវបានចុះជាប្រធានក្រុមហ៊ុនស៊ីងយ័ន កាងយៀក ខូអិលធីឌី (Xing Yuan Kanng Yeak) ហើយក៏ជាប្រធានក្រុមហ៊ុនយឺតតេប្របភីតធីមេនេចមែន (Yuetai Property Management) ដែលជាក្រុមហ៊ុនសាខា របស់ក្រុមហ៊ុន ហ្គ័ងស្យូ យឺតតេគ្រុបខូអិលធីឌី (Guangzhou Yuetai Group Co. Ltd). ដែលត្រូវបានចុះបញ្ជីនៅក្នុងផ្សារហ៊ុនទីក្រុងសៀងហៃផងដែរ។ ក្រុមហ៊ុនស៊ីងយ័ន កាងយៀក ខូអិលធីឌី (Guangzhou Yuetai Group) ដើមឡើយជាកម្មសិទ្ធិរបស់រដ្ឋ ហើយស្ថិតក្រោមឈ្មោះ ក្រុមហ៊ុន ហ្គ័ងស្យូ ដុងហ្គួ អ៊ីនដាស់ស្ទ្រៀលខូអិលធីឌី (Guangzhou Donghua Industrial Co., Ltd)។ ក្នុងឆ្នាំ ២០០១ ក្រុមហ៊ុនហ្គ័ងស្យូ (Guangzhou) ដុងហ្គួ (Donghua) បានចុះបញ្ជីក្នុងផ្សារហ៊ុនទីក្រុងសៀងហៃ ហើយបានប្តូរឈ្មោះទៅជា ក្រុមហ៊ុនហ្គ័ងស្យូ យឺតតេគ្រុប (Guangzhou Yuetai Group) ក្នុងឆ្នាំ ២០១៦។ នៅពេលនោះ ក្រុមហ៊ុនយឺតតេហូលឌីង (Yuetai Holdings) គឺម្ចាស់ភាគហ៊ុន ដែលមានសិទ្ធិគ្រប់គ្រង។ នាយកប្រតិបត្តិក្រុមហ៊ុនគឺ យ៉ាង ស៊ុភីង (Yang Shuping) ។ កូនប្រុសរបស់យ៉ាង ស៊ុភីង (Yang Shuping) ឈ្មោះ យ៉ាងស៊ុ (Yang Shuo) គឺជាថ្នាក់ដឹកនាំប្រតិបត្តិនៅក្រុមហ៊ុន។ ភាគទុនិករបស់ក្រុមហ៊ុនយឺតតេគ្រុប (Yuetai Group) ទាំងអស់ជាក្រុមហ៊ុនវិនិយោគដែលត្រូវបានគ្រប់គ្រងដោយឯកជន និងរូបវន្តបុគ្គល។

ក្រុមហ៊ុនយឺតតេគ្រុប (Yuetai Group) បានប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុ និងបញ្ហានិយតកម្មយ៉ាងធ្ងន់ធ្ងរក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ក្រុមហ៊ុននេះត្រូវបានផាកពិន័យសម្រាប់ការផ្សាយពាណិជ្ជកម្មមិនពិតនៅក្នុងប្រទេសចិន ហើយក៏ត្រូវបានពិន័យផងដែរសម្រាប់ការខកខានក្នុងការបង្ហាញចេញពីសំណាក់ផ្សារហ៊ុនទីក្រុងសៀងហៃ។ នាយកប្រតិបត្តិយ៉ាង ស៊ុភីង (Yang Shuping) ផ្ទាល់ត្រូវបានដាក់ទណ្ឌកម្មចំពោះការបំពានច្បាប់ផ្សេងៗ។ ប្រាក់ចំណេញរបស់ក្រុមហ៊ុនបានធ្លាក់ចុះចាប់តាំងពីឆ្នាំ ២០១៧។ ក្នុងខែសីហា ឆ្នាំ ២០២១ ត្រូវបានគេរាយការណ៍ថា ភាគទុនិកកំពូលមួយចំនួនរបស់ក្រុមហ៊ុន គ័ងស្យូ យឺតតេ (Guangzhou Yuetai) បានប្រកាសក្ស័យធន។ នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០២១ ប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន

យឺតតេ (Yuetai) បានលាលែងពីតំណែង។ ការបង្ហាញចេញដោយក្រុមហ៊ុន ហ្គ័ងស្សូ យឺតតេគ្រុប (Guangzhou Yuetai Group Co., Ltd) ក្នុងខែមករា ឆ្នាំ ២០២៣ ទៅកាន់ផ្សារហ៊ុនទីក្រុងសៀងហៃ បញ្ជាក់ថា វាមិនប្រាកដទេថាតើក្រុមហ៊ុនអាចបន្តជាក្រុមហ៊ុនជំនួញបន្ត ឬយ៉ាងណា។

យ៉ាង ស៊ុភីង (Yang Shuping) បានទទួលសញ្ជាតិខ្មែរនៅឆ្នាំ ២០១២ និង យ៉ាងស៊ុ (Yang Shuo) នៅឆ្នាំ ២០១៥ (ដោយដាក់ឈ្មោះថា សាមយឿង Sam Yeung)។ យ៉ាងស៊ុ (Yang Shuo) ក៏មានសញ្ជាតិកាណាដាផងដែរ។

ពេលមួយនៅក្នុងឆ្នាំ ២០១៤ ក្រុមហ៊ុនដើម ស៊ីងយ័ន កាងយៀក XYKY បានក្ស័យធន ហើយអាជ្ញាប័ណ្ណរុករកត្រូវបានផ្ទេរទៅម្ចាស់ថ្មី។ ការផ្លាស់ប្តូរកម្មសិទ្ធិមួយផ្សេងទៀតបានកើតឡើងនៅចន្លោះឆ្នាំ ២០១៥ និង ២០១៩ រហូតដល់ម្ចាស់បច្ចុប្បន្នបានកាន់កាប់អណ្តូងរ៉ែនៅឆ្នាំ ២០១៩ ។

ក្នុងអំឡុងពេលពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ អ្នកជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចក្នុងមូលដ្ឋាននៅអូរត្រុន បានឆ្លៀតឱកាសប្រមូលរ៉ែមាសដែលត្រូវបានបោះចោលដោយកម្មកររបស់ក្រុមហ៊ុននៅជុំវិញការដ្ឋានអណ្តូងរ៉ែដែលគេបោះបង់ចោល។ រហូតមកដល់សព្វថ្ងៃនេះ អ្នកភូមិខ្លះនៅតែប្រមូលដីនៅតាមផ្លូវក្បែររណ្តៅជីករ៉ែទំនេរមួយ។ មុនពេលក្រុមហ៊ុនចាប់ផ្តើមប្រតិបត្តិការឡើងវិញនៅឆ្នាំ ២០១៩ អ្នកជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចក្នុងមូលដ្ឋានបាននិយាយថាពួកគេអាចរកប្រាក់បានច្រើន ហើយឥឡូវនេះពួកគេកំពុងលក់រ៉ែដែលប្រមូលបានត្រឡប់ឱ្យក្រុមហ៊ុនវិញ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទំហំប្រតិបត្តិការជីករ៉ែបានកើនឡើងយ៉ាងខ្លាំង និងបានបន្ថែមបច្ចេកទេសចម្រាញ់ យកមាសរបស់ខ្លួនឱ្យកាន់តែខ្លាំងដោយប្រើប្រាស់ការកែច្នៃគីមី។ បច្ចុប្បន្នក្រុមហ៊ុន ស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) មានរណ្តៅមាសចំនួនប្រាំ ដែលនីមួយៗមានបី ឬបួនស្រទាប់ ជម្រៅប្រហែលសែសិបម៉ែត្រ។ ក្រុមហ៊ុនបានបញ្ជាក់ថា ខ្លួនគ្រោងនឹងជីករណ្តៅនីមួយៗឱ្យជ្រៅដល់ ៨០០ ទៅ ១០០០ ម៉ែត្រ។ ក៏មានរណ្តៅកាកសំណល់ ទំហំ ៥០០ម x ៥០០ម ដែលបានពង្រីងតាំងពីឆ្នាំ ២០១៩ មកម្ល៉េះ។







# តំបន់ធ្វើអាជីវកម្មរ៉ែមាសរបស់ក្រុមហ៊ុនស៊ីងយួនកាងយៀក ខេត្តក្រចេះ ប្រទេសកម្ពុជា

**សញ្ញាសំគាល់**

- តំបន់ធ្វើអាជីវកម្មរ៉ែ ស៊ីងយួនកាងយៀក
- អាងស្តុកទឹកកខ្វក់ដែលអាចមានជាតិពុល
- ភូមិដែលបានសំភាសន៍
- ផ្លូវ
- អូរ
- សម្បទានរ៉ែក្រុមហ៊ុនស៊ីងយួនកាងយៀក
- តំបន់ធ្វើអាជីវកម្មរ៉ែក្រុមហ៊ុនស៊ីងយួនកាងយៀក

មាត្រដ្ឋាន: 1:180,000

ប្រព័ន្ធកូអរដោណេ: W.G.S 1984

ប្រភពទិន្នន័យ:
Opendevelopment.net, Esri SatelliteImagery, Google Earth, Handhelp GPS

## ប្រវត្តិភូមិ

ភូមិអូរត្រួន ដើមឡើយមានឈ្មោះថា អូរតេកតោក(O'Tek Toak) (ឬ អូរក្លេកក្លោក(O'Klek Kloak) ហើយពីមុនមានជនជាតិដើមភាគតិចរស់នៅ។ ពួកគេបានអនុវត្តការជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចរហូតដល់ពាក់កណ្ដាលទស្សវត្សរ៍ឆ្នាំ ១៩៨០ នៅពេលដែលគ្រួសារខ្មែរជនជាតិដើមកាន់តែច្រើនបានផ្លាស់ទីលំនៅមកតំបន់នេះដើម្បីចូលរួមក្នុងសកម្មភាពជីករ៉ែ។ ក្រោយឆ្នាំ ១៩៩៧ មានជនជាតិខ្មែរដើមពី ៣០ ទៅ ៤០ គ្រួសារបន្ថែមទៀតបានផ្លាស់ទៅរស់នៅតំបន់នោះ។ ពួកគេបានចូលរួមក្នុងការជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចលក្ខណៈធម្មតាៗ និងមានសុវត្ថិភាពចំពោះបរិស្ថាន។ ពួកគេបានជីករណ្ដៅរាក់ ៗ វាយកំទេចថ្មធំ ៗ និងត្រងកម្ទេចថ្មដែលបែកមកដោយប្រើខ្ទះដើម្បីរើសបន្ទះមាសនិងធូលីដីចេញ។

ទោះបីជាមិនត្រូវបានទទួលស្គាល់ជាផ្លូវការថាជាភូមិមួយក៏ដោយ ក៏ឥឡូវនេះវាមានផ្ទះប្រហែល ៤០ ទៅ ៥០ គ្រួសារហើយ។ មេភូមិក្រៅផ្លូវការសម្ដែងការខកចិត្តចំពោះដំណើរការចុះឈ្មោះអូរត្រួនជាភូមិរដ្ឋបាលផ្លូវការមួយ។ លោកសម្គាល់ថា នៅពេលណាដែលលោកយកទុក្ខសោករបស់សហគមន៍ទៅក្រុមហ៊ុនជីករ៉ែ ដំណើរការចុះបញ្ជីនឹងជាប់គាំង។

ក្នុងឆ្នាំ ២០០៩ អ្នកជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចក្នុងមូលដ្ឋានត្រូវបាន បញ្ឈប់សកម្មភាពជីករ៉ែទាំងអស់ ហើយមានការប្រកាសជាផ្លូវការបន្ថែមទៀតត្រូវបានធ្វើឡើងនៅឆ្នាំ ២០១៥ ថាសកម្មភាពជីករ៉ែទាំងអស់នៅក្នុងតំបន់នេះគឺខុសច្បាប់។ តំណាងក្រុមហ៊ុននៅពេលនោះបានប្រាប់អ្នកភូមិថា "អ្នកអាចរស់នៅលើដីបាន ប៉ុន្តែអ្នកមិនអាចធ្វើអ្វីនៅក្រោមដីបានទេ"។

## ផលប៉ះពាល់សង្គម និងបរិស្ថាន

អ្នកផ្តល់បទសម្ភាសបានរាយការណ៍ថាសមត្ថភាពរបស់ពួកគេក្នុងការរកប្រាក់សមរម្យពីការជីកយករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចបានធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់ពីម្ចាស់ថ្មីរបស់ក្រុមហ៊ុន ស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) បានចាប់ផ្តើមការជីកយករ៉ែឡើងវិញនៅឆ្នាំ ២០១៩ ។ អ្នកឆ្លើយសំណួរម្នាក់បាននិយាយថា "ក្រុមហ៊ុនជីកយករ៉ែមាសបានបំបែក "ផ្ទាំងបាយរបស់អ្នកជីករ៉ែ"នៅអូរត្រុនដោយសំដៅដល់ឃ្លាជាភាសាខ្មែរដែលមានន័យថា ពួកគេមិនអាចទ្រាំទ្រនឹងការលំបាកនេះទេ។ អ្នកជីករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូច ជាច្រើនបាននិយាយថា ពួកគេបានប្តូរទៅធ្វើស្រែចម្ការវិញ ប៉ុន្តែប្រាក់ចំណូលរបស់ពួកគេទាបជាងមុនពេលក្រុមហ៊ុនបានមកដល់។

អ្នកភូមិបានរាយការណ៍ថាការផ្គត់ផ្គង់ទឹកក្រោមដីត្រូវបានកាត់បន្ថយយ៉ាងខ្លាំងបន្ទាប់ពីក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការកាន់តែខ្លាំងនៅក្នុងតំបន់ និងបានសាងសង់ផ្លូវមួយខ្សែដែលនាំឱ្យមានការខ្វះខាតទឹកបន្ថែមទៀតសម្រាប់ដំណាំកសិកម្ម។ ការជីកអណ្តូង ឬការប្រមូលទឹកក្នុងតំបន់។ អ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា "សកម្មភាពទាំងនេះត្រូវបានហាមឃាត់ និងចាត់ទុកថាខុសច្បាប់ ដោយគ្មានការអត់ឱន ឬការយល់ពីការលំបាករបស់អ្នកភូមិនោះទេ"។ ការសាងសង់ផ្លូវ អ្នកភូមិបានអះអាងថាក៏មានការកើនឡើងនូវឧប្បត្តិហេតុទឹកជំនន់ផងដែរ ដោយសារការសាងសង់បានបិទខ្សែទឹកអូររាម និងអូរតានឹម ដើម្បីបើកផ្លូវសម្រាប់ផ្លូវថ្មី ដែលក្រុមហ៊ុនប្រើប្រាស់ក្នុងការដឹកជញ្ជូនរ៉ែមាស។

មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើខ្សែទឹកអូរត្រុន ដែលប្រជាពលរដ្ឋបានប្រើប្រាស់សម្រាប់ទឹកផឹក មុនពេលប្រតិបត្តិការជីកយករ៉ែបានចាប់ផ្តើម។ ឥឡូវនេះ ប្រជាពលហូបតែទឹកបរិសុទ្ធ ឬច្រកទឹកតាមខ្លួន ឬប្រើទឹកពីអាងស្តុកទឹក ដែលត្រូវបានពិភាក្សានៅខាង ក្រោម។

អ្នកភូមិក៏បានសម្តែងការខកចិត្តផងដែរដែលក្រុមហ៊ុន ស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) បានឈូសឆាយទីតាំងកប់ផ្នូរបែបប្រពៃណីរបស់ពួកគេនៅជីព្រៃក្បែរភ្នំ។ ព្រៃនៅក្បែរនោះត្រូវបានក្រុមហ៊ុនកាប់ឆ្ការទាំងស្រុង ដែលធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពប្រមូលផលិតផល អនុផលព្រៃឈើ។ ធនធានធម្មជាតិដែលអាចប្រើប្រាស់បានហើយនៅសេសសល់តែមួយគត់ គឺអាងស្តុកទឹកដ៏ធំមួយដែលសាងសង់ដោយក្រុមហ៊ុនដី សម្បទានសេដ្ឋកិច្ចកសិកម្ម។ អ្នកភូមិត្រូវបានគេអនុញ្ញាតឱ្យប្រើប្រាស់អាងស្តុកទឹកដើម្បីនេសាទ និងប្រើប្រាស់ទឹក។

អ្នកឆ្លើយសំណួរក៏បានសម្តែងការខកចិត្តផងដែរ ដែលក្រុមហ៊ុនបានយកដីរបស់អ្នកភូមិមួយចំនួនដោយគ្មានសំណងណាមួយជាពិសេសទាក់ទងនឹងការសាងសង់រណ្តៅកាកសំណល់នៅខាងក្រៅបរិវេណ ជីករ៉ែ។ អ្នកភូមិម្នាក់បាននិយាយថា ពួកគេបានបាត់បង់ដីចំនួន ៣ហិកតា។

អ្នកភូមិបានត្អូញត្អែរពី ក្លិនគីមីធួលខ្លាំង" ពីសារធាតុគីមីដែលគេប្រើដើម្បីចម្រាញ់យកមាសនៅតំបន់ក្បែរបរិវេណក្រុមហ៊ុន។ ក៏មានស្នាមប្រេះធំលេចឡើងនៅក្នុងផ្ទះរបស់ពួកគេផងដែរ ដែលពួកគេបាននិយាយថា វាមកពីសកម្មភាពបំផ្ទុះនៅ

ក្រោមដី ហើយមានការបំពុលរំខានដោយសំឡេងជាញឹកញាប់។ អ្នកផ្តល់បទសម្ភាសម្នាក់បានបញ្ចេញមតិថា "ខ្ញុំកំពុងរស់នៅក្នុងស្ថានភាពសំឡេងរង្គើដូចគ្រាប់បែក ពេលពួកគេកាយថ្មកាន់តែជ្រៅ!" ប៉ុន្តែដោយសារការបំផ្ទុះបានចុះកាន់តែជ្រៅទៅៗក្រោមដី ពួកគេបាននិយាយថា បញ្ហានេះបានថមថយហើយ។

អ្នកភូមិប្រហែល ២០នាក់ បាននិយាយថា បច្ចុប្បន្នពួកគេកំពុងធ្វើការឱ្យក្រុមហ៊ុនស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) ខណៈដែលអ្នកដែលនៅសល់ជីកយករ៉ែមាសដោយដៃក្នុងទ្រង់ទ្រាយតូចនៅតំបន់ទំនេរ ឬចូលរួមសកម្មភាពកាប់ឈើឱ្យក្រុមហ៊ុន។ អ្នកផ្តល់បទសម្ភាសម្នាក់បាននិយាយថា "ពួកយើងជាអ្នកភូមិមិនដែលមានការរំពឹងទុកអ្វីទេ ទោះបីជាយើងបានឮថា ប្រតិបត្តិការជីករ៉ែនឹងផ្តល់ផលប្រយោជន៍ដល់រដ្ឋ ហើយការវិនិយោគនោះនឹងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនក្នុងមូលដ្ឋានមានភាពប្រសើរឡើងក៏ដោយ។ ប៉ុន្តែក្នុងនាមជាអ្នកជំនាន់ទីពីររបស់អ្នកភូមិអូរត្រុនទៅហើយ [អ្នកភូមិ] យើងមិនដែលទទួលបានអត្ថប្រយោជន៍ណាមួយពីចំណូលរដ្ឋដែលទទួលបានពីផលិតកម្មមាសនៅក្នុងតំបន់នេះទេ »។

## ការពិគ្រោះយោបល់ជាសាធារណៈ

ប្រជាពលរដ្ឋនៅតំបន់នោះបាននិយាយថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលបានធ្វើឡើងក្នុងឆ្នាំ ២០២១ មិនដែលត្រូវបានចែករំលែកជាមួយសហគមន៍មូលដ្ឋាននោះទេ។ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានរៀបរាប់ពី ការបាត់បង់ព្រៃឈើដែលអាចប៉ាន់ស្មានចំនួន ១៦% នៅក្នុងការវាយតម្លៃនោះ ទោះបីជាវិសាលភាពនៃចំនួនភាគរយនោះមិនត្រូវបានកំណត់ច្បាស់លាស់ក៏ដោយ។ យោងតាមផ្នែកមួយដែលទាក់ទងនឹងការបាត់បង់ទីជម្រក និងផលប៉ះពាល់លើសត្វព្រៃ ការសិក្សាបាននិយាយថានឹងមាន "ការបាត់បង់ព្រៃឈើប្រហែល ៦ ហិកតា" ដែលក្រោយមកត្រូវបានពិពណ៌នាថា "ភាគច្រើនជាដើមឫស្សី និង "ព្រៃចម្រុះ" ដែលមានដង់ស៊ីតេទាប។

នេះគឺផ្ទុយពីការអះអាងរបស់អ្នកភូមិដែលនិយាយថាដីព្រៃដែលមានតម្លៃខ្ពស់ត្រូវបានបាត់បង់ទៅឱ្យប្រតិបត្តិការរបស់ក្រុមហ៊ុន។

បន្ថែមពីនេះ របាយការណ៍បានពិភាក្សាអំពីការបាត់បង់ព្រៃឈើចំនួន ៦៦ ហិកតាសម្រាប់ការសាងសង់កន្លែងចាក់កាក សំណល់រឹង ហើយទទួលស្គាល់ថានឹងមានការបាត់បង់សត្វព្រៃ និងជីវចម្រុះដោយជៀសមិនរួច។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន កត់សម្គាល់បន្ថែមទៀតអំពីផលវិបាកដ៏គ្រោះថ្នាក់នៃការជ្រាបចូលបារតទៅក្នុងខ្យល់ និងសារសំខាន់នៃការធានាឱ្យបានថារណ្តៅបង្ហូរទឹកមិនស្ងួតចេញជាតិបារត។

កថាខណ្ឌ ១៧០ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើកឡើងដោយក្តីកង្វល់ថា "ទោះបីជាតំបន់នេះគ្មានមនុស្សរស់នៅក៏ដោយ ក៏ផលប៉ះពាល់នេះ (ការបំពុលដោយសម្លេង) នឹងប៉ះពាល់ដល់បុគ្គលិកដែលធ្វើការនៅទីនោះដែរ"។ នេះច្បាស់ណាស់ជាការរកឃើញភាន់ច្រឡំដែលគួរតែត្រូវបានដោះស្រាយដោយក្រសួងអនុម័តលើអាជ្ញាប័ណ្ណ។

ខណៈពេលដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានដាក់ជូនក្នុងឆ្នាំ ២០១២ ហើយវាអាចទៅរួចដែលក្រុមហ៊ុន ស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) បានធ្វើការសិក្សាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបន្តបន្ទាប់ ការសិក្សាទាំងនេះក៏មិនត្រូវបានចែករំលែក ហើយក៏ហាក់ដូចជាមិនមានការអនុលោមយ៉ាងតឹងរ៉ឹងជាមួយនឹងចំណុចរឹតត្បិតនានាដែលបាន

ចែងនៅក្នុងការវាយតម្លៃឆ្នាំ ២០១២នោះ ផងដែរ។ ជាសំខាន់ ការរកឃើញ និងផលប៉ះពាល់ដែលអាចបង្គ្រោះថ្នាក់ទាំងនោះមិនត្រូវបានចែករំលែកជាមួយសហគមន៍មូលដ្ឋានទាល់តែសោះ។

មានកិច្ចប្រជុំមួយជាមួយអ្នកភូមិដែលរៀបចំដោយក្រសួងបរិស្ថានក្នុងឆ្នាំ ២០២០ ដែលមន្ត្រីបាននិយាយថាអ្នកភូមិ "ត្រូវមានការយោគយល់គ្នាជាមួយក្រុមហ៊ុន" ហើយបានស្នើឱ្យអ្នកភូមិ "គួរតែជូនដំណឹងដល់ពួកគេសម្រាប់ដំណោះស្រាយប្រសិនបើមានបញ្ហាណាមួយពីសំណាក់ក្រុមហ៊ុន។"

កន្លងមក មន្ត្រីទាំងនោះបានបំពានការសន្យានេះ ដែលធ្វើឱ្យសមាជិកសហគមន៍មានការខកចិត្ត និងមិនអាចទទួលបានការឆ្លើយតបត្រឹមត្រូវចំពោះពាក្យបណ្តឹងតូញត្អែរទាក់ទងនឹងប្រតិបត្តិការរបស់ក្រុមហ៊ុនស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak)។ មានមនុស្សម្នាក់បាននិយាយថា ខណៈដែលក្រសួងបានចុះទៅពិនិត្យការដ្ឋានអណ្តូងរ៉ែជាប្រចាំ ពួកគេមិនដែលបានទាក់ទងជាមួយអ្នកភូមិទេ។

មេភូមិក្នុងមូលដ្ឋានមានតួនាទីសំខាន់ខ្លាំងណាស់ ព្រោះពេលណាអ្នកភូមិមានបណ្តឹងតូញត្អែរ ក្រុមហ៊ុននឹងស្តាប់តែពាក្យបណ្តឹងតូញត្អែរតាមរយៈមេភូមិតែប៉ុណ្ណោះ។

*សមាជិកសហគមន៍និយាយថា៖ "មានក្លិនគីមីខ្លាំង នៅតំបន់ក្បែរបរិវេណក្រុមហ៊ុនដែលក្រុមហ៊ុនបានប្រើសម្រាប់យករ៉ែមាស"*

## បរិយាបទសង្គម សិទ្ធិការងារ និងសុវត្ថិភាពការងារ

អ្នកភូមិដែលធ្វើការឱ្យក្រុមហ៊ុន ស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) បាននិយាយថា ប្រាក់ខែចាប់ផ្តើមមានចំនួនតិចណាស់ ហើយអ្នកភូមិអាចរកប្រាក់ចំណូលបន្ថែមដោយធ្វើកសិកម្ម ដែលជាចំណូល ចិត្តរបស់ពួកគេ។ ប្រជាពលរដ្ឋជាច្រើនជឿថា ប្រសិនបើពួកគេធ្វើការឱ្យក្រុមហ៊ុន ស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) ដីរបស់ពួកគេទំនងជាត្រូវបានយកដោយបង្ខំដោយក្រុមហ៊ុន។ ការបាត់បង់ដីនឹងអាចជាការហិនហោច ព្រោះពួកគេនឹងគ្មានទ្រព្យសម្បត្តិទុកឱ្យកូនៗរបស់ពួកគេឡើយ

អ្នកភូមិមូលដ្ឋានមួយចំនួនដែលបានធ្វើប្រតិបត្តិការជីករ៉ែមាសទ្រង់ទ្រាយតូចបាននិយាយថាពួកគេប្រឈម នឹងការរើសអើងពី សំណាក់ក្រុមហ៊ុនដែលមិនព្រមជួលពួកគេ។ ដូចបានរៀបរាប់មុននេះ អ្នកភូមិប្រហែល ២០នាក់ធ្វើការឱ្យក្រុមហ៊ុន។ បុរសៗ ត្រូវបានឱ្យធ្វើការនៅក្នុងរណ្តៅរ៉ែ ហើយស្រីៗឱ្យធ្វើការនៅខាងក្រៅរណ្តៅរ៉ែ។ ជាធម្មតាបុរសត្រូវបានផ្តល់កិច្ចសន្យារយៈពេលវែងជាង និងទទួលបានប្រាក់ឈ្នួលច្រើនជាង "ប្រតិបត្តិការជីករ៉ែខុសច្បាប់ផ្សេងទៀតនៅក្នុងតំបន់"។ ក្រុមហ៊ុនក៏ផ្តល់ការធានារ៉ាប់រងគ្រោះថ្នាក់ជាមូលដ្ឋានផងដែរ ប៉ុន្តែធានារ៉ាប់រងនេះ អាចស្នើទាមទារបាន លុះត្រាតែកម្មករ របួស "ចេញឈាម" ប៉ុណ្ណោះ។ អ្នកភូមិបាននិយាយថា ពួកគេពេញចិត្តក្នុងការទទួលបានធានារ៉ាប់រងគ្រោះថ្នាក់ ប៉ុន្តែបានចង្អុលបង្ហាញថា មិនមានគ្រូពេទ្យនៅនឹងកន្លែងនោះទេ ហើយទីតាំងអណ្តូងរ៉ែមិនមានត្រៀមសម្ភារវេជ្ជសាស្ត្រត្រឹមត្រូវ ឬឧបករណ៍សង្គ្រោះបឋមនោះទេ។

ក្រុមហ៊ុនមិនអនុញ្ញាតឱ្យពួកគេមានច្បាប់ឈប់សម្រាក ដែលមានប្រាក់ឈ្នួល អត្ថប្រយោជន៍

សន្តិសុខសង្គម ឬអត្ថប្រយោជន៍ផ្សេងទៀតរបស់កម្មករទេ។ យោងតាមកម្មករម្នាក់ ក្រុមហ៊ុននឹងអនុម័តច្បាប់ឈប់សម្រាកឈឺ ប៉ុន្តែកាត់ប្រាក់ខែរបស់ពួកគេទៅតាមចំនួនសមាមាត្រ។

អ្នកផ្ដល់បទសម្ភាសបាននិយាយថា កាលពីមុនក្រុមហ៊ុនមានការពិបាកក្នុងការបើកប្រាក់ឈ្នួលជាទៀងទាត់ ប៉ុន្តែថ្មីៗនេះក្រុមហ៊ុនបានបើកបៀវត្សរ៍ទាន់ពេល ដោយមានការពន្យារពេលម្ដងម្កាលដែលអាចមានរយៈពេលពីបីសប្ដាហ៍។ ប្រាក់ឈ្នួលមានចាប់ពី ៣០០ ដុល្លារអាមេរិកដល់ ៦០០ ដុល្លារអាមេរិក អាស្រ័យលើតួនាទីជាក់លាក់។

កម្មករបានរាយការណ៍ថាមិនមាន "ការតំរង់ទិសគ្រប់ជ្រុងជ្រោយសម្រាប់កម្មករថ្មីទេ" ហើយត្រូវបានផ្ដល់ឱ្យត្រឹមតែ "ការណែនាំខ្លីៗសម្រាប់ការចាប់ផ្ដើមការងារ"ប៉ុណ្ណោះ ។ គ្រឿងបរិក្ខារសម្រាប់ការងារ និងគ្រឿងបរិក្ខារសុវត្ថិភាពត្រូវបានផ្ដល់ឱ្យកម្មករ ប៉ុន្តែចំណាយលើបរិក្ខារនេះត្រូវបានកាត់ចេញពីប្រាក់ខែរបស់ពួកគេក្នុងអំឡុងពេលសាកល្បងរយៈពេលបីខែ។

កម្មករបានរាយការណ៍ថា មានក្លិនអាស៊ីតធុលខ្លាំងនៅកន្លែងធ្វើការ។ ពួកគេបានបន្ថែមថា មានមនុស្សស្លាប់នៅក្នុងរណ្ដៅដោយសារការបាក់ដី។ គ្រួសាររបស់កម្មករម្នាក់ដែលបានស្លាប់ក្នុងឧបទ្ទវហេតុមួយត្រូវបានផ្ដល់សំណងចំនួន ១០.០០០ ដុល្លារអាមេរិក ដោយកម្មករបច្ចុប្បន្នម្នាក់បាននិយាយថាពួកគេត្រូវទទួលយក «ហានិភ័យខ្ពស់ព្រោះខ្ញុំក្រណាស់»។

កម្មករបានសម្ដែងការព្រួយបារម្ភថាមន្ត្រីក្រសួងបរិស្ថាន និងរ៉ែបាននិយាយទៅកាន់បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) ប៉ុន្តែមិនបានធ្វើការតាមដាន ឬត្រួតពិនិត្យសុវត្ថិភាពនៃហេដ្ឋារចនាសម្ព័ន្ធអណ្ដូងរ៉ែនោះទេ ដូចជាប្រព័ន្ធអគ្គិសនី និងប្រព័ន្ធទឹក ផ្លូវដើរ ឬការសំអាតជាដើម។ ដោយគ្មានប្រព័ន្ធត្រួតពិនិត្យឯករាជ្យ កម្មករបាននិយាយថា ហានិភ័យនៃគ្រោះថ្នាក់មានកម្រិតខ្ពស់។

*សមាជិកសហគមន៍និយាយថា៖ "ទាំងក្រុមហ៊ុនរ៉ែមាស ឬក្រុមហ៊ុនថ្មម៉ាប មិនបានផ្ដល់អត្ថប្រយោជន៍ផ្ទាល់ណាមួយដល់អ្នកភូមិអូត្រូនយើងនោះទេ"*

## ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ

អ្នកភូមិបាននិយាយថា ផ្លូវល្អៗក្នុងភូមិជួយឱ្យពួកគាត់ធ្វើដំណើរកាន់តែងាយស្រួល។ អ្នកភូមិនិយាយថា ផ្លូវថ្មល់ដែលបានកែលម្អនេះមានអត្ថប្រយោជន៍ច្រើនជាងចំពោះប្រតិបត្តិការរបស់អណ្ដូងរ៉ែ ហើយថា ខណៈពេលដែលពួកគេទទួលបានអត្ថប្រយោជន៍ដោយប្រយោលនៃការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនេះ វាមិនសមតម្លៃឡើយបើធៀបនឹងភាពអវិជ្ជមានទាំងអស់ដែលក្រុមហ៊ុន ស៊ីងយ័ន កាងយៀក (Xing Yuan Kanng Yeak) បាននាំមកក្នុងភូមិ។

អ្នកផ្តល់បទសម្ភាសម្នាក់បានអធិប្បាយថា "ទាំងក្រុមហ៊ុនជីករ៉ែមាស ឬក្រុមហ៊ុនថ្មម៉ាប មិនបានផ្តល់អត្ថប្រយោជន៍ផ្ទាល់ណាមួយសម្រាប់ពួកយើងអ្នករស់នៅអូរគ្រុនទេ។ “ទោះបីពួកគេបានសាងសង់ផ្លូវមួយក្នុងភូមិក៏ដោយ តាមទស្សនៈរបស់ខ្ញុំ វាពិតជាមិនល្អទាល់តែសោះព្រោះយើងបានបាត់បង់ធនធានធម្មជាតិរាប់មិនអស់ជាថ្នូរនឹងផ្លូវមួយ។ វាសម្រាប់តែគោលបំណងដឹកជញ្ជូនរបស់ពួកគេប៉ុណ្ណោះ”។

អ្នកផ្តល់បទសម្ភាសផ្សេងទៀតបាននិយាយថា មានឱកាសកាន់តែច្រើនសម្រាប់អាជីវកម្មខ្នាតតូចដែលផ្គត់ផ្គង់ដល់ប្រជាកម្មករនៅអណ្តូងរ៉ែ ហើយសេវាទូរស័ព្ទចល័តកាន់តែប្រសើរឡើងនាពេលថ្មីៗនេះ។

អ្នកផ្តល់បទសម្ភាសបាននិយាយថា ក្រុមហ៊ុនផ្តល់ថ្នាក់ភាសាចិនដល់កុមារក្នុងមូលដ្ឋានដែលបង្រៀនដោយអ្នកបកប្រែរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនក៏បានផ្តល់មូលនិធិក្នុងការកែលម្អសាលារៀនក្នុងមូលដ្ឋាន និងបានផ្តល់សម្ភារសិក្សាដល់កុមារនាពេលកន្លងមក។

## សេចក្តីសង្ខេប

បញ្ហាធំៗនៅតែមានក្នុងតំបន់។ អ្នកភូមិបង្ហាញការព្រួយបារម្ភជុំវិញការកាប់បំផ្លាញព្រៃឈើនាពេលបច្ចុប្បន្ន និងការបន្តកាប់ព្រៃឈើ។ ការលក់ដីដោយបង្ខំនៅតែមានបន្តដោយអ្នកភូមិជាច្រើននាក់ត្អូញត្អែរអំពីដីដែលត្រូវបានគេយកដោយបង្ខំ ហើយមិនបានទទួលសំណងអ្វីសោះ។ អាជ្ញាធរមូលដ្ឋានហាក់ដូចជាមិនអាណិតអាសូរចំពោះផលប្រយោជន៍របស់អ្នកជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូច និងកសិករសោះឡើយ។ ខណៈដែលការងារល្អមួយចំនួនត្រូវបានដំណើរការដោយក្រុមហ៊ុនទាក់ទងនឹងការគាំទ្រសហគមន៍ អ្នកភូមិយល់ថាការគាំទ្រនោះបណ្តាលឱ្យបរិស្ថានក្នុងមូលដ្ឋានរងការខាតបង់ក្នុងកម្រិតខ្ពស់ពេក។ ការគាំទ្របន្ថែមទៀតចាំបាច់តែត្រូវបាន ផ្តល់ឱ្យពីថ្នាក់ជាតិដើម្បីជួយដល់អ្នកជីករ៉ែមាសដោយដៃទ្រង់ទ្រាយតូចក្នុងមូលដ្ឋាន។ លក្ខខណ្ឌសុវត្ថិភាពនៅការដ្ឋានអណ្តូងរ៉ែចាំបាច់ត្រូវកែលម្អឱ្យបានច្រើន រួមជាមួយនឹងការផ្តល់កិច្ចព្រមព្រៀងការងារដែលមានលក្ខណៈកាន់តែប្រសើរដោយគោរពតាមច្បាប់ឈប់សម្រាក និងអត្ថប្រយោជន៍បន្ថែមដែលអាចទទួលបានក្រោមច្បាប់ការងារកម្ពុជា។

*សមាជិកសហគមន៍ម្នាក់បាននិយាយថា៖ «ទោះបីជាគេបានសង់ផ្លូវនៅក្នុងភូមិខ្ញុំក៏ដោយ តាមការខ្ញុំយល់របស់ខ្ញុំវាមិនល្អទាល់តែសោះដោយសារយើងបានបាត់បងធនធានធម្មជាតិជាច្រើនរាប់មិនអស់ជាថ្នូរនឹងផ្លូវមួយនេះ។ វាសម្រាប់តែគោលបំណងដឹកជញ្ជូនរបស់ក្រុមហ៊ុនប៉ុណ្ណោះ»*

## អនុសាសន៍

១. មន្ត្រីដែលពាក់ព័ន្ធត្រូវគិតគូរពីក្តីកង្វល់របស់សហគមន៍មូលដ្ឋានឱ្យបានម៉ត់ចត់ ហើយចំណាយធនធានបន្ថែមទៅក្នុងការដោះស្រាយវិវាទដោយស្មោះត្រង់ នៅក្នុងតំបន់សំខាន់ៗ ដែលការជីកចម្រាញ់យករ៉ែមាសកំពុងធ្វើឡើង ជុំវិញការទន្ទ្រានយកដី។ នេះគួរតែត្រូវបានជម្រុញដោយការផ្តោតជាបន្ទាន់លើការចេញអាជ្ញាប័ណ្ណជីកចម្រាញ់យករ៉ែថ្មី បន្ថែមពីលើការត្រួតពិនិត្យជាផ្លូវការគ្រប់ជ្រុងជ្រោយ និងជាប្រព័ន្ធលើអាជ្ញាប័ណ្ណរុករកដែលមានស្រាប់។

២. ប្តេជ្ញាចុះឈ្មោះដើម្បីក្លាយជាដៃគូអនុវត្តន៍នៃគំនិតផ្តួចផ្តើមស្តីពីតម្លាភាពឧស្សាហកម្មនិស្សារណកម្ម ហើយចាប់ផ្តើមដំណើរការជានាថាប្រទេសកម្ពុជាគោរពតាមគោលការណ៍និងលក្ខខណ្ឌតម្រូវការនៃស្តង់ដារ។

៣. អនុវត្តយ៉ាងតឹងរឹងនូវគ្រប់ច្បាប់និងបទបញ្ញត្តិទាំងឡាយ ទាក់ទងនឹងការចេញអាជ្ញាប័ណ្ណរុករករ៉ែ និងធ្វើអោយប្រាកដថាក្រុមហ៊ុនអាជីវកម្មរ៉ែមានការទទួលខុសត្រូវចំពោះមុខច្បាប់ និងអនុវត្តបាននូវគ្រប់ដំណាក់កាលនៃអាជីវកម្មរុករករ៉ែ។

៤. ធ្វើការសន្យាឡើងវិញចំពោះវេទិកាសន្ទនាសង្គមស៊ីវិលទាំងអស់រួមទាំង វេទិកាអភិបាលកិច្ចវិស័យឧស្សាហកម្មនិស្សារណកម្ម (EIGF), បណ្តាញផលប៉ះពាល់សង្គមនិងបរិស្ថានដោយឧស្សាហកម្មនិស្សារណកម្ម (EISEI) និងសម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន (CRRT)។

៥. បន្ថែមកិច្ចខិតខំប្រឹងប្រែងឡើងវិញដើម្បីចូលរួមជាមួយអង្គការសង្គមស៊ីវិលដែលផ្តោតលើការជួយជនជាតិដើមភាគតិចកម្ពុជា ដោយទទួលស្គាល់ជាផ្លូវការថាសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិពិសេសដូចដែលបានទទួលស្គាល់ដោយសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចដែលកម្ពុជាជាហត្ថលេខីមួយ។

៦. បង្កើនធនធានសម្រាប់មន្ត្រីក្រសួងបរិស្ថានដើម្បីវាយតម្លៃការខូចខាតចំពោះបរិស្ថានដែលបច្ចុប្បន្នបណ្តាលមកពីអណ្តូងរ៉ែមាសសកម្មដែលមានស្រាប់ ។ ចាត់វិធានការដើម្បីផ្អាកប្រតិបត្តិការណាមួយដែលបង្កើតការខូចខាតចំពោះបរិស្ថាន និងផ្តល់ជំនួយដល់ប្រតិបត្តិករ ដើម្បីធានាថាប្រតិបត្តិការរបស់ពួកគេអនុលោមតាមស្តង់ដារអន្តរជាតិ និងច្បាប់បរិស្ថានកម្ពុជា។

៧. បង្កើតយន្តការពិនិត្យឡើងវិញយ៉ាងតឹងរឹង ដែលអាចផ្តល់ដំណោះស្រាយយ៉ាងមានប្រសិទ្ធិភាពសម្រាប់សហគមន៍រងផលប៉ះពាល់ ហើយធ្វើការដោះស្រាយរាល់បញ្ហា និងការព្រួយបារម្ភទាំងឡាយទាក់ផលប្រយោជន៍ សង្គម និងផលប៉ះពាល់បរិស្ថានអោយបានល្អប្រសើរ។



អង្គការ សមធម៌កម្ពុជា
equitable cambodia